# ណូហ្គូជី ហ៊ីដេយោ
# 野口英世

និពន្ធដោយ បាបា ម៉ាសាវ

បកប្រែដោយ ប៉ែន សេដ្ឋារិន



DAIDO THE DAIDO LIFE FOUNDATION





KODOMO NO DENKI ZENSYÛ 4 NOGUCHI HIDEYO
Text copyright © 1968 by Masao Baba
First published in Japan in 1968 by Poplar Publishing Co., Ltd.
Khmer translation rights directly arranged with Poplar Publishing Co., Ltd.
Published in Cambodia by The Daido Life Foundation, 2006
The Khmer version Publication arranged by Phnom-Penh printing house.
© Khmer Edition : The Daido Life Foundation
© Khmer Text : Ms. Penn Setharin
All rights reserved. No part of this book may be reproduced or utilized in any form or by any means, electronic or mechanical, without prior written permission from the publisher.
The Photographs and Images except appeared in original NOGUCHI HIDEYO in this book are used with the kind permission of THE HIDEYO NOGUCHI MEMORIAL ASSOCIATION.

# ឈូងជី ហ៊ីដេយ៉ោ





រូបគំនូរណូងូជី ហ៊ីដេយ៉ោ ដែលគូរដោយខ្លួនលោកផ្ទាល់



អ្នកម្ដាយត្រកងសេសាគីដែលដួលក្នុងជើងក្រានសឹងតែបាត់ព្រលឹង ។
ឯសេសាគីវិញ គិតតែពីស្រែកយំក្ដែងៗ ។



នៅរដូវធ្លាក់ទឹកកក ម្តាយសេសាគីបានទៅធ្វើការលីសែងជាមួយកម្មករ លីសែងប្រុសៗ។ សេសាគីបារម្ភពីម្តាយ តែងតែទៅទទួលដល់ជើងភ្នំ ។



នៅពេលដែលឃើញម្ដាយដែលដើរត្រុកៗលុយព្រឹលតាមផ្លូវដ៏ងងឹត
សេសាគី រត់សំដៅមក ដោយស្រែកថា :  ម៉ែ !



ណូហ្គូជី ហ៊ីដេយោ ដែល បានក្លាយទៅជាវិរបុរសនៃពិភពលោក បានត្រឡប់
មកភូមិកំណើតវិញ ។ ម្ដាយនិងកូនចាប់ដៃគ្នាអរដោយបានជួបគ្នាជាថ្មី ។

# ជំរាបសួរមិត្តអ្នកអាន

កាលពីខ្ញុំនៅជាសិស្សសាលាបឋមសិក្សា រៀនថ្នាក់ទី៦ នៅឡើយ សាលារៀនបាននាំពួកយើងធ្វើដំណើរទៅលេងភូមិកំណើតរបស់លោក *ណូងូជី ហ៊ីដេយោ*។ នៅពេលនោះ លោកគ្រូ *កុបាយ៉ាស៊ី* ដែលមិត្តអ្នកអាននឹងជួបនៅក្នុងសាច់រឿងជាបន្ទាប់ទៅនេះ មិនទាន់ទទួលអនិច្ចកម្មនៅឡើយទេ។

លោកគ្រូ កុបាយ៉ាស៊ី គឺជាអ្នកដែលរកឃើញទេពកោសល្យរបស់ ណូងូជី ហ៊ីដេយោ ហើយបានអូសទាញកុមារនេះអោយចូលទៅក្នុងសៃរៀននៃការស្រាវជ្រាវ ព្រមទាំងបានខិតខំយ៉ាងស្វិតស្វាញដើម្បីព្យាបាលដៃពិការរបស់កុមារនេះ រហូតទាល់តែគេបានក្លាយជា "*ណូងូជី*" នៃពិភពលោក។

វេលានោះ ខ្ញុំនៅតូចនៅឡើយ ខ្ញុំស្តាប់ប្រសាសន៍លោកគ្រូ កុបាយ៉ាស៊ី បណ្តើរ គិតបណ្តើរថា នៅពេលដែលខ្ញុំធំឡើង ខ្ញុំនឹងខំរៀន ឱ្យបានទៅជាមនុស្សប្រសើរដូច *ហ៊ីដេយោ* អញ្ចឹងដែរ។
ហើយបើទោះជាមិន
បានស្មើគាត់ក៏សុំ ឱ្យ
ត្រឹមតែជិតស្មើ



គាត់ក៏បានដែរ ។

ក្រោយពីនោះមក ខ្ញុំបានទៅលេងភូមិនោះច្រើនដង ។ ផ្ទះកំណើតរបស់ ហ៊ីដេយោ នៅដដែល ហើយចង្ក្រានដែលគេធ្លាក់ចូលទៅឡើងរលាកដៃ ក៏នៅដូចមុនដដែលដែរ ។ នៅក្នុងសួនច្បារ គេឃើញផ្ទាំងថ្មដែលចារពាក្យដែលគេចូលចិត្ត "*នីងតាយ*" បកប្រែថា "អំណត់ទ្រាំ" ។ ភ្នំ *បាន់ដៃ* ឈរជង្រ្គឹងខ្ពស់ទៅលើលំហអាកាស ។ បើយើងបែរទៅក្រោយ យើងនឹងឃើញទន្លេ *អ៊ីណាវ៉ាស៊ីរ៉ូ* ដែលមានទឹកពេញព្រៀបទូលាយល្វើយល្វឹង ។

ជីវិតរបស់ ណូហ្គូជី ហ៊ីដេយោ ដែលបានបរិច្ចាគដើម្បីមនុស្សជាតិ បានដាស់ទឹកចិត្តយើងម្នាក់ៗឱ្យមានកំឡាំងកំហែងខំប្រឹងប្រែង ។

អ្នកនិពន្ធ *បាបា ម៉ាសាវ*



# មាតិការឿង



# មាតិការឿង


| អត្ថបទ | ទំព័រ |
|---|---|
| វលោកទឹកក្តៅ | ១៤ |
| អ្នកម្តាយ | ២២ |
| ក្មេងក្រងង់ | ៣២ |
| លោកគ្រូតូច | ៤៥ |
| លោកគ្រូ កុបាយ៉ាស៊ី | ៥៤ |
| លោកគ្រូពេទ្យ វ៉ាតាណាបេ | ៦៤ |
| ជំហានទី១ទៅកាន់វិជ្ជាពេទ្យ | ៦៩ |
| អតិសុខុមទស្សន៍ជារបស់ចំឡែកមែន | ៧៧ |
| លោកគ្រូពេទ្យ ជិវ៉ាគី | ៨៥ |
| ក្មេងបំរើគេបានក្លាយទៅជាគ្រូ | ៩៨ |

| | |
|---|---|
| ពី សេសាគី ទៅ ហ៊ីដេយោ | ១១០ |
| ឯងគង់តែនឹងឃើញទេ ចាំមើលទៅ | ១១៦ |
| ការចេញដំណើរទៅស្រុក អាមេរិក | ១២៩ |
| ការស្រាវជ្រាវរកពិសពស់ | ១៤០ |
| ការទៅសិក្សានៅអឺរ៉ុប | ១៥០ |
| វិជ្ជាស្ថាន រ៉ុកហ្វេល័រ | ១៥៧ |
| ពីការស្រាវជ្រាវមួយទៅការស្រាវជ្រាវមួយទៀត | ១៦៧ |
| ត្រឡប់ទៅភូមិកំណើតជាទីស្រឡាញ់និងរលឹក | ១៧៧ |
| ការប្រយុទ្ធនឹងជម្ងឺគ្រុនខាន់លឿង yellow fever | ១៩២ |
| ដំណើរទៅអាហ្វ្រិក | ២០៨ |
| សេចក្តីពន្យល់ដោយ តាកាណុ រ៉ុគីរ៉ូ | ២២១ |
| ប្រវត្តិរបស់ ណ្ហូងូជី ហ៊ីដេយោ | ២៤០ |
| រូបថតឯកសារផ្សេងៗ | ២៤២ |

<u>អ្នកនិពន្ធ</u> : *បាបា ម៉ាសាវ* កើតនៅឆ្នាំ១៩១៣ នៅខេត្ត*ហ៊ីគី ស៊ីម៉ា*។ ចេញពីសាលាគរុកោសល្យ *តុស៊ីម៉ាគី តូគ្យូ*។ ធ្វើគ្រូ បង្រៀននៅសាលាបឋមសិក្សា *សេយយោង៉ាគីអិន*។ ជា សមាជិកនៃសមាគមអ្នកនិពន្ធរឿងកុមារជាអ្នកនិពន្ធ រឿង "*ឪសណោយ*" "*ស៊ីបួយ សាកាអិ*" "*ស៊ីស៊ីតិ មិអេគិជ*" "*កញ្ច្រោងហ៊ីហា*" ជាដើម។

<u>បកប្រែដោយ</u> ប៉ែន សេដ្ឋារិន សាស្ត្រាចារ្យមហាវិទ្យាល័យ



អ្នករៀបចំដេស្លាញ : *ណាំបា អាតស៊ុី*

អ្នកគំនូរក្របក្រៅ : *គិង៉ាវ៉ា ហ៊ុដេអុ*

គំនូរ : *យ៉ាម៉ាណាកា ហ៊្វីយុជ*

រឿងពិតនៃមហាបុរសក្នុងពិភពលោក

# ឈូនូជី ហ៊ីដេយោ





# ស្លោកទឹកក្តៅ

-មេនាង *អ៊ីន* ម៉ែឯងមកវិញរឺនៅចៅ?

-ចាំនៅទេយាយ ។

-ចុះ *សេសាគី* គេងលក់ស្រួលអត់ធ្វើទុក្ខទេរឺ?

-ចាំ យាយ ។ អាអូនដេកលក់ស្រួលទេ ។

នៅក្នុងបន្ទប់ដែលងងឹតព្រាលៗ គេឮសូរជីដូនដែលមានត្រចៀកធ្ងន់ទៅហើយ និយាយឆ្លើយឆ្លងជាមួយនឹងចៅស្រីដែលមានអាយុ៤ឆ្នាំ ឈ្មោះនាង អ៊ីនុ ។

នាងតូច អ៊ីនុ ចាំម្តាយយូរពេកក៏ទ្រាំលែងបាន ហើយស្ទុះចេញទៅក្រៅមើលផ្លូវម្តាយ ។

រដូវផ្ការីកជិតកន្លងផុតទៅហើយៗរដូវក្តៅកំពុងតែឈានជើងចូលមកបន្តិចម្តងៗជាលំដាប់ ។ គឺជាពេលវេលាដែលអ្នកស្រុក អ្នកភូមិរវល់ជាងពេលណាៗទាំងអស់ ក្នុងមួយ

ឆ្នាំ ។ ស្មៅពណ៌បៃតងព្រមទាំងស្លឹកឈើទាំងឡាយទទួល
ពន្លឺ ពីព្រះអាទិត្យដែលហៀបអស្ដង្គត ចាំងភ្លឺផ្លេកព្រាកៗ ។
-ម៉ែ ! ម៉ែ !

-មេនាង កូនឯងចេះណាស់ ។ កូនចេះចាំផ្ទះបានល្អល្មមមែន ។

នេះបានគេហៅថាកូនល្អ ។

-ម៉ែអើយ ខ្ញុំឃ្លានបាយណាស់ម៉ែ ។ ខ្ញុំខំចាំម៉ែអើយចាំ ។

-អើ អើ ម៉ែដាំបាយឱ្យ(អោយ) កូនញ៉ាំឥឡូវហើយ ។

អ្នកម្ដាយត្រឡប់មកពីស្រែភ្លាម គ្មានពេលដាក់គូថសំរាក មួយដង្ហើមទេ។ អ្នករវាំសរវើរៀបចំអាហារសំរាប់ពេលល្ងាច ភ្លាមមួយរំពេច ។ អ្នកបង្កាត់ភ្លើង ហើយដាក់ឆ្នាំងដាំស្ល ។ គ្រាន់តែមានវត្តមានអ្នកតែប៉ុណ្ណេះ ក៏បន្ទប់ដែលងងឹតព្រាលៗ អំបាញ់មិញ ហាក់ដូចជាឡើងភ្លឺចិញ្ចាចភ្លាមមួយរំពេច ។

ទឹកដែលដាក់ដាំលើជើងក្រាន បានឡើងក្ដៅ ចេញកូន ពពុះប្រូចៗ ។

ទារករូបល្អសមសួន កំពុងដេកលក់សុខក្សេមក្សាន្តក្នុង អង្រឹងផ្ដៅ ។

អ្នកម្តាយ ដោយបានឃើញកូនដេកលក់ស៊ុបស្ងួន ក៏ស្ងប់ចិត្តឥតបារម្ភ ហើយដើរចេញទៅក្រៅដើម្បីរកបេះបន្លែឯក្រោយផ្ទះមកដាំស្ល ។ កំពុងតែបេះ ស្រាប់តែឮសូរសំឡេងកូនង៉ាស្រែកយំវ៉ាស ។ អ្នកបន្ទីបន្ទាន់រត់មកវិញ ។ ពេលនោះស្រាប់តែឃើញកូនង៉ាវារទៅដួលក្នុងជើងក្រានដែលមានដាំទឹកក្តៅពុះប្រូច១ ។ វាប្រហែលជាបានលូកដៃចូលទៅក្នុងឆ្នាំងដែលដាំទឹកក្តៅនោះហើយ ។ អ្នកម្តាយស្ទុះទៅត្រកងឱបបុត្រ ប៉ុន្តែពេលនោះ ដៃឆ្វេងរបស់ទារកបានរលាកទឹកក្តៅឡើងក្រហមរងាល និងរលេះរលួយស្បែកអស់បាត់ទៅហើយ ។



គេតោងតែប្រញាប់ប្រញាប់ព្យាបាលជាបន្ទាន់ ទើបអាចសង្គ្រោះបាន។ ប៉ុន្តែនៅទីនោះគ្មានគ្រូពេទ្យទេ។ ថ្នាំសង្កូវក៏គ្មានដែរ។ ភូមិដែលនៅជិតៗនោះសោតក៏គ្មានពេទ្យដែរ។ អ្នកភូមិដែលមានថ្នាំលាប គេអាណិត គេហុចថ្នាំឱ្យយកមកលាប។ អ្នកម្ដាយបានយកកន្ទបកណ្ដាចមករុំរបួសឱ្យ(អោយ) បុត្រ។

-*សេសាគី* កូនម្ដាយ ! ម្ដាយអាណិតអ្នកណាស់ ! ព្រះអើយជួយកូនខ្ញុំផងព្រះអង្គ។

អ្នកម្ដាយខិតខំថែរក្សារបួសរបស់កូនទាំងយប់ ទាំងថ្ងៃមិនហ៊ានសំរាកឡើយ។ វេលាងងុយក៏តាំងយកចន្ទាសឬស្សីមកទល់ភ្នែក កុំឱ្យនិទ្រាលក់កើត។

វេលាដែលបានខិតខំថែរក្សា ទ្រាំរបួសបុត្រចំនួន២០ថ្ងៃទៅ *សេសាគី* បានរួចចាកផុតពីសេចក្ដីស្លាប់ ប៉ុន្តែដៃរបស់គេឡើងក្រងង់ ដូចជាដុំពកនៃដើមស្រល់។ មេដៃរបស់ *សេសាគី* ក្ដោបចូលទៅលើ កដៃ។ ម្រាមកណ្ដាលឡើងទៅកក

ជាប់នៅកណ្ដាលបាតដៃ រីឯម្រាមដទៃទៀត ជ្រុះខាងចុងអស់នៅកំបុត១។ ប៉ុន្តែតោងគិតថា នេះជាសំណាងមួយនៅក្នុងគ្រោះទាំងមួយរយទៅចុះ ដោយវាជាដៃឆ្វេង។

គ្រោះរលាកនេះ កើតឡើងនៅពេលដែល *ណូហ្គូជី សេសាគី* មានអាយុ២ខួប។

គ្រាដែលនៅតូចនៅឡើយ មិនទាន់ដឹងថាខ្លួនពិការ មិនពេញលេញ ក៏ចេះតែសប្បាយ លោតបាក់ទៅតាមសភាវៈជាក្មេង។ មាតាវេលាដែលឃើញបែបនេះម្ដង១ ក៏ខ្សឹកខ្សួលអាណិតកូនបណ្ដើរលើកដៃប្រណម្យទៅលើ ឱ្យកូនលើកលែងទោសឱ្យខ្លួននៅក្នុងចិត្តបណ្ដើរ។





-*សេសាគី* ! សូមអ្នកអភ័យទោសឱ្យម្តាយផង។ ដោយសារតែម្តាយប្រហែស ហើយទើបបានជាអ្នក ទៅជាពិការយ៉ាងនេះ។

រួចហើយ អ្នកម្តាយនិយាយនឹង *សេសាគី* ថា :

-កូនអើយបើដៃអ្នកក្រងែងបែបនេះ ធំឡើងទៅធ្វើស្រែធំការយ៉ាងម៉េច? រស់យ៉ាងម៉េចទៅកូន? យើងក្រ គ្មានលុយរៀន មានតែធ្វើការងារកំឡាំងបាយតពូជ តែកូនឯងនេះទាល់តែប្រើកំឡាំងប្រាជ្ញាហើយ ទើបរស់បាន។ ម៉ែនឹងខំរកលុយទុកឱ្យ(អោយ)កូនរៀន ម៉ែនឹងខំធ្វើការមួយទ្វេជាពីរជាបី។ ទោះជាលំបាកយ៉ាងណាក៏ម៉ែខំដែរ ដូច្នេះ ចូរកូនខំរៀន ខំរៀនឱ្យ(អោយ)បានចេះច្រើនណាំ កូន ណាំ។

*សេសាគី* បានធំឡើង ហើយចូលទៅរៀននៅសាលាបឋមសិក្សា។ បើរាប់ពីឥឡូវទៅ គឺជាប់ជាង១០០ឆ្នាំហើយ។ ពោលគឺនៅ ខែមេសា ឆ្នាំ១៨៨៣។



# អ្នកម្ដាយ

គ្រួសាររបស់ *សេសាគី* មានដីស្រែចំការតិចតួចណាស់ ។ បើរំពឹងតែរស់ដោយសារតែដីស្រែចំការប៉ុណ្ណោះ រស់ទៅមិនរួចទេ ។ ម្ដាយឪពុក *សេសាគី* តោងតែទៅស៊ីឈ្នួលគេ យកលុយដែលបានបន្ដិចបន្ដួចមកបន្ថែមដើម្បីរស់ ។



ផ្ទះកំណើតរបស់ សេសាគី ខុសគ្នានឹងសព្វថ្ងៃយ៉ាងខ្លាំង

កម្មអ្វី ឪពុក *សេសាគី* ចូលចិត្តពិសារស្រា តែងតែយក លុយដែលបានពីស៊ីឈ្នួលគេ ទៅតៀមស្រា ហើយមិនដែល មានលុយយកមកផ្ទះឱ្យបានម្តងទេ។ ហើយក៏មិនដែលរវល់ ពីកូនប្រពន្ធទៀតផង។

ដូច្នេះ បន្ទុកគ្រួសារទាំងមូល ត្រូវធ្លាក់មកលើម្តាយ *សេសាគី* តែម្នាក់ឯងគត់។

មានពេលមួយនោះ មានពាក្យចចាមអារាមថា មាន ព្រាយអសុរកាយ ចេញមកលងមនុស្សនៅក្នុងភូមិ។

-វើយ អាដែង ! អញឮ (លឺ) គេថា មានខ្មោចលងសំបើម ណាស់ ភូមិយើងឥឡូវ។

-អើ អញក៏ឮ(លឺ) អញ្ចឹងដែរ។

-ឮ(លឺ)គេថា មានព្រាយសក់វែងស្រកាក ចេញពីក្នុងបឹង មកលងមនុស្សរាល់តែយប់។ អញ្ចឹងមែនឬ?

-អើអញឮ(លឺ)តែគេថាដែរ។ អញវាឆ្ងល់ តើខ្មោចព្រាយ ឯណាគេ។ ចង់ទៅរកមើលឱ្យឃើញច្បាស់នឹងភ្នែកម្តង។

ៗ ចាំមកកាប់ខ្មោច។ កុំអីមិនរីវរធំទៅហើយទេឬ



់ៗនាំគ្នាសំពះសុំទោសម្ដាយ *សេសាគី* ផ្ដិតផ្ដូងៗ
បោតជើងសព្រាតទៅភូមិវិញអស់ទៅ។ តើមាតា
*ហាគី* ធ្វើបែបនេះធ្វើអ្វី? នៅពេលដែលគាត់ផ្ដេក
្ញាយឱ្យដេកលក់អស់ហើយ អ្នកម្ដាយលបដើរចេញ

ពីផ្ទះយ៉ាងស្ងៀមស្ងាត់មិនឱ្យ(អោយ)នរណាចាប់ភ្លឹក សំដៅមកបឹងនេះ។

អ្នកយកសំណាញ់កញ្ចាស់ ផ្ទះធ្លាយលិចកើតបង់បានកូនត្រី កូនកំពិសយកទៅលក់ឯផ្សារនៅពេលព្រលឹមស្រាង១។

ពេលដឹងដំណឹងនេះ ពួកអ្នកភូមិរឹងរឹតតែនាំគ្នាកោត និងអាណិតមាតាកំសត់ដែលគិតកូនដល់ថ្នាក់នេះ។

ឯ *សេសាគី* ក៏បែបនោះដែរ នៅពេលដែលដឹងថា មាតាខិតខំដើម្បីខ្លួន ក៏នៅស្ងៀមលែងកើត ហើយសុំខ្លួនប្រើដៃដែលក្រងង់ ជួយធ្វើស្រែចំការ ជួយចាប់កូនត្រី កូនកំពិសយកទៅលក់ដែរ។

នៅពេលដែលឮកូននិយាយបែបនេះ អ្នកម្ដាយមិនត្រេកអរទេ។ ចិត្តអ្នកចង់បានតែម្យ៉ាងគឺឱ្យកូនខិតខំរៀនសូត្រ។ -*សេសាគី* ម្ដាយត្រេកអរ និងសាធុចំពោះចិត្តបុណ្យរបស់កូនដែលគិតដល់ម្ដាយណាស់។ បើកូនមានពេលសំរាប់ជួយ

ម្ដាយ ចូរកូនយកពេលនោះទៅរៀនសូត្រទៅវិញទៅ ម្ដាយ អរជាង។

អ្នកម្ដាយតែងតែនិយាយពន្យល់កូនបែបនេះជានិច្ច។

នៅស្រុកនោះ តែដល់ខែវស្សាម្ដងៗ ព្រីលធ្លាក់ច្រើនណាស់។ ដូច្នេះហើយ ការធ្វើដំណើរពីភូមិមួយទៅភូមិមួយមានការលំបាកជាខ្លាំង។ សូម្បីតែសេះក្ដី បើព្រីលធ្លាក់ត្រូតៗគ្នា ហើយគរជាកំរាលក្រាស់ឃ្មឹកទៅ វានឹងជាន់ផុងៗ ដើរទៅមុខមិនរួចឡើយ។ នៅពេលបែបនោះ មានតែផ្លូវមួយ៉ាងគត់ គឺរំពឹងលើកំឡាំងបាយមនុស្សប្រុស។ គេជួលកម្មករប្រុសៗ ឱ្យលីពុនរបស់ធ្ងន់ៗឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀត។ ការងារប្រើកំឡាំងបាយបែបនេះ បានប្រាក់ឈ្នួលថ្លៃជាងការងារធម្មតា មួយជាពីរ។

ម្ដាយរបស់ *សេសាគី* បានទៅអង្វរគេ សុំអោយគេទទួលយកគាត់ធ្វើជាកម្មករលីពុនដែរ។

-អ្នក *ស៊ីកា* ទោះជាអ្នកថាមានកំឡាំងមាំមួន ក៏ទៅមិនរួចដែរ ។ សូម្បីតែមនុស្សប្រុស ក៏ថ្ងូរទៅហើយ នៅពេលយ៉ាប់ខ្លាំង ។ ព្រីលធ្លាក់គ្រូតគ្នាសឹងតែដល់ចង្កេះឯនោះ មិនងាយទេ ។

ទោះជាគេបដិសេធបែបនេះក្តី ក៏ម្តាយ *សេសាគី* មិនញញើតដែរ ។ គាត់អង្វរករគេរងោច១ ទាល់តែគេសុខចិត្ត ។

-បើនិយាយហើយមិនជឿ អ្នកឯងសាកធ្វើសាក ពីរ បីថ្ងៃលមើលទៅ ។

ទឹកចិត្តដែលមុះមុត ប៉ងប្រាថ្នា ធ្វើអ្វីក៏កើតដែរ ។ ម្តាយរបស់ *សេសាគី* បានប្រកបការងារជាកម្មករលីសែង ដ៏លំបាកក្រៃលែង ក្នុងចំណោមកម្មករលីសែងប្រុស១ទាំងឡាយ ។

*សេសាគី* បារម្ភនឹងម្តាយណាស់ តែងតែដើរទៅចាំមើលផ្លូវម្តាយ រហូតដល់ចុងភូមិដែលនៅចង្កេះភ្នំ ។ មាតាដើរង៉ក់១តាមផ្លូវក្រោលព្រីលដែលឡើងងងឹតទៅហើយ ។ គ្រាន់

តែឃើញស្រមោលមាតាភ្លាម *សេសាគី* ស្ទុះទៅឱបមាតា ខ្ទិតអត់លែង ស្រែកហៅមាតា :



-ម៉ែ !

-*សេសាគី !*

អ្នកទាំងពីរឱបក្រសោបគ្នា អរជាមួយគ្នា ក្ដាប់ដៃដែលឡើងត្រជាក់ស្រេបរបស់គ្នាទៅវិញទៅមក ដើម្បីឱ្យកំដៅឆ្លងគ្នា ហើយប្រញាប់ប្រញាប់ដើរត្រឡប់ទៅផ្ទះ ។

នៅឯផ្ទះឯនោះ ជីដូន និងបងស្រី គឺនាង *អ៊ីនុ* ដាំទឹកក្ដៅទុកងូត និងបាយទុកចាំជាស្រេច ។ ពេលនោះ សេសាគី មានប្អូនប្រុសម្នាក់ហើយ ។ អាង៉ាក៏រង់ចាំផ្លូវម្ដាយនឹងគេ នឹងឯងដែរ ។

-ម៉ែហត់ខ្លាំងហើយ ម៉ែចូលងូតទឹកក្ដៅឱ្យស្រួលខ្លួន ឱ្យបាត់ហត់សិនទៅ ។

-អរគុណកូន ។ ចាំម៉ែយករបស់នេះទៅអោយហាង *ម៉ាត ស៊ីម៉ាយ៉ា* សិន ។

-ខ្ញុំយកទៅជំនួស ម៉ែងូតទឹកទៅ ។

-កុំអីកូន ។ម៉ែឯ(អែ)នេះទទឹកស្រាប់ ។ ចាំម៉ែតែមួយភ្លែតទេ ម៉ែមកវិញឥឡូវហើយ ។

ថាហើយ     អ្នកម្ដាយក៏ដើរបង្អួសផ្ទះបន្ដទៅមុខទៀត គ្មានបានដាក់តួចសំរាកមួយដង្ហើមឡើយ ។

គ្រួសារ សេសាគី ក្រណាស់ គ្មានកន្ទេលតាតាមីក្រាស់ក្រាលពីលើរនាបទេ។ បើមាន គឺមានតែកន្ទេលកក់ ពីរបីបន្ទះតែប៉ុណ្ណោះ។  ខ្យល់ត្រជាក់បក់ចូលមកតាមប្រឡោះរនាប និងជញ្ជាំងរូ១។ ចង្កៀងប្រេងកាតតូចមួយបញ្ចេញពន្លឺផ្លុង១ រកកលនឹងរលត់ម្ដង១។ គ្រួសារនេះគ្មានលុយសំរាប់ទិញប្រេងកាតប្រើឱ្យបានគ្រប់គ្រាន់ទេ។ ប៉ុន្ដែទឹកចិត្ដដ៏កក់ក្ដៅរបស់មាតា បានធ្វើឱ្យ(អោយ) គ្រួសារនេះរីករាយជានិច្ចជាកាល ។



# ក្មេងក្រងង់

-*សេសាគី* គឺជាក្មេងក្រងង់ ! ក្មេងក្រងង់ គឺ *សេសា*

-ហ្អេ កូននេះក្រងង់ ! ហ្អេ *សេសាគី* ក្រងង់ !

ក្រងង់ គឺបានន័យថាដៃមិនត្រង់ដូចគេដូចឯ

*សេសាគី* នាំគ្នាចំអកឡកលេង ឱ្យ *សេសាគី* ដែល

នៅថ្ងៃមួយ ពេលចេញពីសាលា...



-នែវើយអាដែង យើងនាំគ្នា ប្រើដៃឆ្វេងគ្រវែងដុំថ្មចូលស្រែ ចាំមើល អាណាចោលបានឆ្ងាយជាងគេ ?

-អញមិនចោលទេ។

ឱ្យគ្រវែងដុំថ្មចូលស្រែគេយ៉ាងម៉េចនឹង កើត?

-ហូ ! និយាយមើលតែឯងហ្នឹងគ្រាន់បើណាស់ ។ មើល៍ សុំមើលដៃឆ្វេងលោកអ្នកគ្រាន់បើបន្តិចមើល៍ ក្រែងក្រេងង់ទេហ្អី ។ អេ ! *សេសោគី* ក្រេងង់ !

មានពេលខ្លះពួកគូកនរបស់ *សេសាគី* បង្ខំគេឱ្យកាន់របស់ធ្ងន់ៗ ជួនកាលទៀតឱ្យធ្វើដៃគួចំបាប់ជាមួយខ្លួន ។ *សេសាគី* មិនចូលចិត្តឱ្យគេឃើញដៃឆ្វេងដ៏មិនជាបើរបស់ខ្លួនទេ ។ គេតែងតែលាក់វានៅក្រោយសំពៀត ឬក៏នៅក្នុងដៃអាវជានិច្ចជាកាល ។

ប៉ុន្តែ នៅពេលខ្លះ គេទ្រាំមិនបាន ក៏ហាក់ទៅសង្គ្រប់



ដៃគូខ្លួនក៏មាន។ ប៉ុន្តែដោយ *សេសាគី* មានមាឌតូច កំឡាំងក៏ខ្សោយ គេមិនដែលវាយឈ្នះគូកនរបស់គេម្តងបានទេ។ ម្ល៉ោះហើយ *សេសាគី* តែងតែឈរឯកោ ស្តាប់សម្លេងចំអកឡកឡឺយរបស់គូកនទាំងឡាយទាំងក្តៅក្រហាយក្នុងចិត្តជាញឹកញយ។

-*សេសាគី* ក្រងេង ក្រងង់ ក្រងុក ង៉ុក ! *សេសាគី* ក្រងុក !

*សេសាគី* ខាំមាត់សង្កៀតធ្មេញក្រឹតៗខំទប់ចិត្ត។ ប៉ុន្តែទប់មិនជាប់កំហឹងក៏បានផ្ទុះ :

-អើ ! ប្រសិនបើដៃអញជាស្រួលបួលដូចគេដូចឯងវិញ ចាំមើល អញធ្វើឱ្យដឹងដៃវិញម្តង។

ថាហើយ គេក៏ដើរទៅរកកន្លែងស្ងាត់ ហើយស្រែកយំអស់មួយទំហឹងតែឯកឯង។

រឿងបែបនេះ មិនមែនកើតមានតែម្តងឬពីរដងទេ។ ដល់តែគេចំអកឡកឡឺយឱ្យញឹកញាប់ពេកទៅ ទោះជា *សេ*

*សាគី* ជាក្មេងចូលចិត្តរៀនបែបម៉េច ក៏គង់ធុញទ្រាន់លែង ចង់ទៅសាលារៀនដែរ ។

-យាយ ! ម៉ែ ខ្ញុំលាទៅសាលាហើយ ។

*សេសាគី* គំនាប់លាជីដូននិងមាតា ថាទៅសាលារៀន ដោយសំឡេងស្វាហាប់ ប៉ុន្តែជើងរបស់គេមិនបោះជំហាន សំដៅទៅសាលាតាមបញ្ជារបស់ខួរក្បាលគេទេ វាបែរជាធ្វើ ដំណើរសំដៅទៅឯព្រៃស្ងាត់ឯនោះទៅវិញ ។ នៅពេលដែល ចូលទៅដល់ក្នុងព្រៃ ចាកផុតពីស្រមោលមនុស្សម្នាទៅ *សេសាគី* គ្រវែងសំពៀតចោល ហើយអង្គុយសំកុកច្រត់ចង្កាដូច ជាមនុស្សមានទុក្ខ ។



សំឡេងរគាំងរ៉ៃម៉ឺង១ បញ្ជាក់ថាដល់ពេលចូលរៀនហើយ ហើយសំឡេងនោះបានឮ(លឺ)សូរមកដល់កន្លែងដែល *សេសាគី* អង្គុយ។ វេលានោះ មុខរបស់គ្រូនិងរបស់គូកនទាំងឡាយបានលេចឡើងជាបន្តបន្ទាប់ពីមុខគេ។ រួចហើយគេក៏តាំងចាប់គិតថា តើគូកនទាំងឡាយកំពុងតែរៀនវិជ្ជាអ្វី? នៅពេលដែលគូកនកំពុងតែនាំគ្នាអង្គុយរៀន ខ្លួនឯងម្នាក់អង្គុយលេង។ ពេលនោះហើយ ដែលមុខនិង ពាក្យរបស់មាតា ដែលតែងតែដាស់តឿនប្រដៅឱ្យខិតខំរៀន លេចធ្លោចេញមក ។ *សេសាគី* ទ្រាំលែងបាន ក៏ស្ទុះរករត់ដេញតាមចាប់មេអំបៅ បាក់ដូចជាចង់បណ្តេញអារម្មណ៍ហួរហួងទាំងឡាយឱ្យចេញផុតអស់ពីខួរក្បាល។

លុះតែនឹកឃើញថាដៃឆ្វេងខ្លួនពិការ ក៏អស់កំឡាំងកំហែងស្លុកហើយអង្គុយចុះទៅវិញទៅ។

ការឈប់សំរាកដោយគ្មានជម្ងឺ ឬធុរៈបែបនេះ នាំឱ្យគិតថា ពេលវេលាកន្លងទៅយឺតអស្ចារ្យណាស់។ ពិបាក

នឹងទ្រាំណាស់ ។ គេមើលថ្ងៃ គិតថា តើល្មមដល់ពេលត្រូវត្រឡប់ទៅវិញឬក៏នៅទេ រួចហើយក៏បោសគូថខោដើរត្រឡប់ទៅផ្ទះត្រុកៗវិញ ។

ដើម្បីកុំឱ្យអ្នកផ្ទះសង្ស័យ គេបានយកទឹកខ្មៅមកប៉ាតសំលៀកបំពាក់មុខមាត់ឱ្យប្រឡាក់ប្រតេកប្រតាកពាសពេញធ្វើហាក់ដូចជាខ្លួនឯងហ្នឹង បានខិតខំរៀនស្វិតស្វាញមុតមាំណាស់ ។

ប៉ុន្តែការសំងាត់នេះលាក់មិនជិតទេ ។ មិនយូរប៉ុន្មានរឿងនេះក៏បែកការណ៍ ដឹងឮដល់ម្តាយ ។

-*សេសាគី !*

ម្តាយធ្វើមុខមាំ ខុសពីម្តាយដែលគេធ្លាប់ឃើញជារៀងរាល់ថ្ងៃ ។

-មកនេះភ្លាម ! ឯងមានរឿងអ្វីលាក់នឹងម៉ែមែនទេ ? និយាយ ឱ្យត្រង់ភ្លាមមក !

*សេសាគី* ក៏ក្រាំក្រាចិត្ត មិនចាញ់ម្តាយដែរ ។ គេបាននិយាយរឿងហេតុតាំងពីដើមដល់ចប់ ជំរាបមាតាអស់ ។ អ្នកម្តាយយល់ពីចិត្តដ៏វេទនារបស់ *សេសាគី* ណាស់ ។ ទេមិនត្រឹមតែយល់ទេ គាត់ថែមទាំងផ្តន្ទាទោសកំហុសខ្លួនគាត់ដែលធ្វេសប្រហែស ធ្វើឱ្យកូនរលាកទឹកក្តៅ ។

-*សេសាគី* កូនម្តាយ ។ អត់ទោសឱ្យម្តាយផង ។ ប៉ុន្តែ បើកូនចុះចាញ់ ហើយលះបង់ការរៀនសូត្រត្រឹមនេះ តើអនាគតកូនឯងនឹងទៅជាយ៉ាងណា? ម៉ែខំទ្រាំលំបាកមកដល់នេះ ក៏ព្រោះតែសង្ឃឹមថាកូននឹងបានខ្ពស់ដោយសារតិរះវិជ្ជា បើកូនឈប់រៀនទៅ សេចក្តីសង្ឃឹមទាំងឡាយនឹងរលាយរលត់អស់ ។ ខំប្រឹងមើលបន្តិចទៀតមើល កើតទេកូន?

-ម៉ែ ! អត់ទោសឱ្យកូនផងម៉ែ ! កូនខុសហើយ ។ កូនលែងឈប់ទៀតហើយ ។ ជាដាច់ខាត ។

ម្តាយនិងកូនក៏ឱបរឹតគ្នាយំខ្សឹកខ្សួល ។ តាំងពីពេលនោះមក *សេសាគី* បានខិតខំរៀនមួយទ្វេជាពីរ ។ ពីថ្នាក់ទី១ ទៅ

ដល់ថ្នាក់ទី៣ គេរៀនមិនបានលេខ១ទេ ប៉ុន្តែចាប់ពីថ្នាក់ទី ៤ ទៅ *សេសាគី* រៀនបានលេខ១ យ៉ាងត្រចះត្រចង់។

ឯក្នុងចំណោមគូកនទាំងឡាយ ក៏មិនមែនមានសុទ្ធតែក្មេងកំណាចទាំងអស់ដែរទេ។ គូកនខ្លះក៏មានចិត្តល្អដែរ។ *សេសាគី* មានគូកនដែលមានចិត្តធំមិនអស់ពីចិត្តខ្លះដែរ។ នៅក្នុងនោះ មានក្មេងម្នាក់ឈ្មោះ *ដៃគីជី*។

ម្តាយឪពុក *ដៃគីជី* ជាម្ចាស់ផ្ទះសំណាក់ ម៉ាតស៊ីម៉ាយ៉ា។ នៅពេលដែល *សេសាគី* គ្មានលុយទិញខ្មៅដៃ ឬ សៀវភៅសរសេរ ម្ចាស់ផ្ទះសំណាក់តែងតែទិញឱ្យគេជានិច្ច។ ថ្ងៃនេះក៏ *សេសាគី* ចេញទៅលេងជាមួយនឹង *ដៃគីជី* ដែរ។

គេនាំគ្នាទៅចាំរហាត់ទឹករបស់គ្រួសារ *ដៃគីជី*។ នៅពេលដែលរហាត់ទឹកវិលយឺតៗ ឮសូរង៉ឺតង៉តៗ ក្មេងទាំងពីរនាំគ្នាអានសៀវភៅរូបភាពមួយជាមួយគ្នាទាំងពីរនាក់។ គេកំពុងតែអានសៀវភៅរឿងប្រវត្តិសាស្ត្រត្រង់វគ្គដែលលោក *ខុអិ*

*ស៊ីឌី គេងស៊ីន* កំពុងតែច្បាំងជាមួយ *តាគេដា ស៊ីនងេន* នៅកោះ *កាវ៉ាណាកា ស៊ីម៉ា*។

-*សេសាគី* ទាយមើល ថាតើអ្នកណាខ្លាំងជាង ?

-ខ្ញាថាខ្លាំងស្មើគ្នា ។

-កុំថាអញ្ចឹង ។ ទាយមើលថាអ្នកណាខ្លាំងជាង ?

-ខ្ញាមិនមែនគ្រូទាយទេវើយ ។

-អញ្ចឹង ខ្ញាសួរអញ្ចេះវិញ។ *សេសាគី* ស្រឡាញ់អ្នកណាជាង ក្នុងចំណោមអ្នកទាំងពីរនាក់ហ្នឹង ?

-ឱ្យទៅស្រឡាញ់អ្នកណាជាង *ស៊ីនងេន* នោះ ?

-ម៉េចអញ្ចឹង ?

-ពីព្រោះគាត់ជាមនុស្សមានប្រាជ្ញា ។

-មក *សេសាគី* យើងភ្នាល់គ្នា ដោយចាប់ចំបាប់មើល ថាតើ *គេងស៊ីន និង ស៊ីនងេន* អ្នកណាគេខ្លាំងជាង ?

ចំពោះ *សេសាតី* ជាញឹកញយណាស់ ដែលពួកគូកនខូចៗ តែងតែមកនាំគេលេងបោកចំបាប់ ។ លុះដល់មកត្រូវ ដៃគីជី នាំលេងបែបនេះ *សេសាតី* ក៏ឆេះប្រាវតែម្តង ។

-មក ! ចូលមក អាកូន !

*សេសាតី* ងើបក្រេះឈរយ៉ាងសឿងបឿង រៀបចំតទល់ជាមួយនឹង ដៃគីជី ។ ប៉ុន្តែ ឱ្យទៅឈ្នះ *ដៃគីជី* ឯណាកើត ។

នៅពេលដែល *សេសាតី* ហៀបនឹងចាញ់ទៅហើយ *ដៃគីជី* ក៏ស្រាប់តែស្រែកថា :

-អូយម៉ែអើយ រសើបណាស់ ។



ពេលនោះដើងគេទាំងពីរនាក់ ក៏ព័ទ្ធគ្នា *សេសាគី* ឈ្នះ។ ពោលគឺថា បើ *ដៃគីជី* លេងខូចឯណោះក៏លេងខិលសងទៅវិញឱ្យឃើញជាក់ស្ដែងដែរ។ *សេសាគី* យកដៃដែលពិការខាងឆ្វេង ចាក់ក្រឡេក *ដៃគីជី* ទាល់តែ *ដៃគីជី* ស្រែក ថា រសើប។

-នេះគឺជាស្នៀតរបស់ *ស៊ីនសេន*។

-*សេសាគី* ខូចណាស់។

-មិនខូចម៉េចនឹងកើត បើឯងដឹងថាដៃឆ្វេងគ្នាខូចហើយ ឯងហៅគ្នាឱ្យចាប់ចំបាប់ជាមួយឯងហ្នឹង។

-ឱសុំទោស សុំទោស *សេសាគី* គ្នារវល់តែស្លុងទៅតាមសាច់រឿង ភ្លេចគិតរឿងដៃឯងនេះ។

គេទាំងពីរនាក់និយាយគ្នាយ៉ាងសប្បាយ។ លុះដល់យប់ ក៏នាំគ្នារៀនក្រោមពន្លឺចង្កៀង។ គ្រួសារ *សេសាគី* មិនមានលុយទិញប្រេងកាតឱ្យបានគ្រប់គ្រាន់ទេ។ ដូច្នេះ *សេសាគី* តែងតែរៀននឹងភ្លើងចង្ក្រាន ប៉ុន្តែរៀនមិនដែលបានពេញលេញ

ឡើយ ។ ឥឡូវគេបានសុំរៀនជាមួយនឹង *ដែគីជី* រាល់យប់ នៅបន្ទប់ *ដែគីជី* ដែលមានទំហំ ៦តាតាមី ( កន្ទេល) ។ គេពីរនាក់រៀនជាមួយគ្នា ឥតដែលមានឈ្លោះប្រកែកគ្នាមួយអ៊ីសឡើយ ។

នៅពេលនោះ គេរៀននៅសាលាបឋមសិក្សានៅឡើយ ប៉ុន្តែ អ្នកទាំងពីរបានខិតខំរៀនភាសាអង់គ្លេសពីព្រះសង្ឃ ព្រមទាំងរៀនអានអក្សរសីល្បិ៍ ចិនពីប៉ូលីសម្នាក់ ដែលនៅភូមិជាមួយគ្នា ។

*ដែគីជី* រៀនលើស *សេសាគី* មួយថ្នាក់ ក៏ប៉ុន្តែ អ្នកដែលស្គាល់គេទាំងពីរនិយាយថា *ដែគីជី* រៀនមិនដែលឈ្នះ *សេសាគី* ទេ ។

*ដែគីជី* រហ័សងងុយដេកណាស់ ។ នៅពេលដែលគេងងុយហើយ *ដែគីជី* ចូលដំណេកភ្លាម ។ ឯ សេសាគី វិញ នៅពេលដែលងងុយ ក៏រត់សំដៅទៅអណ្ដូង ដងទឹកត្រជាក់លុបមុខឱ្យស្វាងងងុយ ។ រួចហើយក៏ចាប់រៀនបន្តទៅទៀត ។ ពេល

*ដេគីជី* ដឹងខ្លួន ហើយនៅតែឃើញ *សេសាគី* រៀន ក៏ស្តីឱ្យថា :

-មក៏ លួមដេកពួនហើយ ! ប្រយ័ត្នឈឺ !

-វាមិនដែលកើតអីទេ។ ខ្លួនមើលស្តេច *ណាប៉ូឡេអុង* មើល៍ គាត់សំរាន្តតែបីម៉ោងទេតើ ម៉េចក៏មិនឃើញអី?

ចាប់តាំងពីពេលនោះហើយដែល *សេសាគី* ទទួលទានដំណេកតិចតួច។ ដល់ពេលក្រោយមកទៀត ពួកអាមេរិកដែលគេឃើញ *សេសាគី* ខំរៀន គេក៏សួរជប៉ុនទាំងភ្ញាក់ផ្អើលថា : "ជប៉ុនដេកថ្មើម៉ានឃ្មុំ?"

*សេសាគី* ចូលដំណេកនៅពេលដែលភ្ញៀវ ដែលមកសំណាក់នៅផ្ទះសំណាក់ក្រោក ហើយចេញដំណើរនៅ ពេលព្រលឹមស្រាងៗ ហើយនិយាយគ្នា រអ៊ុះ រអ៊ុះ។



# លោកគ្រូតូច

-ម៉ែ ខ្ញុំមកពីសាលារៀនវិញហើយ ។

-អើ ម៉េចដែរកូន សាលារៀនសប្បាយទេ?

-បាទ ! ម៉ែហ្នា ឥឡូវលោកគ្រូឱ្យខ្ញុំធ្វើសេដោ ។

-ស្អីគេទៅកូន *សេដោ* ហ្នុង?

"សេដោ" គឺអ្នកដែលរៀនពូកែខ្លាំង ទោះបីជាទើបតែរៀនដល់ថ្នាក់ទី៤ក៏ដោយ ក៏អាចបង្រៀនសិស្សតូចៗជំនួសគ្រូបានដែរ ។ ពោលគឺ "លោកគ្រូតូច" ។

សេចក្ដីខិតខំទ្រាំទ្រការលំបាករបស់ម្ដាយកូន បានទទួលផ្លែផ្កាបន្តិចម្ដងៗហើយ ។ អ្នកម្ដាយភ្លេចអស់នូវកង្វល់ទាំងឡាយ ដែលមានរហូតមកដល់ថ្ងៃនេះ ។

-ធ្វើលោកគ្រូ បើស្លៀកពាក់បែបនេះ មិនសមរម្យសោះ។

មែនហើយ សំលៀកបំពាក់របស់ *សេសាគី* ទិញយូរឆ្នាំមកហើយ។ មានបំណះត្រង់នេះបន្តិចត្រង់នោះបន្តិច ហើយចាស់រិចរីលណាស់។ អ្នកម្តាយខំប្រមែប្រមូលប្រាក់ទិញសំលៀកបំពាក់ថ្មីឱ្យកូនមួយបន្លះ។ ប៉ុន្តែ នៅក្នុងភូមិមានមនុស្សខ្លះមិនសប្បាយចិត្តទេ។

-ស្អី ? ឱ្យអាអ្នកក្ររហាមបែបនេះ បង្រៀនសិស្ស ?

-អាមនុស្សដើរតែខ្ចីលុយគេចាយហ្នឹង ?



ដល់ថ្ងៃដែល *សេសាគី* ទៅបង្រៀនសិស្សហើយ ។ ប៉ុន្តែ ឯណាទៅឈើកំណល់តុគ្រូ ម៉េចក៏មិនឃើញ ?

-រើយអាដែង *សេសាគី* ក្រងង់ឡើងធ្វើលោកគ្រូតូចផង ។

-ងាប់ហើយ ឱ្យមនុស្សក្រងង់បង្រៀនអញ្ចឹង ចេះអីទៅ ?

-តស់ ! ធ្វើឱ្យវាសមមុខម្តង ។ កុំឱ្យវាជោរទៀត ។

-អើ ត្រូវ ! តស់ កនយើង នាំគ្នាសែងកំណល់តុយកទៅចោលឯវត្ត ។ អាល្បងនោះទាបកញ្ជ្រឹកៗអញ្ចឹង មិនលែងឡើយនឹងយ៉ាប់យ៉ឺនទេ ។ វាមិនអាចសរសេរលើក្តារខៀនកើតទេ ចាំតែសើចទៅកនយើង ។



-ចាំតែមើល សប្បាយអស់ទាស់ហើយ ។

ពួកក្មេងកំហិលទាំងឡាយនាំគ្នាសែងកំណាល់តុ ហ្មេហ្មឹប ៗ យកទៅចោលឯណាបាត់ ។

ប៉ុន្តែ *សេសាគី* បានបង្រៀនដោយមិនមានរអាក់រអួល ទាល់តែចប់ចុងចប់ដើម ។ ថ្ងៃបន្ទាប់ក៏បែបនោះដែរ ។ សិស្ស កំហិលទាំងឡាយ នាំគ្នា សែងកំណាល់តុ ចេញទៅ ក្រៅ ពពាក់ពពូនទៀត ហើយ ។

នៅពេលដែលពួកគេបំរុងនឹងដាក់កំណាល់ តុទៅលើផ្ទៃដី នៅក្នុងបរិវេណវត្ត ស្ត្រីម្នាក់លេចមុខចេញពីក្រោយដើម ឈើមកហើយសម្លក់ពួកគេថ្ងៃ ។ គឺមាតារបស់ *សេសាគី* អ្នក *ស៊ីកា*។

-មីងមិនដឹងថាពួកឯងមានបំណងធ្វើអ្វីទេ ។ មើលឱ្យមីងសុំ អង្វរទៅចុះ ។ ចូរពួកឯងយកកំណាល់នេះទៅទុកកន្លែងដើម វិញភ្លាម !

ដល់តែពួអ្នក *ស៊ីកា* និយាយដាច់ណាត់បែបនេះ ពួក ក្មេងខូចទាំងឡាយទាល់ច្រក ក៏នាំគ្នាលីសែងកំណល់តុដ៏ធ្ងន់ ត្រឡប់ក្រោយបែរ ទៅសាលារៀនវិញទៅ ។

លុះដល់ក្រោយមក ក្មេងទាំងអស់បានស្គាល់ពីកិរិតប្រាជ្ញា របស់ *សេសាគី* ហើយក៏រៀនជាមួយនឹង *សេសាគី* ដោយ រីករាយ ។

ពេលរៀនចប់ថ្នាក់ទី៤ហើយ *សេសាគី* បានរៀនបន្តទៅ មុខទៀត ។

ពេលបញ្ចប់ការសិក្សានៅបឋមសិក្សាបានចូលមកហើយ ។ គេតោងតែប្រឡងចេញពីសាលា ។ គ្រូប្រចាំថ្នាក់របស់សិស្ស មិនអាចត្រួតពិនិត្យការប្រឡងបានទេ ។ គ្រូក្នុងសាលាជា មួយគ្នាក៏មិនអាចដែរ ។ មានគ្រូពីសាលាក្រៅ មកធ្វើជា មេប្រយោគនិងជាអ្នកចោទសំនួរ ហៅសិស្សមកសួរម្នាក់ ម្តង១ ។ គ្រូប្រចាំថ្នាក់ម្នាក់១ព្រួយបារម្ភណាស់ ។ ឯសិស្ស រាល់គ្នាក៏បារម្ភ ភ័យបុកពោះភឹប១ រង់ចាំវេនរបស់ខ្លួនដែរ ។

-*ណួងជី សេសាគី*!

-បាទ !

លោកគ្រូដែលធ្វើមេប្រយោគការប្រឡង ឈ្មោះលោកគ្រូ *កុបាយ៉ាស៊ី*។ លោកគ្រូ *កុបាយ៉ាស៊ី* ជាគ្រូដែលបង្រៀននៅសាលាបឋមសិក្សាជាន់ខ្ពស់នៅភូមិជាប់នោះ។ ដោយ *សេសាគី* ឆ្លើយបានត្រឹមត្រូវ ហើយមានប្រាជ្ញាវៀងវៃអស្ចារ្យ លោកគ្រូមានការភ្ញាក់ផ្អើលជាខ្លាំង។

លោកគ្រូបានចាប់អារម្មណ៍ពីដៃឆ្វេងរបស់ *សេសាគី* ដែលគេលាក់ទៅខាងក្រោយខ្នង។ លោកគ្រូបានសួរនាំពីគ្រួសាររបស់ *សេសាគី*។ សួរប៉ុណ្ណេះ ក៏ហាក់ដូចជាមិនទាន់គ្រប់គ្រាន់ លោកក៏បានហៅ *សេសាគី* ឱ្យមកបន្ទប់លោកពិសេសតែឯង ហើយសាកសួរថែមទៀត។

-*ណួងជី* ដៃចៅឯងកើតអី?

-បាទលោកគ្រូ ខ្ញុំបាទរលាកទឹកក្ដៅកាលពីខ្ញុំបាទមានអាយុ ២ឆ្នាំ។



-ឱអញ្ចឹង? ឯងមិនដឹងជាត្រូវទុរន់ទុរាចិត្តយ៉ាងណាទេ ហ្ន៎ រហូតមកដល់ពេលនេះ? ដល់ចេញពីសាលាទៅ ឯងគិតធ្វើអី ?

-បាទលោកគ្រូ ម្ដាយខ្ញុំបាទមានបំណងឱ្យខ្ញុំបាទរៀនបន្តទៅមុខ ប៉ុន្តែគ្រួសារខ្ញុំបាទក្រខ្សត់ណាស់ ខ្ញុំបាទមិនអាចរៀនបន្តទៅមុខបានទេ។

-ប៉ុន្តែឯងចង់រៀនតទៅទៀតមែនទេ ?

-បាទលោកគ្រូ បើអាចធ្វើទៅបាន ខ្ញុំបាទចង់រៀនបន្តទៅសាលាបឋមសិក្សាជាន់ខ្ពស់ទៀតណាស់។

-អើគ្រូយល់ហើយ។ គ្រូចង់ដឹងឱ្យកាន់តែច្បាស់បន្តិចទៀត។ តើឯងអាចមករកគ្រូឯផ្ទះបានទេ?

-បាទលោកគ្រូ។ ខ្ញុំបាទសូមអរគុណលោកគ្រូ។

-នេះគ្រូគូរប្លង់(ផែនទី)ឱ្យ។ ចូរឯងមកតាមផ្លូវនេះជាមួយម្ដាយឯងមក នឹងឃើញផ្ទះគ្រូហើយ ស្រួលរកទេ។

-បាទលោកគ្រូ។ ខ្ញុំបាទសូមជំរាបលាលោកគ្រូ។

*សេសាគី* គិតថា អនាគតរបស់គេកំពុងតែភ្លឺចិញ្ចាចទៅមុខហើយ ហើយគេរីករាយក្នុងចិត្តឥតឧបមា។



# លោកគ្រូកុបាយ៉ាស៊ី



ផ្ទះលោកគ្រូ កុបាយ៉ាស៊ី

ថ្ងៃដែល *សេសាគី* និងមាតា ត្រូវទៅផ្ទះលោកគ្រូ *កុបាយ៉ាស៊ី* បានចូលមកហើយ ។ ផ្ទះរបស់លោកគ្រូ *កុបាយ៉ាស៊ី* នៅឃ្លាតឆ្ងាយពីភូមិដែល *សេសាគី* រស់នៅ ៦គីឡូ ។ ភូមិនោះឈ្មោះ *អ៊ីណាវ៉ាស៊ីរ៉ូ*។ មាតា *សេសាគី* ខ្ចប់កូនត្រីដែលខ្លួនបានចាប់នឹងស្លឹកឈើយកទៅជាមួយ ជាទ្រនាប់ដៃ ជាបញ្ញើចំពោះលោកគ្រូ *កុបាយ៉ាស៊ី* ។

-លោកគ្រូ នាងខ្ញុំមានរបស់ប៉ុននេះយកមកជូន មិនដឹងជាលោកគ្រូចូលចិត្តឬក៏មិនចូលចិត្តទេ។

ថាហើយ អ្នកក៏លបយកត្រីនោះទៅដាក់ឯចង្ក្រានបាយរបស់លោកគ្រូ។ គេបាននាំអ្នកទាំងពីរឱ្យចូលទៅក្នុង។

អ្នកជាមាតា បានជំរាបលោកគ្រូពីអ្វីៗ ដែលកើតមានឡើងរហូតមកដល់ថ្ងៃនេះ ព្រមទាំងពីឪពុកដែលផឹកស្រាស្រវឹងជានិច្ចជាកាលនាំឱ្យគ្រួសារលំបាក ឥតមានលាក់លៀមកន្លែងណាឡើយ។ បន្ទាប់មក អ្នកជាមាតាបានរៀបរាប់ពីបំណងដែលចង់ឱ្យ *សេសាគី* រៀនឱ្យបានវែងឆ្ងាយតទៅមុខ ទោះជាមានឧបសគ្គអ្វីក៏ដោយ ក៏នឹងខំពុះពារមិនថយទៅក្រោយឡើយ។

នៅពេលដែលបានស្តាប់មាតា *សេសាគី* រៀបរាប់ហើយ លោកគ្រូ *កុបាយ៉ាស៊ី* និងភរិយា អាណិតឡើងស្រក់ទឹកភ្នែកទាំងពីរនាក់ប្តីប្រពន្ធលោក។ លោកគ្រូមានប្រសាសន៍ថា :

-យើងទាំងពីរនាក់មិនមែនជាអ្នកមានទេ តែយើងនឹងខំឱ្យ

អស់ពីសមត្ថភាពរបស់យើងជួយអ្នកទាំងពីរ ។ ខ្ញុំនឹងចំណាយលុយសំរាប់ការសិក្សារបស់កូ្នយ *សេសាគី* ។

មាតា និងកូន វេលាឮប្រសាសន៍បែបនេះរបស់លោកគ្រូ ក៏ត្រេកអរឥតឧបមា មិនដឹងជាត្រូវថ្លែងអំណរគុណបែបណា ឱ្យសមនឹងចិត្តដ៏ល្អប្រពៃរបស់លោកគ្រូ *កុបាយ៉ាស៊ី* និងភរិយានេះទេ ។ បេះដូងរបស់អ្នកទាំងពីរដែលងងឹតស្លុប ហាក់ដូច




នៅមុំផ្ទះកំណើតរបស់ហ៊ីដេយោ

ជាត្រូវបានបំភ្លឺដោយពន្លឺដ៏ត្រចះត្រចង់ ។

នៅពេលដើរតាមផ្លូវ ត្រឡប់មកផ្ទះវិញ ម្ដាយបានពន្យល់កូនថា :

-*សេសាគី* កូនតោងតែចងចាំឧបការគុណនេះមួយជីវិត ណាំកូនណាំ ។ ហើយតោងតែខិតខំរៀនដើម្បីតបស្នងទឹកចិត្តដ៏ល្អរបស់លោកគ្រូ ។ ម៉ែក៏អញ្ចឹងដែរ ម៉ែនឹងខិតខំធ្វើការមួយជាពីរ តទៅទៀត ។



ដោយឧបការគុណនេះ *សេសាគី* ក៏បានចូលទៅរៀននៅសាលាមធ្យមសិក្សា*អ៊ិណាវ៉ាស៊ិរ៉ូ* នៅខែមេសា ឆ្នាំ១៨៨៩ ពោលគឺ នៅឆ្នាំទី២២ នៃជំនាន់*មេ៉ជី*។ វេលានោះ *សេសាគី*



មានអាយុ១៣ឆ្នាំ។ បេះដូង និងខួរក្បាលរបស់ *សេសាគី* ពេញព្រៀបទៅដោយសេចក្តីសប្បាយនឹងបានចូលរៀន។ ចំពោះការដើរទៅរៀន ទៅមក១២គីឡូ ក៏គេគ្មានថ្ងូរមួយអ៊ឺះ។ ទោះជាបែបនេះក៏ដោយ ក៏នៅពេលដែលព្រិលធ្លាក់ *សេសាគី* មានការលំបាកខ្លាំងណាស់។ ព្រិលផាត់មកជាមួយនឹងខ្យល់ដ៏ត្រជាក់។ នៅពេលដែលព្រិលធ្លាក់ខ្លាំងមែនទែន គេតោងតែដើរកាត់ព្រិល ដែលធ្លាក់ក្រាលត្រួតៗពីលើគ្នា

កំរាស់សឹងតែកប់ហួសចង្កេះ ។ ទោះជាយ៉ាងនេះក្តីក៏ *សេសាគី* មិនដែលឈប់សំរាកមួយថ្ងៃ ឬក៏ទៅឃីតម៉ោងដែរ ។

ការសិក្សាសប្បាយអស្ចារ្យចំពោះ *សេសាគី*។ វេលាយប់ *សេសាគី* ទៅផ្ទះ *ដៃគិជី*។ ពេលចូលងូតទឹកក្តី ពេលដុសក្អែលខ្នងឱ្យ *ដៃគិជី* ក្តី ក៏នឹកតែពីពាក្យអង់គ្លេសដែលបានរៀននៅសាលា ហើយគ្មានបានគិតថាខ្លួនកំពុងតែដុសខ្នងមនុស្សទេ លុះតែ *ដៃគិជី* ស្រែក :

-អូយ *សេសាគី* ឈឺណាស់ ។

-វាម៉េច *ដៃគិជី*?

-វាម៉េចអី ! ក្តាឈឺ ។ ល្បងឯងយកស្អីកោសខ្នងគ្នាអំបាញមិុញហ្នឹង?

-ហ្ន៎ !

នៅក្នុងដៃស្តាំរបស់ *សេសាគី* គេឃើញមានដុំពពុះថ្មសំរាប់ដុសស្បែកកែងជើងឱ្យទន់ ។ *សេសាគី* បានច្រឡំយក

ថ្ងៃនោះដុសខ្លួង *ដៃគិជី* ដោយស្មានតែសាប៊ូ។ បែប១នេះ មិនឱ្យ *ដៃគិជី* ឈឺសឹងតែលោតឯណាកើត។

*សេសាគី* ជក់នឹងរៀនមែន តែបេះដូងរបស់គេនៅតែខ្វាយខ្វល់អំពីដៃឆ្វេងរបស់គេជានិច្ច។ នៅសាលាធំលែងមានការចំអកឡកឡឺយ ពីសំណាក់មិត្ត១ដូចនៅសាលាបឋមសិក្សាទៀតហើយ ក៏ប៉ុន្តែ នៅពេលរៀនសរសេរអក្សរជក់ នៅពេលរៀនកីឡា នៅពេលទទួលទានបាយសំណុំ នៅពេលខូងខ្មៅដៃ *សេសាគី* មានការលំបាកណាស់។



ម្តាយតែងតែធ្វើបាយពំនូត ដាក់ឱ្យយកមកទទួលទាននៅសាលាដើម្បីកុំឱ្យមានកង្វល់អំពល់ដល់ដៃឆ្វេង។

ថ្ងៃមួយ *សេសាគី* បានប្រើដៃឆ្វេងនេះដើម្បីសរសេរតែងសេចក្តីមួយ ។

"...ដោយសារតែដៃក្រងង់នេះ តើអ្នកអាចស្មានបានទេថាតើខ្ញុំមានការលំបាកប៉ុនណា? នៅពេលដែលខ្ញុំសម្លឹងមើលដៃឆ្វេងខ្ញុំដែលឡើងដូចជាដុំពកមួយ ខ្ញុំតែងតែគិតថា នៅពេលដែលយើងមានដៃបែបនេះ ទោះជាយើងខំព្យាយាមដល់កំរិតណា ក៏យើងមិនអាចក្លាយទៅជាអ្នកធំបានដែរ ។ ហេតុដូច្នេះ ខ្ញុំក៏ទៅជាឈឺចាប់យ៉ាងខ្លាំង ។ ខ្ញុំតែងតែគិតពីម្តាយខ្ញុំ ដែលតែងតែកម្លាចិត្តខ្ញុំ ណែនាំខ្ញុំឱ្យខិតខំ ។ ខ្ញុំត្រូវតែខំឱ្យបានទៅជាអ្នកធំដើម្បីម្តាយរបស់ខ្ញុំដែរ ។"

នៅពេលដែលអានអត្ថបទតែងសេចក្តីរបស់ *សេសាគី* លោកគ្រូ *កុបាយ៉ាស៊ី* នៅមិនសុខមិនសាប់ទេ ។ លោកយកតែងសេចក្តីនោះទៅជូនលោកគ្រូចាងហ្វាងសាលា បន្ទាប់មក យកទៅជូនលោកគ្រូអ្នកគ្រូឯទៀតៗឱ្យអានដែរ ។ រួចហើយ លោកអានឱ្យសិស្សឯទៀតៗស្តាប់ ។

វេលាដែលបានស្ដាប់តែងសេចក្ដីរបស់ *សេសាគី* យោបល់ជាច្រើនបានលេចចេញមកជាបន្តបន្ទាប់ ។

-យើងគោងតែជួយ *សេសាគី* ។

-ត្រូវតែយកវាទៅឱ្យពេទ្យចំណានពិនិត្យទើបបាន ។

-នៅ*វ៉ាកាម៉ាតស៊ុ* មានគ្រូពេទ្យល្អដែលទើបនឹងមកពីសហរដ្ឋអាមេរិក ។

-តើបានលុយពីណា បើខ្លួនក៏ក្រដែរបែបនេះ?

-រកប្រមូលពីគេពីឯងបន្តិចម្នាក់ៗ ទោះតិចក្តីច្រើនក្តី ។

គ្រូ និងសិស្សទាំងឡាយ បានស្រុះដៃគ្នាអង្គាសលុយពីអ្នកនេះបន្តិច អ្នកនោះបន្តិច រហូតដល់បានប្រាក់១០យ៉េន ។ ប្រាក់១០យ៉េនជំនាន់នោះច្រើនសន្ធឹកសន្ធាប់ណាស់ មិនតិចដូចសព្វថ្ងៃទេ ។ បើគិតទៅស្មើនឹងប្រាក់ខែរបស់ចាងហ្វាងសាលាមួយខែ គឺប្រហែលជារាប់សិបម៉ឺនយ៉េនជំនាន់នេះ ។

*សេសាគី* ក្រីក្រមែនប៉ុន្តែគឺជាកុមារដែលមានសុភមង្គល

ណាស់។ បន្ទាប់ពីពេលនោះមកទៀតក្តី ក៏គេតែងតែជួប
ប្រទះនឹងគ្រូ ឬ មិត្តដែលចិត្តល្អជានិច្ច។ តើហេតុអ្វីបានជា
កុមារនេះមានសំណាងល្អបែបនេះ?

# លោកគ្រូពេទ្យវ៉ាតាណាបេ

-មើល៍ ខិតមកជិតលោកគ្រូពេទ្យបន្តិចទៀតមើល ។ លោកគ្រូពេទ្យសុំមើលដៃក្មួយឯងឱ្យច្បាស់បន្តិច ។ ឱ ! ដៃនេះរលាកសំបើមតែម្តងហើយនេះ ។

-លោកគ្រូពេទ្យ តើគេអាចព្យាបាលឱ្យជាបានឬមិនបាន ទានប្រោស?





រូបថតអនុស្សាវរីយ៍ សេសាគី នៅស្តាំ

លោកគ្រូពេទ្យ *វ៉ាតាណាបេ* បានចុច ហើយអង្អែលដៃរបស់*សេសាគី* រួចហើយក៏មាន ប្រសាសន៍ម៉ាត់ៗថា : -អាចព្យាបាលបាន។ មិនអីទេ លោកគ្រូនឹងព្យាបាលឱ្យក្មួយឯងអាចកាន់អ្វីៗនឹងដៃនេះឱ្យទាល់តែបាន។

ពីរបីថ្ងៃក្រោយមក ការវះកាត់បានប្រព្រឹត្តទៅ។ មិត្តម្នាក់របស់ *សេសាគី* ឈ្មោះ *អាគីយ៉ាម៉ា យោស៊ុយ៊ីជី* បានមកតាមជួយកំដរ និងលើកទឹកចិត្តគេ។ វេលាដែលបានឃើញការវះកាត់ មិត្តភក្តិឯនោះទៅជាឡើងស្លាំង ស៊ីងតែសន្លប់។ ឯ *សេសាគី* វិញអ្នកត្រេកអរដោយអាចទទួលការព្យាបាលជាងទទួលអារម្មណ៍ឈឺចុកចាប់។ សេចក្តីទុក្ខសោកដែលបានបៀមទុកនៅក្នុងទ្រូង អស់រយៈពេល ១០ឆ្នាំ មកហើយ នឹងត្រូវចៀរចេញបន្តិចម្តងៗជាបន្តបន្ទាប់។

ការវះកាត់បានប្រព្រឹត្តទៅដោយជោគជ័យ ។ *សេសាគី* ដេកព្យាបាលនៅមន្ទីរពេទ្យចំនួនប្រហែលជា១០ថ្ងៃ ។ នៅពេលចេញពីពេទ្យ មិត្តរួមថ្នាក់ឈ្មោះ *យ៉ាដោ យ៉ាស៊ីហេ* បានមកទទួលគេ ។

-ខ្ញុំបានជានេះ ដោយសារតែទឹកចិត្តសប្បុរសរបស់លោកគ្រូ អ្នកគ្រូ និងមិត្តទាំងអស់ ។ សូមអរគុណ ។

-ទេ ទេ កុំថាអញ្ចឹង ។ តែគ្នាក៏ជួយអរឯងដែរ *សេសាគី* ។

ក្មេងទាំងពីរបានទៅថតរូបអនុស្សាវរីយ៍មួយទុក ហើយត្រឡប់មកផ្ទះជាទីរឭកវិញ ។ បន្ទាប់ពីចេញពីពេទ្យមក *សេសាគី* តែងតែទៅពេទ្យដែលនៅ *វ៉ាកាម៉ាតស៊ុ* នោះជារៀងរាល់ថ្ងៃដើម្បីឱ្យគេប្តូរបង់ (ស្បៃ) រុំដៃឱ្យ ។ គេតោងតែដើរ២០គីឡូ តែគេមិនដែលថ្ងូរទេ ។ ដូចការសន្យារបស់លោកគ្រូពេទ្យមែន បីអាទិត្យបន្ទាប់មក មុខរបួសក៏សះ ។

-មើល ក្មួយ *ណូងូជី* កំរើកដៃឯង លមើលមើល៍ !

*សេសាគី* ភ័យបុកពោះភឹបៗ ខំតោងកៅអីជាប់។ គេមានអារម្មណ៍ហាក់ដូចជារសើបៗ។ គេអាចចាប់កាន់ស្ពីឡូ ឬចង្កឹះសំរាប់ចាប់ធ្យូង ដែលធ្វើពីលោហធាតុបានហើយ។

តើនេះជាដៃរបស់ខ្លួនមែន ឬមិនមែន។ គេទៅជាឆ្ងល់។

-ទៅ ! យកទៅបង្ហាញលោកគ្រូ អ្នកគ្រូ ម្ដាយ និងពួកម៉ាកឯងដែលតែងតែព្រួយពីឯង ឱ្យគេជួយអរផងទៅ។

*សេសាគី* រត់រូដូចគេហោះត្រឡប់ទៅផ្ទះវិញ។ អ្នកម្ដាយចាប់ដៃនោះមកដាក់លើថ្ពាល់លោក ហើយយំខ្សឹកខ្សួល។

-ម្ដាយអរណាស់។ ទាំងនេះសុទ្ធតែជាគុណបុណ្យរបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងមិត្តទាំងអស់ហើយ។ *សេសាគី* ចូរកូនចាំគុណូបការគុណនេះជានិច្ច កុំបីភ្លេចឱ្យសោះណា។



*សេសាគី* គន់មើលដៃរបស់ខ្លួនហើយគិតក្នុងចិត្តថា ៖
-ដៃនេះមិនមែនជាដៃរបស់អាត្មាអញតែម្នាក់ទេ គឺជាដៃរបស់គ្រូអញ របស់មិត្តអញ របស់ម៉ែអញ អញតោងតែថែរក្សាវាឱ្យបានល្អ ។

លើសពីនេះគេមានការភ្ញាក់ផ្អើលជាខ្លាំង ពីអធិគុណនៃវិជ្ជាពេទ្យ ។ ម្រាមដៃដែលគេបានលំបាកអស់រយៈពេល១០ឆ្នាំ បានត្រូវត្រឡប់ទៅជាធម្មតាក្នុងរយៈពេលតែបីអាទិត្យ ។

តាំងពីព្យាបាលដៃជាមក *សេសាគី* មានបំណងថា ខ្លួនក៏ត្រូវតែរៀនវិជ្ជាពេទ្យ ហើយក្លាយទៅជាគ្រូពេទ្យមើលជម្ងឺឱ្យមនុស្សជាច្រើនបានជា នាអនាគតកាល ។

# ជំហានទី១ ទៅកាន់វិជ្ជាពេទ្យ

នៅពេលបានបញ្ចប់ការសិក្សា នៅសាលាបឋមសិក្សាជាន់ខ្ពស់មក *សេសាគី* បានចូលធ្វើគ្រូបង្រៀននៅភូមិ មួយរយៈពេល។ ប៉ុន្តែ ទឹកចិត្តដែលចង់ក្លាយទៅជាគ្រូពេទ្យ មិនបានចុះអន់ថយទេ ផ្ទុយទៅវិញ សន្ទុះចិត្តនេះរឹតតែកញ្ជ្រោលខ្លាំងឡើងៗ នៅក្នុងទ្រូងរបស់ *សេសាគី* ។

លុះដល់បង្ក្រាបចិត្តនេះលែងបាន *សេសាគី* បានចូលទៅសំណាក់លោកគ្រូ *កុបាយ៉ាស៊ី* ហើយពិគ្រោះជាមួយនឹងលោក។

-លោកគ្រូ ដោយសារតែគុណបុណ្យរបស់លោកគ្រូពេទ្យ *វ៉ាតាណាបេ* ដៃរបស់ខ្ញុំបាទក៏បានជានា ហើយខ្ញុំបាទអាច

ប្រើវាធ្វើអ្វីគ្រប់យ៉ាងបាន។ ខ្ញុំបាទបានដឹងពីអធិគុណរបស់វិជ្ជាពេទ្យ ហើយមានគំនិតថា នឹងក្លាយទៅជាគ្រូពេទ្យដើម្បីធ្វើការងារ ជាប្រយោជន៍ដល់មនុស្សម្នាទាំងឡាយ។

-ប្រសើរណាស់គំនិតចៅឯងនេះ។ ប៉ុន្តែ តើយើងត្រូវធ្វើយ៉ាងម៉េចបាំ?

វេលានោះ ខួរក្បាលរបស់អ្នកទាំងពីរគិតឃើញតែរូបលោកគ្រូពេទ្យ *វ៉ាតាណាបេ* មួយតែប៉ុណ្ណោះ។

-រកទៅពិគ្រោះជាមួយនឹងលោកគ្រូពេទ្យ *វ៉ាតាណាបេ* លមើល ក្រែងលោលោកអាចប្រើឱ្យធ្វើជាអ្នកយាមក្លោងទ្វាផ្ទះលោកបណ្ដើរ ឱ្យរៀនបណ្ដើរ។

នៅវេលាដែលគិតឃើញគំនិតនេះភ្លាម *សេសាគី* ក៏ចាប់ផ្ដើមអនុវត្តភ្លាម។ ទោះជាត្រូវដើរ២០គីឡូ ក៏គ្មានបញ្ហាដែរ។ គេធ្វើដំណើរទៅកាន់ផ្ទះពេទ្យ ដែលគេបានបែកយូរណាស់ហើយ ទាំងបេះដូងរីករាយ។

-អូ ក្មួយ *ណូហ្គូជី*។ ម៉េចមានការអ្វី? ដៃឯងមានបញ្ហាអ្វីឬ?

លោកពេទ្យបែរមុខមករកមើលដៃឆ្វេងរបស់ *សេសាគី* បណ្តើរ សាកសួរមកដោយសម្លេងស្រទន់បណ្តើរ ។

-ព្រះបាទទេ លោកគ្រូពេទ្យ ។ ដោយសារតែគុណបុណ្យលោកគ្រូពេទ្យ ដៃរបស់ខ្ញុំបាទបានជាសះស្បើយ ស្រួលបួលល្អណាស់ ។ ថ្ងៃនេះខ្ញុំបាទមកជំរាបសួររឿងផ្សេងទៀតទេ ទានប្រោស ។



លោកគ្រូពេទ្យ វ៉ាតាណាបេ

-អញ្ចឹងទេ? មើល និយាយមកមើល កុំខ្លាចចិត្តខ្លាចថ្លើមអ្វី ។

*សេសាគី* បានខិតខំប្រមែប្រមូលអស់សេចក្តីក្លាហាន បើកទ្រូងជំរាបលោកគ្រូពេទ្យ ពីទឹកចិត្តប្តេជ្ញារបស់ខ្លួន ព្រមទាំង សូមឱ្យលោកគ្រូពេទ្យ ជួលខ្លួនជាគូលីយាមទ្វាររបងលោកផង ។

លោកគ្រូពេទ្យបានឃើញ *សេសាគី* ដែលសុភាពរាបសាបែបនេះ លោកក៏អាណិត ហើយយល់ព្រមតាមបំណងរបស់កុមារនេះ ។

-ចូរឯងកុំភ្លេចទឹកចិត្តនេះឱ្យសោះ ហើយខំប្រឹងឱ្យបានទៅជាគ្រូពេទ្យចំណានមួយរូបណាំ ។ បើយើងអាចធ្វើអ្វីមួយ ជាកម្លាំងដល់ឯង យើងមិនរួញរានឹងជួយទេ ។

*សេសាគី* បានជាន់ដល់ជំហានទី១នៃកាំជណ្ដើរ នៃវិជ្ជាពេទ្យហើយ ។ វេលានោះគេមានអាយុ១៧ឆ្នាំ ។

គេក្រោកពីដំណេកមុនគេមុនឯង រែកទឹក បោសជូតសំអាតផ្ទះ ហើយរត់ទៅទិញឥវ៉ាន់តាមតែគេប្រើ ។មួយថ្ងៃៗរវល់វិលក្បុង ។



នៅផ្ទះរបស់លោកគ្រូពេទ្យ *វ៉ាតាណាបេ* មាននិស្សិតជាច្រើនដែលមកសុំជ្រកកោន រៀនជាមួយលោក។ *សេសាគី* ចូលក្រោយហើយក្មេងជាងគេផង ក៏តោងតែធ្វើការងារច្រើនជាងគេ ។ ទំរាំតែធ្វើការងារកំប៉ិកកំប៉ុកបែបនេះរួចរាល់,យប់ជ្រៅល្មម។ ដល់ពេលដែលគេទំនេរអាចរៀនបានហើយ។ តែ *សេសាគី* អស់កម្លាំងណាស់ គ្មានទឹកចិត្តនឹងរៀនទេ ចង់តែប្រាសខ្លួនសំរាក។ ប៉ុន្តែទឹកចិត្តដែលចង់ក្លាយទៅជាគ្រូពេទ្យចំណានជំរុញឱ្យគេអាចខិតខំរៀនបាន។ វេលាដែលគិតទៅដល់មាតា ដែលតែងតែចង់ឱ្យខ្លួនមាន



ជោគជ័យក្នុងជីវិត ពីលោកគ្រូ *កុបាយ៉ាស៊ី* និងមិត្តភក្តិ ដែលតែងតែបារម្ភពីខ្លួន ជួយជ្រោមជ្រែងខ្លួន *សេសាគី* មិនអាចបណ្តោយឱ្យពេលវេលាកន្លងផុតទៅដោយឥតអំពើបានឡើយ ។ នៅពេលដែលមិនសូវយល់កន្លែងណាមួយ *សេសាគី* តែងតែ សាកសួរលោកគ្រូជានិច្ច ។ រីឯលោកគ្រូវិញ នៅពេលឃើញ *សេសាគី* ចេះតែចំរើនលឿនលយទៅមុខឆាប់រហ័ស លោកមានការភ្ញាក់ ផ្អើលជាខ្លាំង ។ ជាពិសេសចំពោះការចំរើនដ៏លឿនខាងភាសាអង់-គ្លេសរបស់ យុវជននេះ ។

ក្រោយមក *សេសាគី* បានខិតខំរៀនខ្លួនឯងនូវវិជ្ជា ខាងភាសាអាល្លឺម៉ង់ ភាសាបារាំង ភាសាចិន អេស្ប៉ាញ៉ុលថែមទៀត ។

នេះមិនមែនបានន័យថា *សេសាគី* មានប្រាជ្ញាវៀងវៃតែម្យ៉ាងទេ គឺជាផ្លែផ្កានៃការខិតខំ និងការព្យាយាមដ៏ខ្លាំងក្លាព្រមទាំងការមិនចុះចាញ់ចំពោះសេចក្តីលំបាកនានានៃយុវ

-ជននេះ ។ លើសពីនេះទៅទៀត គឺការអាចប្រមូល និងភ្ជង់អារម្មណ៍ឱ្យមូលទៅលើមុខវិជ្ជាមួយណារបស់គេបាន ។ នៅពេលដែលគេជក់នឹងអ្វីមួយហើយ *សេសាគី* ភ្លេចវត្តមាននៃអ្វីផ្សេងទៀតអស់ ។

នៅពេលជាមួយគ្នានោះ មានយុវជនម្នាក់ឈ្មោះ *យោស៊ីដា*។

*យោស៊ីដា* ចូលមកមន្ទីរព្យាបាលលោកគ្រូ *វ៉ាតាណាបេ* ក្នុងនាមជានិស្សិតម្នាក់ ។ *យោស៊ីដា* ក៏ជាកូនកសិករដូច *សេសាគី* ដែរ ។ លើសពីនេះ គេមានប្រាជ្ញាមិនចាញ់ *សេសាគី*ទេ ។ ចំពោះ *សេសាគី* វត្តមានរបស់ *យោស៊ីដា* គឺជាការទទួលនូវដៃគូដ៏ល្អមួយសំរាប់គេ ។

លោកគ្រូបានរៀបចំបន្ទប់មួយនៅជាន់ទីពីរឱ្យ( អោយ) សិស្សពីររូបនេះ ដើម្បីឱ្យគេអាចរៀនឱ្យបានសមល្មមតាមចំណង់ចិត្តរបស់គេ ។



ទោះជាដល់ម៉ោង១២ ឬ មួយយប់ហើយក្តី ក៏គេនៅតែឃើញចង្កៀងបន្ទប់អ្នកទាំងពីរ នៅឆេះដែរ។ អ្នកជិតខាងទាំងឡាយ នាំគ្នាសរសើរមិនដាច់ថា :

-និស្សិតទាំងនេះចំជាសិស្សឧស្សាហ៍មែនតែម្តង។

អ្នកទាំងពីរបានព្យាយាម បែបនេះ ហើយបានលូតលាស់មួយជំហានបន្តិចៗនៅ ក្នុងថ្នាលនៃវិជ្ជាពេទ្យ។





# អតិសុខុមទស្សន៍ជារបស់ចំឡែកមែន

នៅតំបន់នេះ មានជម្ងឺចម្លែកម្យ៉ាង ដែលឆ្លងរាលដាលពាសពេញ។ អ្នកជម្ងឺក្តៅហើយស្រេក រួចហើយក៏លាប់ក្តៅមកវិញសាជាថ្មីទៀត។ គឺជាជម្ងឺថ្មីមួយដែលគេហៅថា "គ្រុនក្តៅលាប់" ដែលឆ្លងតាមចៃ ឬសង្កើចដែលនាំឱ្យសម្បុរអ្នកជម្ងឺឡើងលឿង។

លោកគ្រូបានបង្ហាញ "មេក្រុប" នៃជម្ងឺនេះតាមអតិសុខុមទស្សន៍ ដែលលោកទើបនឹងទិញថ្មីៗ។

និស្សិតទាំងឡាយនាំគ្នាឆ្លុះមើលម្នាក់ម្តងៗ តាមកែវឆ្លុះយ៉ាងចម្លែក ហើយភ្ញាក់ផ្អើលគ្រប់ៗគ្នា។ លុះដល់វេនរបស់ *សេសាគី*ៗ ឆ្លុះមើលតាមអតិសុខុមទស្សន៍ ឡើងភ្លឹក ផត

ព្រមដកភ្នែក។ ព្រលឹងគេហាក់ដូចជាត្រូវបាន "មេក្រុប" ដ៏តូចឆ្មារចម្លែកនេះខាបយកទៅបាត់បែបនោះឯង។

វេលានោះ និស្សិតម្នាក់ស្រែកថា :

-នែ *ល្អងជី* ឱ្យគ្នាមើលម្ដងមើលរ៉ឺ ! ដៃឯងនេះទោះជាមួយអាយ៉ូសទៀត ក៏មិនអាចប្រើអតិសុខុមទស្សន៍ឱ្យស្រួលបានដូចគេដូចឯងដែរ។

*សេសាគី* ភ្នាក់ក្រញេង។ ខ្លួនក៏ខុសដែរ ដោយមិនបានផ្ទេរវេនទៅឱ្យមិត្តភក្តិមើលអតិសុខុមទស្សន៍ឆាប់ៗ។ ប៉ុន្តែល្បងនេះគ្រាន់តែប៉ុណ្ណឹង ក៏លើករឿងដៃឆ្វេងមកនិយាយដែរ។ *សេសាគី* មិនសប្បាយចិត្តទេ នៅពេលដែលនរណាម្នាក់និយាយប៉ះពាល់ដល់រឿងដៃរបស់គេ។ ជាការពិតណាស់ ទោះជាគេបានវះកាត់វាហើយក្តី ក៏ចុងម្រាមដៃដែលមានរបួសមិនអាចកំរើកឱ្យបានល្អិតល្អន់ឡើយ។

*សេសាគី* ធ្វើមុខជូរ។ គេនិយាយទៅកាន់មិត្តថា :

-*យោស៊ីដា* គ្នាសុំទោស ។ ដោយគ្នាវាមិនដែលឃើញក៏ជ្រុល ជក់មើល ភ្លេចថាមានគេរង់ចាំពីក្រោយ ។

-អូ ! ឯងនៅគិតអីទៀតរឿងកន្លងទៅហើយហ្នឹង? គិតទៅ ចម្លែកមែន មេក្រុបនេះចេះកំរើកហ្នំ ។

-គ្នាដូចជាចង់ស្រាវជ្រាវពីមេក្រុបនេះដល់ហើយ ។ តើខ្លួនយល់ថាជាមួយនឹងដៃបែបនេះគ្នាអាចធ្វើកើត ឬមិនកើតរើយ?

-វាមិនដែលកើតអីដោយគ្រាន់តែដៃឆ្វេងហ្នឹងពិការទេ ។ ខំទៅ វាមុខជានឹងបានសំរេច ។ ចម្លែកម្ល៉េះ *ណូប៉ូជី* ថ្ងៃនេះ?

*យោស៊ីដា* បានជួយលើកទឹកចិត្ត *សេសាគី* ។ *សេសាគី* បានគិតព្រមទាំងប្ដេជ្ញាក្នុងចិត្តថា :

-ជាមួយនឹងដៃពិការបែបនេះ បើទោះជាអាត្មាអញបានធ្វើជាគ្រូពេទ្យក៏អ្នកជម្ងឺមិនសូវស្រួលចិត្តប៉ុន្មានដែរ ។ បើដូច្នេះអញយល់ថា មានតែការស្រាវជ្រាវរកប្រភពនៃជម្ងឺទេទើបស្រួល ហើយវាត្រូវនឹងធាតុខ្លួនអញផង ។ ត្រូវហើយការ

ប្រយុទ្ធជាមួយនឹងសរីរៈ ដែលមើលនឹងភ្នែកមិនឃើញនោះ វាពិតជាត្រូវនឹងធាតុខ្លួន ហើយវាត្រូវតែទៅជាការងារប្រចាំជីវិតរបស់ខ្លួន ។

នោះជាពេលដែល *សេសាគី* កំពុងតែដឹងថា អ្វីដែលខ្លួនចង់ធ្វើ កាន់តែលេចរូបរាងច្បាស់ឡើង បន្តិចម្តងៗជាលំដាប់ហើយ ។

នៅឆ្នាំ១៨៩៤ ប្រទេសជប៉ុនបានធ្វើសង្គ្រាមជាមួយនឹងប្រទេសចិន ។ គឺជាសង្គ្រាមរវាងប្រទេសមហាយក្ស និងជប៉ុនដ៏តូច ។ លោកគ្រូ *វ៉ាតាណាបេ* បាន ត្រូវគេកេណ្ឌយកទៅឱ្យព្យាបាល អ្នករបួសនៅសមរភូមិ ។

ដល់តែដូច្នេះទៅលោកតោងតែបិទមន្ទីរព្យាបាលមួយរយៈ ។ និស្សិតពេទ្យទាំងឡាយតោងតែ ទៅរៀននៅមន្ទីរពេទ្យផ្សេង ឬក៏ ត្រឡប់ទៅផ្ទះរបស់ខ្លួនមួយរយៈសិន ។

*សេសាគី* ក៏តោងតែបែកពីមិត្តសម្លាញ់ *យោស៊ីដា* ដែរ ។ លើសពីនេះ គេប្រហែលជាលែងបានរៀនវិជ្ជានេះបន្តទៅ

ទៀតហើយក៏មិនដឹង ។ វេលានោះលោកគ្រូបានហៅ *សេសាគី* មកផ្ដាំផ្ញើឱ្យជួយនៅមើលផ្ទះពេទ្យជំនួសលោក ។

-លោកគ្រូគាត់ជឿទុកចិត្តលើអញណាស់ បើដូច្នេះអញតោងតែខិតខំធ្វើយ៉ាងណា ឱ្យមន្ទីរពេទ្យនេះមានដំណើរការទៅមុខបានល្អ ទើបសមនឹងទឹកចិត្តប្រោសប្រណីរបស់លោកនេះចំពោះរូបអញ ។

*សេសាគី* បានខិតខំចាំផ្ទះពេទ្យរបស់លោកគ្រូ ដោយប្រឹតប្រៀន ហើយក៏មិនភ្លេចការសិក្សាដែរ ។ គេរឹតតែខំរៀនទ្វេមួយជាពីរ ។ ដើម្បីនឹងទៅជាគ្រូពេទ្យបាន គេតោងតែចេះភាសាអាល្លឺម៉ង់ ។ *សេសាគី* បានព្យាយាមរៀនភាសាអាល្លឺម៉ង់ ហើយអាចអានសៀវភៅពេទ្យដែលសរសេរជាភាសានេះស្ទាត់ ។ ចំណែកឯការរៀនភាសាបារាំង ក៏គេខិតខំមិនឱ្យភ្លេចដែរ ។

ពេលវេលាកន្លងទៅឆាប់ណាស់ ។ ធ្មេចបើក១សោះរយៈពេលពីរឆ្នាំបានកន្លងទៅផុត ។ លោកគ្រូ *វ៉ាតាណាបេ*

បានបញ្ចប់បេសកកម្មដោយសុវត្ថិភាពហើយបានវិលត្រឡប់មកប្រទេសជាតិវិញ។ លោកគ្រូមានការពេញចិត្ត និងសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ *សេសាគី* ជាខ្លាំង។

លោកគ្រូមានមិត្តម្នាក់ឈ្មោះ *ជីរ៉ាគី ម៉ូរីណុស៊ីតេ* ។ គាត់ជាអ្នកឯកទេសខាងវិជ្ជាពេទ្យធ្មេញ។ លោក *ជីរ៉ាគី* បង្រៀននៅតូក្យូ ឯនោះទេ ប៉ុន្តែលោកឆ្លៀតពេលវ៉ាកងខែក្តៅ មកពិនិត្យមើលធ្មេញឱ្យប្រជាជននៅស្រុកដែលលោកគ្រូពេទ្យ *វ៉ាតាណាបេ* រស់នៅ។ នៅជំនាន់នោះមិនសូវមានពេទ្យធ្មេញទេ។ ទោះជាមាន ក៏ មានតែនៅទីក្រុងធំៗ ឯនៅតំបន់ស្រុកស្រែ សូម្បីតែម្នាក់ ក៏មិនមានដែរ។ ឮតែថាមានពេទ្យធ្មេញ មកព្យាបាលឱ្យដូច្នេះ ប្រជាជនក៏បាក់ទ័ពមកឱ្យលោកគ្រូពេទ្យពិនិត្យ នាំឱ្យលោកគ្រូពេទ្យ *ជីរ៉ាគី* រវល់ជាខ្លាំងមួយថ្ងៃៗ។

លុះដល់ការពិនិត្យក្នុងមួយថ្ងៃចប់រួចរាល់ទៅ លោកគ្រូពេទ្យ *ជីរ៉ាគី* តែងតែឡើងមកលេងនឹងលោកគ្រូពេទ្យ *វ៉ាតា*



*ណាកេប* ។

-*វ៉ាតាណាកេប* គ្មាពួល្បីថានៅពេទ្យខ្លួនមាននិស្សិតក្មេងឧស្សាហ៍ ។

-ឱ ! ប្រហែលជាណូហ្គូជី ហើយ ។ ហ្នឹងហើយ  គេជានិស្សិត

ដែលមានអនាគតល្អទៅមុខ ។



ឯងគួរតែជួបគេឱ្យស្គាល់ដែរ

ក្រែងអាចពឹងពាក់អ្វី ។

*សេសាគី* ក៏បានស្គាល់លោកគ្រូ

ពេទ្យ *ជីវ៉ាគី* នៅពេលនោះ ដោយ

សារការណែនាំឱ្យស្គាល់ ពីលោក

គ្រូពេទ្យ  *វ៉ាតាណាកេប*។ វេលា

ដែលបាននិយាយគ្នាជាមួយសេសាគី លោកគ្រូ *ជីវ៉ាគី* ក៏ភ្ញាក់ដោយបានដឹងថាសេសាគីខិតខំរៀនចេះ ដឹងបានជ្រៅជ្រះណាស់។ សំនួររបស់ *សេសាគី* នីមួយៗសុទ្ធតែមានកំរិតខ្ពស់ ហើយសួរតែកន្លែងពិបាក។

-យ៉ាងម៉េចដែរ ឯងអាចមក តូក្យូ បានទេ។ ស្ថានីយចុងក្រោយ គឺមានតែ តូក្យូ ទេ។ ឯខ្ញុំៗក៏នឹងជួយឯងទៅតាមសមត្ថភាពរបស់ខ្ញុំដែរ។

លោកគ្រូ *ជីវ៉ាគី* បានបន្សល់ពាក្យនេះទុកឱ្យ *សេសាគី* ហើយក៏ត្រឡប់មកតូក្យូវិញបាត់ទៅ។



# លោកគ្រូពេទ្យ ជីវ៉ាគី

ដល់ពេលដែល *សេសាគី* ត្រូវប្រឡង យកសញ្ញាប័ត្រពេទ្យហើយ ។

-លោកគ្រូ *វ៉ាតាណាបេ* ខ្ញុំបាទសូមអរគុណ ដោយលោកគ្រូបានជួយជ្រោមជ្រែងខ្ញុំបាទរហូតមកដល់ខណៈនេះ ។ ខ្ញុំបាទដឹងដែរ ថា ចំណេះខ្ញុំបាទនៅស្ដើរណាស់ ក៏ប៉ុន្តែខ្ញុំបាទគិតសុំលាលោកគ្រូចេញទៅតូក្យូ ដើម្បីប្រឡងពេទ្យ លមើលហើយ ។

-អញ្ចឹងឬ? *សេសាគី* គ្រូមិនឃាត់ឯងទេ ។ គ្រូឃើញថាឯងបានខិតខំ ហើយមានចំណេះវិជ្ជាគ្រប់គ្រាន់អាចនឹងចូលទៅប្រឡងនឹងគេនឹងឯងបានហើយ ។

លោកគ្រូបានអនុញ្ញាត ឱ្យទៅដោយស្នោះស្ម័គ្រ ព្រមទាំងខ្សៀកកូនសំបុត្របណ្ដាំមួយ ផ្ញើទៅផ្ដាំផ្ញើឱ្យលោកគ្រូពេទ្យ *ជីវ៉ាគី* ជួយមើល *សេសាគី* ទៀតផង។ រួចហើយ លោកគ្រូបានដកប្រាក់១០យ៉េនផ្ដល់ឱ្យ *សេសាគី* ជាសោហ៊ុយធ្វើដំណើរថែមទៀត។



ឯលោកគ្រូ *កុបាយ៉ាស៊ី* ក៏ត្រេកអរអស្ចារ្យដែរ។ លោកគ្រូបានមានប្រសាសន៍ថាកុំឱ្យ *សេសាគី* បារម្ភពីម្ដាយឱ្យសោះ ឱ្យទៅក្រុងខិតខំប្រឡងឱ្យបានជាប់ចុះ។

អក្សរឆ្លាក់លើសសរផ្ទះ

រួចហើយ លោកគ្រូបានហូតយកលុយ១០ យ៉េន ពីប្រាក់ខែ១២យ៉េន របស់លោកហុច ឱ្យទៅ *សេសាគី* ។ ឯ *ដៃគិជី* ដែលនៅជិតខាង ក៏បានឱ្យ៣យ៉េនដែរ ដោយពេលនោះ ផ្ទះសំណាក់មិនសូវចំណេញ ក៏ឱ្យបានតែប៉ុណ្ណោះ។

*សេសាគី* បានទទួលការអបអរលើកទឹកចិត្តពីញាតិមិត្ត ជិតឆ្ងាយយ៉ាងកក់ក្ដៅ ហើយត្រូវចាកចេញពីភូមិស្រុកទៅហើយ ។

លាហើយផ្ទះកំណើតប្រក់ស្បូវ ដែលជាទីស្រឡាញ់ ជាទីរលឹក ។ *សេសាគី* បានយកដែកគោលឆ្លាក់ជាអក្សរលើសសរដែលឡើងខ្មៅ រលនៃកូនបន្ទប់ ទទួលភ្ញៀវ ជាន័យថា ៖

"ប្រសិនបើ គោលបំណង របស់ខ្លួនមិនបានសំរេចទេ ខ្លួននឹងមិនត្រឡប់មកទីនេះជាលើកទី២ឡើយ ។"

ថ្ងៃនោះនៅពេលព្រឹកព្រលឹម *សេសាគី* បានទៅផ្ទះលោកគ្រូ *កុបាយ៉ាស៊ី* នៅឯ *អ៊ីណាវ៉ាស៊ីរ៉ូ* ជាមួយនឹងមាតា ។ លោកគ្រូ និងភរិយាបានធ្វើម្ហូបចំណីជប់លៀងឱ្យ ។ មាតា និងលោកគ្រូ *កុបាយ៉ាស៊ី* បានជូនដំណើរគេរហូតដល់ក្បាលស្ពាននៅចុងភូមិ ។

-លោកគ្រូ! ម៉ែ! ទោះ ជាអ្នកទាំងពីរជូនខ្ញុំបាទ ទៅដល់ណាក៏មិនគ្រប់គ្រាន់នឹងចិត្តនឹករលឹក និងចិត្តដែលមិនចង់បែក

ដែរ។ ជូនត្រឹមនេះបានហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ។

-កូន ចូរកូនប្រុងប្រយ័ត្នខ្លួនប្រាណ កុំឱ្យឈឺចាប់ណា។ ឯម្ដាយ ចូរឯងកុំបារម្ភ។

-ម៉ែ សូមម៉ែថែរក្សាខ្លួនណា។ ខ្ញុំនឹង ខិតខំប្រឹង ឱ្យបានក្លាយជាគ្រូពេទ្យដ៏ប្រសើរសំរាប់ភូមិរបស់យើង ម៉ែចាំមើលចុះ។



*សេសាគី* លាបឹងទន្លេដែលអាចមើលឃើញពីចន្លោះព្រៃព្រឹក្សាលាភ្នំ បាន់ដៃ ដែលលូតសន្ធឹម ខ្ពស់ទៅលើមេឃនៃរដូវស្លឹកឈើជ្រុះ និងភូមិស្រុក ដែលពោរពេញទៅ ដោយអនុស្សាវរីយដ៏ច្រើនលើសលុប។

-លោកគ្រូ ! ម៉ែ ! ខ្ញុំបាទសូមគោរពលាហើយ ។

*សេសាគី* សឹងតែរត់ត្រឡប់ក្រោយទៅចាប់ដៃមាតាលា ជាថ្មីទៀត ប៉ុន្តែ គេបានកាត់ចិត្ត ដើរត្រង់ទៅមុខឥតងាក ក្រោយ ។



ស្រមោល *សេសាគី* ដែល ពាក់គីម៉ូណូ និង ស្បែកជើងឈើ បានរួមតូចទៅៗ ។

-លាហើយ

-លាហើយ

ពីទីនោះទៅ *សេសាគី* ត្រូវធ្វើដំណើរដោយជើង ចំនួន ២៤គីឡូ ទើបអាចបានទៅដល់ស្ថានីយ *ម៉ូតូមីយ៉ា* នៃខ្សែ រថភ្លើង *តូហុគី ហុងសិង* ដើម្បីឡើងជិះរទេះភ្លើង ។ យុវជន

ដើរយ៉ាងលឿនតាមផ្លូវព្រៃភ្នំដែលទទឹកជោកទៅដោយទឹកសន្សើមវេលាព្រឹក ដោយទឹកចិត្តសប្បាយចម្លែកដូចគេប្រុងប្រៀបនឹងហោះ ។ វេលានោះ *សេសាគី* មានអាយុ២០ឆ្នាំ ។

*សេសាគី* ធ្វើដំណើរពី *កូរិយ៉ាម៉ា* សំដៅទៅតូក្យូ ។ គឺជាលើកទីមួយហើយដែល *សេសាគី* បានជិះរទេះភ្លើង ។

ខែកញ្ញា ឆ្នាំ១៨៩៦ (ចូលសម័យ *មេជី* បាន២៩ឆ្នាំ) *សេសាគី* បានជាន់ដីនៃទីក្រុងតូក្យូជាលើកដំបូងបង្អស់ ។ គេប្រញិបប្រញាប់រកជួលផ្ទះថោកនៅ ដើម្បីរៀនប្រុងប្រៀបសំរាប់ការប្រឡង ។ ខំរៀនប្រហែលជាមួយខែ *សេសាគី* បានចូលទៅប្រឡងពេទ្យជាលើកទីមួយ ។

ដូចប្រសាសន៍របស់លោកគ្រូ *វ៉ាតាណាបេ* មែន គេបានប្រឡងជាប់ដោយជោគជ័យ ។ *សេសាគី* គិតថាបានប្រឡងជាប់ហើយ ក៏ដូចជាគេបានដើរឆ្លងភ្នំមួយហើយដែរ ប៉ុន្តែតើពីពេលនេះទៅមុខគេត្រូវធ្វើដូចម្ដេច? លុយក៏អស់ មានតែទៅរកលោកគ្រូពេទ្យ *ជីវ៉ាគី* តែប៉ុណ្ណោះ ។

លោកគ្រូពេទ្យ *ជីវ៉ាគី* ដូច មិត្តអ្នកអានបានជ្រាបហើយ គឺជាមនុស្សដែលបានឃើញការ ខិតខំរបស់ *សេសាគី* ហើយ បាន ណែនាំឱ្យ *សេសាគី* ចេញមក តូក្យូ ។



លោកគ្រូពេទ្យជីវ៉ាគី

*សេសាគី* កាន់សំបុត្ររបស់លោកគ្រូ *វ៉ាតាណាបេ* ហើយ ចេញដំណើរទៅមន្ទីរពេទ្យធ្មេញឈ្មោះ *តាកាយ៉ាម៉ា* ដែល លោកគ្រូពេទ្យ *ជីវ៉ាគី* ធ្វើការ ។

-លោកគ្រូពេទ្យ ខ្ញុំបាទបានចេញពីភូមិស្រុកមកមែនតាម បណ្តាំរបស់លោកគ្រូពេទ្យបាត់ ទៅហើយ ។

-អូ *សេសាគី* សូមស្វាគមន៍ ។ ឥឡូវឯងធ្វើការអ្វីដែរ?

-បាទ លោកគ្រូពេទ្យ ខ្ញុំបាទបានប្រឡងជាប់សញ្ញាប័ត្រ ពេទ្យគ្រលាក់ទីមួយហើយ ។

-ប្រសើរណាស់។ សូមជូនពរ។ ចូរខិតខំប្រឹងប្រែងណា៎ អនាគតឯងនឹងបានល្អប្រសើរហើយ ពីពេលនេះតទៅ។

*សេសាតី* បាននិយាយរៀបរាប់ពីដំណើរការ រហូតមកដល់ពេលនេះ ហើយសុំឱ្យលោកគ្រូពេទ្យ *ជីវ៉ាតី* ជួយឱ្យយោបល់។ រួចហើយ ក៏ធ្វើសំណូមពរត្រង់ៗថា :

-តើលោកគ្រូមិនអាចទទួលខ្ញុំបាទ ឱ្យធ្វើការនៅទីនេះបានឬទេ ទាន ប្រោស?

លោកគ្រូពេទ្យក៏ឆ្លើយថា :

-ឯងចង់ធ្វើការនៅទីនេះឬ? ចាំមួយស្របក់សិនមើល ខ្ញុំទៅសួរលោកប្រធានឱ្យ។

លោកគ្រូពេទ្យ ក៏ប្រញិបប្រញាប់ទៅសុំលោកប្រធានពេទ្យឱ្យ *សេសាតី* បានធ្វើការ។ ជាថៃដន្យ វេលានោះមាននិស្សិត និងអ្នកជំនួយគ្រប់គ្រាន់ហើយ *សេសាតី* មិនអាចធ្វើការទីនោះបានទេ។ លោកគ្រូ *ជីវ៉ាតី* ដោយមានចិត្តអាណិត

ចំពោះ *សេសាគី* ដែលខំកាត់វាលចូលព្រៃចប្រច់មករកលោក បែបនេះ លោកក៏ខ្នះខ្នែងជួយគិត *សេសាគី* :

-នឹកឃើញហើយ ចូរឯងទៅនៅសយនដ្ឋានសាលាមួយរយៈ សិនទៅ ទំរាំខ្ញុំរកការងារឱ្យធ្វើបាន ។

លោកគ្រូគិតបែបនេះហើយ ក៏ឱ្យ *សេសាគី* ទៅនៅសយនដ្ឋានសាលា (ផ្ទះសំរាប់និស្សិតក្រីក្រ) ហើយផ្ដែផ្ដាំពូមីងដែលជាអ្នកថែទាំ បោសជូតសយនដ្ឋាន ឱ្យជួយមើលយុវជននេះ ។

*សេសាគី* គ្មានអ្វីនឹងខ្លួនទេ ។ សូម្បីតែកន្ទេលខ្នើយ ឬខោអាវសម្រាប់ផ្លាស់ក៏គ្មានដែរ ។ កាលពីពេលដែលចូលទៅនៅផ្ទះលោកគ្រូពេទ្យ *វ៉ាតាណាបេ* ឯ *វ៉ាកាម៉ាតស៊ុ* ក៏បែបនោះដែរ ។ គេមិនអាចនិយាយថា *សេសាគី* ចូលទៅនៅសយនដ្ឋានទេ បើឱ្យថាលួចចូលទៅនៅទើបត្រឹមត្រូវជាង ។

ប៉ុន្តែ *សេសាគី* មិននៅស្ងៀមដៃទេ អ្នកជួយធ្វើការពូមីង ដូចជាកាលពីពេលដែលអ្នកនៅឯ *វ៉ាកាម៉ាតស៊ុ* ជាមួយ

លោកគ្រូពេទ្យ *ភីតាណាបេ* បែបនោះឯង។ អ្នកបោសជូត ក្តាររនាប ចង្កៀងឱ្យស្អាត ឱ្យតែឃើញទាស់ភ្នែក ក៏សំអាត មិនចាំបាច់ឱ្យគេប្រើទាន់ឡើយ។ ក៏ប៉ុន្តែការជូតចង្កៀងមាន ការយ៉ាប់យ៉ឺនណាស់ ដោយសារតែដៃឆ្វេងរបស់ *សេសាគី* មិនធម្មតា។ ដូច្នេះគេមិនអាចទប់អំពូងចង្កៀងឱ្យជាប់បាន ទេ។ គេយកជើងទាំងពីររបស់គេគៀបអំពូងចង្កៀងឱ្យនៅ នឹង ហើយទើបចាប់ជូតសំអាត។



អ្វីៗដែល *សេសាគី* ធ្វើ មិនកន្លងពីភ្នែករបស់ចាងហ្វាងសាលាទេ។ លោកគ្រូចាងហ្វាង *តាកាយ៉ាម៉ា* គិតក្នុងចិត្តថា និស្សិតនេះខិតខំណាស់ទេតើ? មិនធម្មតាទេ។ បើប្រើវាឱ្យជួយកិច្ចការកំប៉ិកកំប៉ុក ច្បាស់ជាវាខិតខំជួយធ្វើមិនខានឡើយ។

ដូច្នេះហើយ *សេសាគី* ក៏ត្រូវបានគេជួលឱ្យធ្វើជាកម្មករជំនួយការងារមានក្របខណ្ឌ ហើយក៏បានប្រាក់បៀវត្សបន្តិចបន្តួចគ្រាន់ចាយវាយ ដាក់ហោប៉ៅនឹងគេនឹងឯង។

ដោយមានការឧបត្ថម្ភពីលោកគ្រូ *ជីវ៉ាគី* ផង *សេសាគី* ក៏ចុះឈ្មោះចូលរៀនភាសាអាល្លឺម៉ង់នៅពេលយប់។ ដោយកម្មករនេះរវល់ជក់រៀនសូត្រជ្រុលពេក ជួនកាលគេចូលទៅបណ្ណាល័យអានសៀវភៅ ជក់ទាល់តែភ្លេចរវៃជួងឱ្យសិស្សចេញពីសាលាក៏មាន។ អាការៈនេះនាំឱ្យសិស្សព្រមទាំងគ្រូគិតតែរៀនឥតបានចេញពីថ្នាក់រៀនគ្រប់ៗគ្នា។

ប៉ុន្តែដោយសារតែអ្នកណាម្នាក់ក៏ដឹងថា *សេសាគី* ខំរៀន



# ក្មេងបំរើគេបានក្លាយទៅជាគ្រូ

*សេសាគី* បានខិតខំបែបនេះ រហូតដល់អាយុ២១ឆ្នាំ ។

នៅរដូវផ្ការីក នៃឆ្នាំ១៨៩៧ *សេសាគី* បានចូលទៅប្រឡងពេទ្យគន្លាក់ទី២ ។ ដើម្បីនឹងចូលប្រឡងនេះ គេបានទៅរៀនគួរត្រៀមរៀបចំប្រុងប្រៀបជាមុន ។ គួរត្រៀមនេះចាប់ផ្ដើមនៅម៉ោង៩ព្រឹក ជារៀងរាល់ថ្ងៃ ។ នៅរដូវរងាពេលព្រឹកម៉ោង៥នៅងងឹតស្លុប មើលអ្វីមិនឃើញឡើយ ។

និស្សិត តោងតែរៀនក្រោមពន្លឺភ្លើងចង្កៀងប្រេងកាតផ្លុង១ ។ លើសពីនេះទៀត សាលារៀនគួរត្រៀមនៅឆ្ងាយពីសយនដ្ឋានរាប់គីឡូ ។ ដូច្នេះ *សេសាគី* តោងតែប្តូរផ្ទះ ។ ដើម្បីនឹងរៀនគួរ គេត្រូវចំណាយលុយមួយខែ១៥យ៉េន ។

ពេលនោះប្រាក់បៀវត្សរ៍របស់លោកគ្រូ *ជីវ៉ាគី* មានតែ ៧ យ៉េនទេ ប៉ុន្តែ លោកគ្រូបានខិតខំរកលុយពីនេះពីនោះមកឧបត្ថម្ភ*សេសាគី* ។ គិតទៅអ្នកកម្លោះនេះជាយុវជនដែលមានសំណាងខ្ពស់ណាស់។ គេបានជួបប្រទះតែមនុស្សល្អៗរកគ្មាន តាំងពីលោកគ្រូ *កុបាយ៉ាស៊ី* លោកគ្រូពេទ្យ*វ៉ាតាណាបេ*។ ឥឡូវនេះ មកពើបប្រទះនឹងលោកគ្រូពេទ្យ*ជីវ៉ាគី* ដែលមានចិត្តល្អប្រសើរនេះ ទៀត។

ថ្ងៃប្រឡងបានចូលមកដល់ហើយ។

-ខោអាវកញ្ចាស់បែបនេះ មិនសមរម្យទេ។ នេះយកខោអាវគ្នាទៅស្លៀកពាក់សិនទៅ ចាំហើយសឹមសងគ្នាវិញ។

-សក់ឯងសំពីងសំពោងណាស់ មិនសមរម្យទេ។

*សេសាគី* បានមិត្តសំឡាញ់ទាំងឡាយជួយមួយដៃមួយជើង



ហើយក៏បានចូលទៅប្រឡងផ្តាច់ព្រ័ត្រនឹងគេនឹងឯង ដោយសំលៀកបំពាក់ និងសក់ក្បាលស្អាតបាត។ មានបេក្ខជន ៨០ នាក់មកចូលរួបរួមក្នុងការប្រឡងនេះ។ គឺសុទ្ធសឹងតែជានិស្សិតដែលខិតខំរៀនសូត្រខ្លាំងក្លា សឹងតែចេញឈាមពីសាច់ម្នាក់ៗ។ គេទាំងឡាយមានមុខមាំ។

នៅក្នុងចំណោមនិស្សិតទាំងឡាយនោះ មាននិស្សិតម្នាក់ហាក់ដូចជាជ្រួលច្រាលខុស ពីគេពីឯង។



ទ្រាំមើលមិនបាន *សេសាគី* ក៏សួរទៅថា :

-នែខ្លួន ម៉េចមិនស្រួលខ្លួន ឬយ៉ាងម៉េច?

-ទេមិនមែនទេ។ គ្នាភ្លេចយកប្រដាប់ឆ្លុះ ទ្រូងអ្នកជម្ងឺមក។ ឥឡូវកំពុងតែព្រួយចិត្ត មិនដឹងជានឹងត្រូវធ្វើដូចម្ដេច។

-អញ្ចឹង? នេះគ្នាឱ្យខ្ចីរបស់គ្នា។

-បើឱ្យគ្នាខ្ចី តើឯងបានអ្វីប្រើពេលប្រឡង?

-ថ្ងៃនេះគ្នាដូចជាមិនត្រូវការវាទេ កុំខ្លាចចិត្តអី យកចុះ។

*សេសាគី* មានចិត្តល្អ ចំពោះអ្នកដែលមិនដែលស្គាល់គ្នាសោះ នេះប្រហែលជាគេជាមនុស្សដែលតែងតែលំបាក ហើយត្រេកអរ នៅពេលដែលមានគេជួយជ្រោមជ្រែង។



*សេសាគី* មិនអាចមើលមនុស្ស
ដែលជួបប្រទះនឹងការ
លំបាកនឹងភ្នែកបានទេ ។
-*ល្អូងជី សេសាគី* !
មេប្រយោគបានហៅឈ្មោះ
*សេសាគី* ៣ ។ ពេលចូលទៅដល់
ក្នុងបន្ទប់ *សេសាគី* ឃើញអ្នកជម្ងឺ ម្នាក់ដេកនៅលើគ្រែ ។ មេប្រយោគឈរ នៅក្បែរនោះ ហើយបញ្ជាឱ្យ *សេសាគី* ពិនិត្យមើលមើល ថាតើអ្នកជម្ងឺនោះ ឈឺអ្វី? *សេសាគី* ក៏តោងតែប្រើប្រដាប់ផ្លុះទ្រូងដែរ ។ គេច្រឹមច្រុមមួយស្របក់ ទើបនិយាយថា:

-សូមអភ័យទោសលោកគ្រូ សូមមេត្តាឱ្យខ្ញុំបាទខ្ចីប្រដាប់ផ្លុះទ្រូងបន្តិច ទានប្រោស ។

-ស្អី! មកប្រឡងគ្មានប្រដាប់ផ្លុះ?



នៅពេលដែលឮមេប្រយោគថាឱ្យបែបនេះ មុខរបស់ *សេសាគី* ឡើងក្រហមងាំង ។

មិនដឹងធ្វើម៉េច គេក៏រៀបរាប់រឿងដែលកើតឡើងជំរាបមេប្រយោគ។ លុះឮបែបនេះ មេប្រយោគក៏ហុចប្រដាប់ ឆ្លុះមកឱ្យសេសាគីខ្ចីដោយរីករាយ ។ ជម្ងឺរបស់អ្នកជម្ងឺនោះពិបាកយល់ណាស់ក៏ប៉ុន្តែ *សេសាគី* បានពិនិត្យ ហើយឆ្លើយបានយ៉ាងត្រឹមត្រូវ ។

មេប្រយោគបានសរសើរ សេសាគី ពីចំណេះ ជាក់ស្តែងប្រាកដប្រជា របស់និស្សិតនេះជាខ្លាំងហើយលើស ពីនេះទៅទៀត លោកបានកោតសរសើរពី ទឹកចិត្តដ៏ល្អរបស់យុវជន ទៅលើអ្នកដទៃ ។

-ធ្វើពេទ្យ មិនមែនដើម្បីកើបលុយទេ តែគឺដើម្បីសង្គ្រោះជីវិតអ្នកជម្ងឺ។ ហើយមិនមែនជាបញ្ហាចំណេញខាតទៀត ។

អ្នកឯងបានឱ្យប្រដាប់ឆ្លុះទៅគេខ្ចី ទឹកចិត្តនេះសំខាន់ណាស់ ចូរកុំភ្លេចឱ្យសោះ ទៅថ្ងៃមុខថ្ងៃក្រោយ ។

ការប្រឡងលើកទី២នេះ មាននិស្សិតមកប្រឡង ៨០ នាក់ ឯអ្នកដែលជាប់មានតែ៤នាក់តែប៉ុណ្ណោះ ។ ឈ្មោះរបស់ *សេសាគី* មាននៅក្នុងចំណោមមនុស្សទាំង៤នាក់នោះដែរ ។

អ្នកដែលរង់ចាំដំណឹងលទ្ធផលនៃការប្រឡងនេះ មានច្រើននាក់ណាស់ ។ ទីមួយ គឺមាតារបស់ *សេសាគី*។ បន្ទាប់មក គឺលោកគ្រូជាច្រើន និងមិត្តភក្តិទាំងឡាយ ។ តើអ្នកទាំងអស់នោះត្រេកអរប៉ុណ្ណាទៅ កាលបើឮដំណឹងដ៏ល្អបែបនេះ ជាពិសេសអ្នកម្តាយដែលតែងតែសង្ឃឹមញញឹមទុកជាយូរអង្វែងមកហើយ មិនដឹងជាអ្នកអរយ៉ាងណាទេ?

*សេសាគី* ផ្ទាល់ក៏ប្រហែលជាមិនដែលបានសប្បាយចិត្តដូចវេលានោះដែរទេ ។

ប៉ុន្តែ *សេសាគី* គ្មានកូនចិត្តតែបន្តិចក៏គ្មានដែរ ថានឹងវិលត្រឡប់ទៅស្រុកកំណើតប្រកបរបររកស៊ីជាគ្រូពេទ្យវិញ ។

-ខ្ញុំមិនអាចបំភ្លេចស្រមោលមេរោគ ដែលបានឃើញតាមអតិសុខុមទស្សន៍នោះបាន ឡើយ។ ត្រូវហើយ ខ្ញុំត្រូវតែក្លាយទៅជាអ្នកឯកទេស ស្រាវជ្រាវរកមេរោគ។

ពេលគិតដូច្នេះហើយ *សេសាគី* ក៏ធ្វើដំណើរទៅរកលោកគ្រូជីវ៉ាគីហើយសុំ លោកគ្រូឱ្យយកខ្លួនធ្វើជាអ្នកបំរើការងារកំប៉ិកកំប៉ុកដូចមុនដើម្បីយកលុយរៀនបន្តទៅមុខ។

ប៉ុន្តែ តើនរណាអាចយកនិស្សិតដែលបានប្រឡងជាប់ជាវេជ្ជបណ្ឌិតពេញលេញហើយ ឱ្យធ្វើជាអ្នកបំរើធ្វើការងារតូចតាចទៅរួច។ លោកគ្រូបានទៅពិគ្រោះជាមួយនឹងលោកគ្រូចាងហ្វាងសាលាសុំឱ្យទទួលយក *សេសាគី* ឱ្យធ្វើជាសាស្ត្រាចារ្យនៅសាលានោះ។

*សេសាគី* ភ្ញាក់បះជើង។ ការនេះហាក់ដូចជាមេឃនិងដីក្រឡាប់ផ្កាប់ផ្ងារពីលើចុះទៅក្រោម។ មិនងាយនឹងមាននូវការប្រែប្រួលផ្លាស់ប្តូររបៀបនេះឡើយ។

ប៉ុន្តែ    នៅមានមនុស្សដែលរឹតតែភ្ញាក់ក្រញ៉ាងជាងនេះទៅទៀត ។

នៅលើក្ដារបិតប្រកាស មានសរសេរថា :

"ពីពេលនេះ មានសាស្ត្រាចារ្យចូលថ្មី គឺលោកគ្រូ *ល្វូងជីសេសាគី* ។

សិស្សទាំងឡាយ នាំ គ្នាខ្សឹបខ្សៀវគ្នាថា តើ លោកគ្រូថ្មី



ដែលមាន ឈ្មោះថា *ល្វូងជីសេសាគី* នោះជាគ្រូបែបណា ។

ឈ្មោះថា ជានិស្សិតក៏ពិតមែន តែមាននិស្សិតខ្លះមាន អាយុច្រើនជាង *សេសាតី* ទៅទៀត។ នៅពេលដែលជួងរោទិ៍ ម៉ឺងឡើង គេក៏ឃើញគ្រូ ដើរចូលមក។ ព្រះ ! តើនោះមិន មែនជាក្មេងបំរើឈ្មោះ *ល្ហងជី* ដែលធ្លាប់ធ្វើការនៅសាលា



នេះពីមុនទេឬ? *សេសាតី* ដើរ ឡើងទៅលើកំណល់តុដាក់ សៀវភៅអាន និងសៀវភៅ សរសេរទៅលើតុ ហើយ ឱន ក្បាលគំនាប់សិស្ស។តើពេល នោះសិស្សទាំងឡាយ មើល ទៅលោកគ្រូ *ល្ហងជី* ដោយទឹកចិត្តបែបណាទៅ? នៅពេល ដែលគោរពសិស្សរួចហើយ *សេសាតី* ក៏ចាប់ផ្ដើមនិយាយ ដោយសំដីច្បាស់ៗមួយៗប្រកបទៅដោយជំនឿលើខ្លួនឯង ហើយពាក្យសម្ដីនោះហូររូទៅមុខជាលំដាប់។ សិស្សទាំង

ឡាយនៅស្ងៀមចាំមើល *សេសាគី* ។ ចុងបញ្ចប់ សិស្សខ្លះក៏ចាប់ផ្ដើមចាប់ប៉ាកាកត់ត្រា នូវសំដីរបស់ *សេសាគី* ទុក ។

សិស្សទាំងឡាយមានការកោត ចំពោះសំដីដ៏ប្រកបទៅដោយន័យ ដ៏ជ្រាលជ្រៅរបស់ *សេសាគី* ហើយក៏ខិតខំស្ដាប់ដោយយក ចិត្តទុក ដាក់បន្តទៅ ។

នៅពេលដែលបានបញ្ចប់ មេរៀន ជាលើកទីមួយដោយជោគជ័យមក ស្រមោលដ៏ទាប របស់ *សេសាគី* ក៏ដើរចេញពីបន្ទប់រៀនទៅ ។

-សុំចាញ់ហើយ ។

-តាមពិតទៅ ដំបូងគ្នាពេប ឱ្យគាត់ទេតើ ។ ម៉េចដែរ មេរៀន គ្រូ នេះ?

-គួរឱ្យកោតពេកណាស់ !

-ពួកយើងក៏តោងតែខិតខំដែរ ទើបបាន ។

ជាលើកដំបូង ក្នុងឋានៈជាគ្រូ លោកគ្រូ *ណូដូជី* បានបំពេញការងារ ប្រកបដោយជោគជ័យសំបើម ។ សូមមេត្តា

រលឹកឃើញពីពេលដែលលោកគ្រូ *ណូង្គជី* បានគេឱ្យធ្វើជា *សេជោ* នៅសាលាបឋមសិក្សា ។ ពីពេលនោះមកដល់ឥឡូវ ពេលវេលាបានកន្លងទៅអស់១០ឆ្នាំគត់ហើយ ។

ឡាយនៅស្ងៀមចាំមើល*សេសាគី* ។ ចុងបញ្ចប់ សិស្សខ្លះក៏ចាប់ផ្ដើមចាប់ប៉ាកាកត់ត្រា នូវសំដីរបស់ *សេសាគី* ទុក។

សិស្សទាំងឡាយមានការកោត ចំពោះសំដីដ៏ប្រកបទៅដោយន័យ ដ៏ជ្រាលជ្រៅរបស់*សេសាគី* ហើយក៏ខិតខំស្ដាប់ដោយយក ចិត្តទុក ដាក់បន្តទៅ។

នៅពេលដែលបានបញ្ចប់ មេរៀន ជាលើកទីមួយដោយជោគជ័យមក ស្រមោលដ៏ទាប របស់ *សេសាគី* ក៏ដើរចេញពីបន្ទប់រៀនទៅ។

-សុំចាញ់ហើយ ។

-តាមពិតទៅ ដំបូងគ្នាពេប ឱ្យគាត់ទេតើ។ ម៉េចដែរ មេរៀន គ្រូ នេះ?

-គួរឱ្យកោតពេកណាស់ !

-ពួកយើងក៏តោងតែខិតខំដែរ ទើបបាន។

ជាលើកដំបូង ក្នុងឋានៈជាគ្រូ លោកគ្រូ *ណូមូជី* បានបំពេញការងារ ប្រកបដោយជោគជ័យសំបើម។ សូមមេត្តា

រលឹកឃើញពីពេលដែលលោកគ្រូ *ណូងជី* បានគេឱ្យធ្វើជា *សេជោ* នៅសាលាបឋមសិក្សា។ ពីពេលនោះមកដល់ឥឡូវ ពេលវេលាបានកន្លងទៅអស់១០ឆ្នាំគត់ហើយ ។

# ពីសេសាគីទៅហ៊ីដេយោ

នៅឆ្នាំ១៨៩៨ *សេសាគី* បានទៅធ្វើ ជាអ្នកជំនួយការ នៅ វិជ្ជាស្ថានស្រាវជ្រាវជម្ងឺឆ្លង។ ប្រធាននៃវិជ្ជាស្ថាននេះ គឺ លោកបណ្ឌិត *គីតាហ្សាតូ ស៊ីបាសាប៊ឺរ៉ូ* ដែលបានទៅ សិក្សានៅប្រទេសអាល្លឺម៉ង់ ហើយដែលជាអ្នកសិក្សាស្រាវជ្រាវដ៏សំបើមម្នាក់។

និស្សិតដែលសិក្សាស្រាវជ្រាវនៅវិជ្ជាស្ថាននេះ សុទ្ធសឹងតែជានិស្សិតដែលចេញពីមហាវិទ្យាល័យ ហើយកម្រមានអ្នកដែលមិនបានចេញពីសាលាពេទ្យដូច *សេសាគី* ដូច្នេះណាស់។ ដោយហេតុនេះហើយ ទើបបានជានៅពេលដំបូង *សេសាគី* មិនចេះរបៀបរបបគេ ហើយនៅពេលធ្វើការពិសោធន៍ជាលើកដំបូង គេបានធ្វើសំណូមពរទៅអ្នកទទួលបន្ទុកថា :

-ខ្ញុំចង់បានកណ្តុរសំរាប់ធ្វើពិសោធន៏១៣ តើអាចរកឱ្យខ្ញុំបានទេ?

ពួកអ្នកទទួលបន្ទុកឮបែបនេះ ក៏នាំគ្នាបើកភ្នែកធំៗឆ្លើយតបថា :

-ម្ចាស់ថ្លៃ ! ឱ្យរកកណ្តុរ១៣? នរណាគេដែលប្រើកណ្តុរខ្ជះខ្ជាយអញ្ចឹង?



ភ្នំបាន់ដៃ ខាងមុខគឺសាលាបឋមសិក្សា អ៊ីណាវ៉ាស៊ីរ៉ូសព្វថ្ងៃនេះ

នៅក្នុងចិត្តរបស់ *សេសាគី* កំសួលនៃចំណង់ទៅលើការស្រាវជ្រាវកំពុងតែមានសន្ទុះខ្លាំង ហាក់ដូចជាអណ្តាតភ្លើង

ដែលកំពុងតែត្រូវខ្យល់ ហើយឆាបឆេះសន្ធោសន្ធៅឥតឈប់ បែបនោះឯង។ គេចង់ធ្វើនេះ ចង់ធ្វើនោះ ជួនកាលដល់តែធ្វើអ្វីក៏មិនកើត ក៏ទៅជាតប់ប្រមល់ពេញមួយថ្ងៃក៏មាន។

វិជ្ជាស្ថាននេះហាក់ដូចជាពុំសូវអាចឆ្លើយតបទៅលើកំសួលទឹកចិត្តពុះកញ្ជ្រោលរបស់ *សេសាគី* ឱ្យចំបានទេ។

នៅវេលានោះ *សេសាគី* បានដំណឹងមកថា ភរិយារបស់លោកគ្រូ *កុបាយ៉ាស៊ុ* មានជម្ងឺជាទម្ងន់។ យុវជនបានប្រញិបប្រញាប់ផ្ញើថ្នាំថ្មីៗ ព្រមទាំងពន្យល់ពីរបៀបព្យាបាលជាដើមទៅជូនលោកគ្រូ ប៉ុន្តែជម្ងឺនោះពុំបានសះស្បើយសោះឡើយ ផ្ទុយទៅវិញ រឹតតែឡើងធ្ងន់ឡើងៗ។*សេសាគី* ក៏រវៀសរវៃរៀបចំចេញដំណើរទៅ *អ៊ីណាវ៉ាស៊ីរ៉ូ* វិញយ៉ាងប្រញាប់។

-លោកគ្រូ តើលោកស្រីបានធូរខ្លះទេ?

-អរគុណ *សេសាគី* ដោយឯងចេះមកទាន់ពេលវេលា។ មីងឯងប្រហែលជាមិនរស់ទេ។

-កុំមានប្រសាសន៍បែបនេះ លោកគ្រូ។ បើលោកគ្រូអស់សង្ឃឹម អ្វីៗក៏នឹងទៅជាអាក្រក់ សូមលោកគ្រូមានសង្ឃឹមឡើង។

*សេសាគី* បានខំទ្រាំថែជម្ងឺភរិយាលោកគ្រូ *កុបាយ៉ាស៊ី* ផង ធ្វើការនានានៅក្នុងផ្ទះផង ឥតទំរន់។ ដោយគុណបុណ្យនេះ ជម្ងឺរបស់ភរិយាលោកគ្រូដែលគ្មាននរណាម្នាក់សង្ឃឹមថានឹងអាចជាសះស្បើយ ក៏ចេះតែជារើបៗបន្តិចម្តងៗ ហើយអ្នកស្រីក៏អាចក្រោកឡើងពីទីដំណេកបាន។

ឆ្លៀតឱកាសដែលមានពេលទំនេរពីការថែទាំជម្ងឺភរិយាលោកគ្រូ *សេសាគី* បានទៅដើរលេងនៅជើងភ្នំ *បាន់ដៃ* ជាមួយនឹងមិត្តពីដើមៗ។ អ្នកទាំងឡាយនាំគ្នារំលឹកពីអនុស្សា-វរីយ៍នានា កាលពីគេទាំងឡាយនៅជាកុមារនៅឡើយ។

ថ្ងៃមួយ *សេសាគី* បានអានរឿងប្រលោមលោកមួយរបស់លោក *ឡូីប៊ូឌជី សូយោ* ដែលជាសៀវភៅដែលមាន

ឈ្មោះល្បីល្បាញជាខ្លាំង គឺរឿង *"ចរិតនៃនិស្សិតសម័យបច្ចុប្បន្ន"*។ តួឯកនៃរឿងឈ្មោះ *ណូណូង្វជី សេសាគី*។

-ចម្លែកដល់ហើយរ៉ឺយ អ្នកណាដែលឮឈ្មោះអ្វីក៏ដូចគ្នាម្ល៉េះ? មិនតែប៉ុណ្ណោះ កន្លែងអាក្រក់ទាំងប៉ុន្មានរបស់គ្នា ក៏រឹតតែដូចទៅទៀត អ្នកនិពន្ធនេះចំជាពូកែសរសេររកលេខដាក់គ្មាន ។

ទោះជាសាច់រឿងក្តី តួអង្គក្តី ជារបស់ស្រមៃប្រឌិតរបស់អ្នកនិពន្ធក្តី ក៏ *សេសាគី* មានការបារម្ភជាខ្លាំង គេក៏កើតមានចិត្តចង់ដូរឈ្មោះរបស់គេចេញនៅពេលនោះ ។

*សេសាគី* ក៏ទៅពិគ្រោះជាមួយនឹងលោកគ្រូ *កុបាយ៉ាស៊ិ* លោកគ្រូក៏មានប្រសាសន៍ថា ៖

-ល្អណាស់ *សេសាគី* ដោយចៅឯងចេះប្រៀបធៀបរូបខ្លួនឯង ទៅនឹងតួអង្គរបស់ *ណូណូង្វជី* ក្នុងរឿង ហើយប្រមើលឃើញគុណវិបត្តិរបស់ខ្លួនឯងបានច្បាស់យ៉ាងនេះ ។

-អញ្ចឹងហើយ បានជាខ្ញុំបាទចង់ប្តូរឈ្មោះ *សេសាគី* នេះចេញ លោកគ្រូ ។

-អញ្ចឹងឬ? គ្រូយល់ហើយ ។ ការប្តូរឈ្មោះ ហើយកែប្រែអ្វីៗឱ្យថ្មីស្រឡាងទាំងអស់ ដើម្បីចាប់ផ្តើមជីវភាពថ្មីមួយចាប់ពីសូន្យទៅបែបនេះ ក៏ល្អម្យ៉ាងដែរ ។

លោកគ្រូ *កុបាយ៉ាស៊ិ* បានដាក់ឈ្មោះថ្មីឱ្យ *សេសាគី* ថា " *ហ៊ីដេយោ* " ដែលបានន័យថា វិរបុរសនៃពិភពលោក ។ គួរឱ្យចម្លែកដែរ ដោយចុងបញ្ចប់ យុវជននេះបានក្លាយទៅជាវិរបុរសនៃពិភពលោក ដូចឈ្មោះរបស់គេមែន ។ ឈ្មោះនេះបានទៅជាកំណើតទី២ របស់យុវជននេះ ។



# ឯងគង់តែនឹងឃើញទេចាំមើលទៅ

បើគ្មានជំនាន់ដែលធ្វើការនៅវិជ្ជាស្ថានស្រាវជ្រាវជម្ងឺឆ្លងទេ ក៏ *ហ៊ិដេយោ* មិនមានគំនិតថានឹងធ្វើដំណើរទៅអាមេរិកដែរ ។

នៅខែមេសា ឆ្នាំ១៨៩៩ ជនជាតិអាមេរិកាំងម្នាក់ឈ្មោះ បណ្ឌិត *ហ្វីលេកស្នា* បានធ្វើដំណើរមកប្រទេសជប៉ុន ។ បណ្ឌិតនេះត្រូវធ្វើដំណើរទៅកាន់ប្រទេសហ្វីលីពីនឯនោះទេ ប៉ុន្តែបានជាមកអាស៊ីហើយក៏ឆ្លៀតចូលមកធ្វើទស្សនកិច្ចនៅវិជ្ជាស្ថានស្រាវជ្រាវជម្ងឺឆ្លងនៅជប៉ុន ។





ដោយសារ *ហ៊ីដេយោ* អាចនិយាយភាសាអង់គ្លេស និង អាល្លឺម៉ង់បាន គេបានទទួលភារកិច្ចជាអ្នកជូនលោកបណ្ឌិត ធ្វើទស្សនកិច្ច ។

នៅវេលាដែលទស្សនកិច្ចពេលថ្ងៃចប់ទៅ មានពិធីជប់ -លៀងស្វាគមន៍លោកបណ្ឌិត ។ *ហ៊ីដេយោ* បានគិតថាខ្លួន ឯង ដែលមានមុខងារជាអ្នកជូនលោកបណ្ឌិត ធ្វើទស្សនកិច្ច ក៏ច្បាស់ជានឹងអាចចូលទៅរួបរួមក្នុងពិធីជប់លៀងនោះដែរ ក៏ប៉ុន្តែផ្ទុយទៅវិញ គេមិនបានទទួលសេចក្តីអនុញ្ញាតិឱ្យចូល រួមទេ។ គេបានឱ្យ *ហ៊ីដេយោ* ទទួលទានបាយតែម្នាក់ឯង

នៅបន្ទប់ផ្សេងមួយ ។ នេះប្រហែលជាមកពីអ្នកកម្លោះនេះនៅក្មេង ហើយទើបនឹងចូលមកធ្វើការនៅវិជ្ជាស្ថាននេះថ្មីៗក៏មិនដឹង ។ ប៉ុន្តែ ការបែងចែកវណ្ណៈ ឋានៈបែបនេះ ធ្វើឱ្យ *ហ៊ីដេយោ* ដែលមានចរិតមិនចូលចិត្តចុះចាញ់ ទ្រាំមិនបានឡើយ ។

-ចាំមើលអញធ្វើឱ្យឃើញ ! ជាដាច់ខាត អញមិនចុះចាញ់ពួកឯងជាដាច់ខាត ។

ព្រលឹងមិនចេះរណបចុះចាញ់នរណារបស់ *ហ៊ីដេយោ* បានពុះពោរឡើង ។

នៅថ្ងៃបន្ទាប់ *ហ៊ីដេយោ* ត្រូវជូនដំណើរលោកបណ្ឌិតធ្វើទស្សនកិច្ចទីក្រុងតូក្យូ ។ *ហ៊ីដេយោ* បានប្រមូលអស់នូវសេចក្តីក្លាហាន ទំលាយសេចក្តីបំណងរបស់ខ្លួន ជំរាបលោកបណ្ឌិត :



-នៅអនាគតកាល ខ្ញុំបាទមានបំណងថានឹងទៅស្រុកអាមេរិក ដើម្បីរៀនវិជ្ជាពេទ្យដែលល្អតលាស់មិនឱ្យខានទេ តើយ៉ាងម៉េចដែរលោកបណ្ឌិត?

ដោយ *ហ៊ីដេយោ* បានចំណាយកម្លាំងជូនលោកដើរធ្វើទស្សនកិច្ច លោកបណ្ឌិតក៏បានឆ្លើយតបដោយទឹកចិត្តប្រកបទៅដោយអំណរគុណថា :

-ប្រសើរណាស់ ។ នៅពេលដែលអ្នកមក ខ្ញុំនឹងជួយទៅតាមកំឡាំងដែលអាចធ្វើទៅបាន ។

លោកបណ្ឌិតបានគិតថាការមកអាមេរិកមិនមែនជាការងាយស្រួលដូចការនិយាយឡើយ ។ ដូច្នេះលោកក៏ឆ្លើយស្រួលយ៉ាងនេះ មិនដឹងឯណាថា *ហ៊ីដេយោ* នឹងមកមែនឡើយ ។ ប៉ុន្តែពាក្យដែលធ្លាយចេញពីមាត់លោកបណ្ឌិតនេះ ជាឈ្នាន់មួយសំរាប់ឱ្យ *ហ៊ីដេយោ* ក្លាយទៅជាមនុស្សនៃពិភពលោក ។

កាលពីមុន លោកគ្រូពេទ្យ *ជីវ៉ាគី* បានបបួលរូបគេឱ្យមកតូក្យូ ហើយលើកនេះលោកបណ្ឌិត *ហ្វីលេកស្នា* បានមាន

ប្រសាសន៍ថា ប្រសិនបើ *ហ៊ីដេយោ* មកអាមេរិក លោកនឹងជួយជ្រោមជ្រែង។ *ហ៊ីដេយោ* ហាក់ដូចជាមានកម្លាំងសំរាប់ញាក់មនុស្ស ឬក៏នៅពេលដែលមានកូនព្រួងសំណាងអ្វីមួយពន្លយក្បាលចេញតែបន្តិចមក យុវជននេះតែងតែយកដៃទៅចាប់ទាញ មិនលែងសំណាងនោះឱ្យលិបចូលទៅវិញបានជាដាច់ខាត។

តាំងពីពេលដែលបានជួបបណ្ឌិត *ហ៊ីលេកស្នា* មក ចិត្តបំណងថានឹងទៅរៀននៅអាមេរិករបស់ *ហ៊ីដេយោ* កាន់តែរីកធំទៅៗ ជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ នៅពេលនោះដោយសារលោកបណ្ឌិត *គីតាសាតូ* ជួយ *ហ៊ីដេយោ* ក៏បានចូលទៅធ្វើការងារនៅឯកំពង់ផែ ដើម្បីពិនិត្យកប៉ាល់ កុំឱ្យជម្ងឺឆ្លង ចូលមកជប៉ុនបាន។

ដើម្បីនឹងទៅស្រុក អាមេរិក នៅជំនាន់នោះគេតោងតែមានប្រាក់ប្រហែលជា៣០០យ៉េន។ នៅវិជ្ជាស្ថានស្រាវជ្រាវប្រាក់បៀវត្សរ៍ដែល *ហ៊ីដេយោ* បានទទួលមួយខែមានតែ១៥

យ៉េនទេ ប៉ុន្តែនៅកន្លែងធ្វើការថ្មីនេះ គេបានទទួលមួយខែប្រហែលជា៣៥យ៉េន។

បើខំប្រឹងតែបន្តិច គេអាចសន្សំលុយសំរាប់ធ្វើដំណើរទៅបាន។ ក្នុងខណៈបែបនេះ នៅពេលនិយាយជាមួយនឹងកម្មករដែលធ្វើការនៅក្នុងកប៉ាល់ក្តី ជាមួយនឹងភ្ញៀវក្តី *ហ៊ីដេយោ* តែងតែគិតថា "ឱអញអើយ! បើអាត្មាអញអាចជិះកប៉ាល់ដែលចេញថ្ងៃ១៦បារាំងនេះ អាត្មាអញក៏អាចនឹងឆ្លងមហាសមុទ្រប៉ាស៊ីហ្វិកដូចគេដូចឯងដែរ"។

ចំណង់ចិត្តដែលប៉ងថាទៅស្រុកអាមេរិក ក៏ចេះតែឡើងធំទៅៗជាលំដាប់។ *ហ៊ីដេយោ* គឺជាយុវជនម្នាក់ដែលមានគំនិតរឹងណាស់ នៅពេលដែលគេនឹកចង់ធ្វើអ្វីមួយហើយ គេតែងតែចង់ឱ្យបំណងនោះបានសំរេចដល់គោលដៅជានិច្ច។

ថ្ងៃមួយនៅពេលដែល *ហ៊ីដេយោ* កំពុងតែពិនិត្យកប៉ាល់ដែលមកពីអាមេរិក នៅក្នុងបន្ទប់កប៉ាល់ មានជនជាតិចិនម្នាក់កំពុងតែឈឺថ្ងូរយ៉ាងលំបាក។



នៅពេលដែលឃើញសភាពនោះភ្លាម *ហ៊ីដេយោ* ក៏ចាប់សង្ស័យថា នេះមិនលែងជាជម្ងឺប៉េស្តឡើយ។ ជម្ងឺប៉េស្ត ជាជម្ងឺដ៏គួរឱ្យខ្លាចពន់ពេកណាស់។ យុវជនក៏ចាប់ផ្តើមពិនិត្យយ៉ាងរួសរាន់ ហើយដូចតែបានស្មានមែន អ្នកជម្ងឺមានជម្ងឺប៉េស្ត។

ការរកឃើញអ្នកមានជម្ងឺប៉េស្ត បានធ្វើឱ្យមនុស្សជាច្រើនមានការភ្ញាក់ផ្អើល ហើយកេរ្តិ៍ឈ្មោះរបស់ *ហ៊ីដេយោ* បាន

ឡើងរន្ទឺល្បីល្បាញភ្លាមមួយរំពេច។ ប៉ុន្តែ *ហ៊ីដេយោ* មិនគ្រប់គ្រាន់នឹងកេរ្តិ៍ ឈ្មោះប៉ុន្មាននេះទេ។

នៅសម័យនោះ នៅប្រទេសចិន ជម្ងឺប៉េស្តបានឆ្លងរាលដាលជាខ្លាំង។ ដោយសារតែប៉េស្តជាជម្ងឺសាហាវ បើជម្ងឺនេះរាលដាលកាន់តែធំទៅ នឹងនាំឱ្យមានគ្រោះធំ។ មានស្រុកជាច្រើនបានបញ្ជូនវេជ្ជបណ្ឌិតឱ្យទៅស្រុកចិន។

ក្នុងចំណោមវេជ្ជបណ្ឌិត១៥នាក់ ដែលគេបញ្ជូនពីជប៉ុនទៅ មានឈ្មោះ *ហ៊ីដេយោ* ម្នាក់ដែរ។

នៅដំណើរនេះ រដ្ឋចេញថ្លៃដំណើរឱ្យមែន ក៏ប៉ុន្តែ ដោយ *ហ៊ីដេយោ* ជំពាក់លុយគេច្រើន ហើយតោងតែសងគេ នៅនឹងដៃ ក៏គ្មានសល់សូម្បីតែមួយសេនក៏គ្មាន។ *ហ៊ីដេយោ* ជាយុវជនដែលមិនសូវចេះរបៀបចាយវាយលុយទេ។ នៅពេលដែលទ័លលុយម្តងៗ គេតែងតែទៅរកខ្ចីបុលពីអ្នកនេះពីអ្នកនោះ។ នៅពេលដែលឮថា *ហ៊ីដេយោ* ជិតចេញទៅបរទេស ពួកម្ចាស់បំណុលនាំគ្នាមករកស្រតែម្តង។

នៅពេលដែលគ្មានលុយមួយសេន នៅក្នុងខ្លួនបែបនេះ *ហ៊ីដេយោ* ក៏តាំងរត់ទៅរកលោកគ្រូពេទ្យ *ជីវ៉ាគី* ទៀត ។

-សូមលោកគ្រូមេត្តាអភ័យទោស ។ សូមមេត្តាឱ្យខ្ញុំបាទខ្ចី ម្តងទៀតយកតែបុណ្យទៅចុះ លោកគ្រូ ។

-ពិបាកមែនតែម្តង ។ ក្មាឯនេះក៏ទើបតែនឹងរៀបការថ្មីថ្មោង គ្មានលុយនៅជាប់នឹងខ្លួន ។

-បាទ ត្រូវហើយលោកគ្រូ ។ ខ្ញុំបាទក៏ដឹងដែរ ។

-កុំអាលមើល ចាំបន្តិច !

លោកគ្រូ *ជីវ៉ាគី* បានយកអាវគីម៉ូណូរបស់ភរិយា ដែលទើបនឹងរៀបការថ្មីថ្មោងទៅលក់បាន១៥យ៉េន យកមកហុចឱ្យ *ហ៊ីដេយោ*។ ទោះជា *ហ៊ីដេយោ* ដែលមិនសូវចេះខ្លាចចិត្តមនុស្ស ក៏ទៅជាញ៉ាក ហើយទទួលយកលុយតែ៥យ៉េន រួចសង១០យ៉េនទៅជូនលោកគ្រូវិញ ទោះបីជាខ្លួនត្រូវការទាំងអស់ក្តី ។

លោកគ្រូ *ជីវ៉ាគី* ឃើញរូបរាង *ហ៊ីដេយោ* ដែលរខេក រខាក ក៏អាណិតជាខ្លាំង ។ ចូលដល់ពាក់កណ្ដាលខែតុលាទៅហើយ អ្នកកម្លោះនេះនៅតែស្លៀកពាក់ខោអាវខែក្ដៅ ខ្ទក់ខ្ទិខ្ទុក មើលតែព្រានព្រៃ ។ លោកគ្រូក៏យកផ្ទួយពណ៌ក្រហមដែលនៅក្បែរដៃ ហុចទៅឱ្យ ។

*ហ៊ីដេយោ* អត់ទ្រាំនឹងទឹកចិត្តដ៏ល្អនេះលែងបាន ក៏យំសសឹកបណ្ដើរ ដើរសំដៅទៅផែ*កូបេ* បណ្ដើរ ។

ចុងបញ្ចប់ *ហ៊ីដេយោ* ក៏បានឡើងកប៉ាល់ដែលបើកសំដៅទៅស្រុកចិន ទាំងយ៉ាប់យ៉ឺន ។ នៅក្នុងកប៉ាល់ វេជ្ជបណ្ឌិត



ទាំងឡាយ នាំគ្នាដកវចនានុក្រមមករៀនភាសាចិនគ្រប់ៗគ្នា។ ប៉ុន្តែ *ហ៊ីដេយោ* មិនធ្វើបែបនេះទេ។ គេចុះទៅបាតកប៉ាល់តែឯង ទៅនិយាយជាមួយនឹងកម្មករចិនដែលធ្វើការនៅទីនោះ។

នៅពេលដែលបានទៅដល់ស្រុកចិន អ្នកឯទៀតៗនិយាយចិនមិនបានពូកែទេ ប៉ុន្តែ *ហ៊ីដេយោ* និយាយចិនបានច្រើន។ ជនជាតិជប៉ុនគ្នាឯងក្តី ជនជាតិចិនក្តី ក៏ចូលចិត្ត ទុកចិត្តលើ *ហ៊ីដេយោ* ពឹងពាក់អ្វីៗលើយុវជននេះទាំងអស់។ *ហ៊ីដេយោ* តែងតែធ្វើអ្វីដែលអ្នកឯទៀតមិនសូវនឹកនាដល់។



ជម្ងឺប៉េស្ត បានចុះអន់ថយ លែងសូវរាលដាលដូចមុនទៀតហើយ ។ ប៉ុន្តែអ្នកជម្ងឺនៅតែមកពេទ្យឱ្យគ្រូពេទ្យពិនិត្យពីគ្រប់ទីតំបន់ទាំងឡាយក្នុងប្រទេស ។ ដូច្នេះ ទោះបីជាគ្រូពេទ្យឯទៀតត្រឡប់ទៅស្រុកជប៉ុនវិញក្តី ក៏ចិនសុំឱ្យ *ហ៊ីដេយោ* នៅបន្តជួយមើលអ្នកជម្ងឺជាបន្តទៅមុខទៀត ជាមួយនឹងគ្រូពេទ្យបរទេសឯទៀតៗ ។

ប្រាក់ខែរបស់គេច្រើនគួរសមដែរ ប៉ុន្តែដោយយុវជននេះចាយលុយមិនសូវគិត គេមិនអាចសន្សំលុយបានទាល់តែសោះ ។

ពេលដែលគេកំពុងតែធ្វើការនៅស្រុកចិននោះ សង្គ្រាមក៏ផ្ទុះឡើង ហើយ *ហ៊ីដេយោ* ពោងតែត្រឡប់មកស្រុកជប៉ុនវិញ ។ គេមានសំណាងបានចេញទៅដល់ស្រុកចិនទៅហើយ ប៉ុន្តែមិនអាចសន្សំលុយសំរាប់បន្តដំណើរ ឱ្យបានទៅដល់ស្រុកអាមេរិកបាន ។



# ការចេញដំណើរទៅស្រុកអាមេរិក

លុះត្រឡប់មកដល់ជប៉ុនវិញ *ហ៊ីដេយោ* បានចូល ទៅធ្វើការនៅសាលារបស់លោកគ្រូពេទ្យ *ជីវ៉ាតី* មួយរយៈ។ ក៏ប៉ុន្តែចិត្តចង់ទៅអាមេរិកនៅតែមិនរលុប។ ទ្រាំលែងបាន *ហ៊ីដេយោ* ក៏គិតរកខ្ចីលុយពីមិត្តម្នាក់ឈ្មោះ *យ៉ាជី យ៉ាស៊ុហេ* ដែល ជាមិត្តធ្លាប់រៀននៅវិទ្យាល័យជាមួយគ្នា ចំនួន ៥០០ យ៉េន។ *ហ៊ីដេយោ* បានពិគ្រោះរឿងនេះជាមួយលោកគ្រូ *កុបាយ៉ាស៊ី* ៗ ក៏ស្តីឱ្យគេថា ៖

-កូនប្រុសដើមទ្រូងប្រាំហត្ថមិនត្រូវរំពឹងលើអ្នកដទៃទេត្រូវរក លុយទៅដោយខ្លួនឯងទៅមើល កុំកំស៊ិចពេក។

ចុងបញ្ចប់ រកឯណាមិនបាន១ ក៏ទៅរំពឹងលើលោកគ្រូពេទ្យ *ជីរ៉ាគី* ដដែលជាដដែល។ លោកគ្រូពេទ្យបានខិតខំរកលុយពីនេះពីនោះទំរាំបានមកឱ្យ *ហ៊ីដេយោ* ទៅអាមេរិក។

ពេលវេលាចេញដំណើរកាន់តែខិតចូលមកជិតហើយ។ *ហ៊ីដេយោ* ចេញដំណើរទៅស្រុកកំណើត ដើម្បីលាមាតា និងលោកគ្រូ *កុបាយ៉ាស៊ី*។ ពេលបានជួបមាតា ដែលមានអាយុច្រើនហើយ *ហ៊ីដេយោ* ហាក់ដូចជារារែក លែងចង់ចេញដំណើរ ហើយគិតវិលមកធ្វើពេទ្យឯស្រុកវិញ។ ប៉ុន្តែលោកគ្រូ *កុបាយ៉ាស៊ី* បានលើកទឹកចិត្តគេថា ៈ

-កុំបារម្ភពីម្ដាយឯងឱ្យសោះ ចាំគ្រូជួយមើលឱ្យ។ នេះលុយនេះមីងឯងគេត្បាញសំពត់លក់បាន ចូរឯងយកទៅជាមួយគ្រាន់ចាយវាយពេលខ្វះខាតចុះ។ គ្រូឱ្យឯងជាចំណងដៃ។

ថាហើយ លោកគ្រូក៏ហុចលុយចំនួន ២០០យ៉េន ឱ្យទៅ *ហ៊ីដេយោ*។



-សូមអរគុណលោកគ្រូ។ គុណរបស់លោកគ្រូ ខ្ញុំបាទមិនអាចភ្លេចបានទេក្នុងមួយជីវិតនេះ។ សូមលោកគ្រូមេត្តាអនុញ្ញាតឱ្យខ្ញុំបាទហៅលោកគ្រូ និងលោកស្រី ថា លោកឪពុក លោកម្ដាយ ណា៎ !

-គ្រូអរណាស់ ដោយឯងគិតគ្រូដល់ថ្នាក់នេះ។ គ្រូមិនដែលគិតថាឯងជាអ្នកដទៃដល់ម្ដងទេ។ ចូរទៅរៀនឱ្យបានជោគជ័យណា៎។

លុះផ្ដាំផ្ញើទុកដាក់អ្វីៗនឹងលោកគ្រូ *កុបាយ៉ាស៊ី* ហើយយុវជនក៏ចេញដំណើរទៅប្រទេសអាមេរិក។

ថ្ងៃទី៥ ខែ១២ ឆ្នាំ១៩០០។ ថ្ងៃនោះមេឃស្រឡះគ្មានពពកមួយគ្រាប់។ និស្សិតទាំងឡាយដែលរៀននៅសាលាលោកគ្រូពេទ្យ *ជីវ៉ាគី* បានទៅចាំជូនដំណើរ *ហ៊ីដេយោ* នៅស្ថានីយ *ស៊ីមបាស៊ី*។

-ជយោ ! ជយោ !

និស្សិត១នាំគ្នាគ្រវីដៃលា *ហ៊ីដេយោ* រហូតទាល់តែរថភ្លើងទៅផុតមើលលែងឃើញ។ លោកគ្រូពេទ្យ *ជីវ៉ាគី* បានមកជូនដំណើរ *ហ៊ីដេយោ* រហូតដល់ផែកប៉ាល់ *យោកូហាម៉ា* ។ នៅពេលដែលកប៉ាល់ហៀបនឹងចេញទៅ លោកគ្រូក៏មានប្រសាសន៍ផ្ដាំជាចុងក្រោយថា ៖

-ពីថ្ងៃនេះតទៅ ឯងតោងតែរំពឹងលើខ្លួនឯងតែម្នាក់ហើយ ។ ឯងមើលសត្វសីង្ហ ដែលជាស្ដេចនៃសព្វសត្វទាំងឡាយមើល វាទំលាក់កូនដែលកើតបានបីថ្ងៃទៅក្នុងជ្រោះជ្រៅ ដើម្បីឱ្យកូននោះខំប្រវាឡើងមកដោយកំឡាំងខ្លួនឯង។ ឥឡូវនេះឯងកំពុងតែត្រូវម៉ែឪច្រានទម្លាក់ទៅក្នុងជ្រោះដ៏ជ្រៅហើយ ចូរឯងខំបញ្ចេញកម្លាំងទាំងអស់ ដើម្បីឱ្យអាចឡើងមកលើច្រាំង វិញបាន ដោយជោគជ័យ ។ ឮឬទៅ?

នៅក្នុងសមុទ្រ នៅវេលាដែលមើលភ្នំ *ហ្វ៊ូជី* លែងឃើញទៀតទៅ ព្យុះដ៏ធំក៏បក់មក។ ព្យុះនោះមានរយៈពេលបីយប់បីថ្ងៃ។ អ្នកឯទៀតគេពុលកប៉ាល់គ្រប់គ្នា អត់តែ *ហ៊ីដេយោ*

ម្នាក់។ អ្នកកម្លោះអង្គុយអានរឿងរបស់អ្នកនិពន្ធអង់គ្លេសឈ្មោះ *សេកស្ព្យែរ* គឺរឿង "*អ្នកជំនួញនៅវេនីស*" ធ្វើវាហី។ ថ្ងៃទី២២ ខែធ្នូ កប៉ាល់បានចូលទៅដល់ទ្វាចូលខាងលិចនៃប្រទេសអាមេរិក គឺទីក្រុង*សាន់ហ្វ្រាន់ស៊ីស្កូ*។ ឯទីក្រុងដែលសាស្ត្រាចារ្យ *ហ្វីលេកស្នា* រស់នៅ គឺក្រុង*ហ្វីឡាដែលហ្វី* នៅឯចុងខាងកើតនៃប្រទេសអាមេរិកឯនោះ។ គេតោងតែជិះរទេះភ្លើងឆ្លងកាត់ទីដីនៃទ្វីបដ៏ធំទូលាយនេះ ចំនួន ៥ថ្ងៃ ទើបអាចទៅដល់ទីនោះ។




ផែនទីសហរដ្ឋអាមេរិក

រទេះភ្លើង ទាញដោយក្បាលរថភ្លើងដ៏ធំសំបើមអស្ចារ្យ ដែលគេមិនដែលឃើញនៅស្រុកជប៉ុនឡើយ ។ វាបោលឡើងភ្នំ កាត់តាមវាលរាបសំដៅទៅទិសខាងកើត ហើយចេះតែរត់ទៅមុខមិនឈប់ ។ *ហ៊ីដេយោ* មិនបានគយគន់មើលទេសភាពចំឡែកនៃប្រទេសទេ ខ្សែភ្នែកអ្នក ទំលាក់ទៅលើអក្សរនៅលើសៀវភៅឥតដក ។ តើអ្នកកម្លោះកំពុងតែគិតពីអ្វីទៅហ្ន៎?



លុះទៅដល់ *ហ៊ីឡាដែលហ៊ី* , *ហ៊ីដេយោ* ក៏ប្រញាប់ប្រញាប់ធ្វើដំណើរទៅរកបណ្ឌិត *ហ៊ីលោកស្មា*។ ដោយគេមិនបានសរសេរសំបុត្រមកជំរាបលោកជាមុន លោកបណ្ឌិតមានការភ្ញាក់ផ្អើលជាខ្លាំង ។

-ខ្ញុំបាទមកហើយ ទានប្រោស ។ ខ្ញុំបាទនេះឈ្មោះ *ណូងូជី* ដែលបានជួបលោកបណ្ឌិតពីឆ្នាំមុន ។

-អូ *ណូងូជី* ។ កាលពីខ្ញុំទៅធ្វើទស្សនកិច្ចនៅជប៉ុន អ្នកបានជួយខ្ញុំច្រើនណាស់ សូមអរគុណ ។ អ្នកឯងសុខសប្បាយទេតើ ។ ខ្ញុំរីករាយណាស់ដោយបានជួបអ្នកជាថ្មីនេះ ។

-បាទ លោកបណ្ឌិត ។ ខ្ញុំបាទមកនេះ គឺមកសុំធ្វើការជាមួយលោកបណ្ឌិត ទោះជាក្នុងឋានៈជាអ្នកជំនួយការនៅក្នុងមហាវិទ្យាល័យ ក៏បានដែរ ទានប្រោស ។

-ក្មួយ *ណូងូជី* ឱ្យខ្ញុំសុំទោស មហាវិទ្យាល័យនេះ គេមិនទទួលជនបរទេសឱ្យធ្វើការទេ ។ គេមានវិន័យគេអញ្ចឹងមក ។



ក្មួយឯងមកប្រផ្ទុចញ៉ែចពេកអញ្ចឹង ខ្ញុំក៏គ្មានពេលគិត គ្មានគំនិតល្អនៅឡើយទេ។ ប៉ុន្តែចាំខ្ញុំជួយ សូមរង់ចាំបន្តិច។

មានប្រសាសន៍បែបនេះហើយ លោកបណ្ឌិតក៏ណែនាំឱ្យ *ហ៊ីដេយោ* ទៅសំណាក់នៅសណ្ឋាគារថោកមួយ។

ហ៊ីដេយោ អស់រំពឹង ខកចិត្ត ខ្សោះកំឡាំង។ នៅចុងឆ្នាំផង លុយក៏មិនសូវមាន ពិបាកចិត្តអស់យ៉ាង។

-អញអើយ ធ្វើម៉េចទៅ ? ខំទ្រាំលេបត្រួសលេបថ្ម ឬក៏អង្គុយស្ងៀមបែបនេះរង់ចាំវេលាស្លាប់ចូលមក?

*ហ៊ីដេយោ* តឹងទ្រូងស្ទើរតែនឹងប្រេះ ដាក់គូថអង្គុយប៉ុកទៅលើកាំជណ្ដើរនៃមហាវិទ្យាល័យ។

គិតយ៉ាងម៉េចក៏ រកច្រកចេញមិនឃើញ។ គេគិតថា លោក



ទីក្រុងហ្វីឡាដេលហ្វីយ៉ា

បណ្ឌិតនេះចំជាចិត្តអាក្រក់ ប៉ុន្តែលោកបណ្ឌិតក៏បានខំគិតពី *ហ៊ីដេយោ* ណាស់ដែរ មិនមែនលោកចិត្តអាក្រក់ទេ។ លោកបានខំគិតយ៉ាងយូរ។ ចុងបញ្ចប់ លោកក៏ហៅយុវជននេះឱ្យទៅជួបលោក។

-ក្មួយឯងដែលធ្វើការស្រាវជ្រាវអំពីពស់ទេ?

គ្រាន់តែឃើញ *ហ៊ីដេយោ* ភ្លាម លោកបណ្ឌិត ក៏សាកសួរមកភ្លាម។ *ហ៊ីដេយោ* មិនដែលស្រាវជ្រាវពីពស់ ទេ។ ប៉ុន្តែកាលពីគេធ្វើការនៅមន្ទីរស្រាវជ្រាវជម្ងឺឆ្លង គេដែលឃើញមិត្តគេស្រាវជ្រាវអំពីពស់ *តែវ៉ាន់* ដែលមានឈ្មោះថា *ហាប*។ *ហ៊ីដេយោ* ក៏ឆ្លើយទាំង លំបាកក្នុងចិត្តថា :

-ព្រះបាទ ដែល ទានប្រោស។

ទាំងគិតថាវាជាការមិនល្អទេ ដោយខ្លួនភូតភរលោក បែបនេះ។

-បើអញ្ជើង មក ជួយធ្វើការខ្ញុំ។

បើបានជាឆ្លើយបែបនេះហើយ *ហ៊ីដេយោ*ក៏បានក្លាយទៅជាអ្នកជំនួយការរបស់សាស្ត្រាចារ្យ ហើយមកដល់ដំណាក់កាលនេះ គេមិនអាចហាមាត់កែប្រែវិញថាធ្វើមិនបានទេ មានតែខិតខំឱ្យដើរទៅមុខតែប៉ុណ្ណោះ។ គេប្រមូលអស់នូវសេចក្តីក្លាហានទាំងប៉ុន្មាន ចូលទៅធ្វើការខាងការស្រាវជ្រាវពិសពស់ ដែលគេមិនចេះទាល់តែសោះ។

# ការស្រាវជ្រាវរកពិសពស់

លុះធ្វើការបានមួយខែមក លោកបណ្ឌិតក៏មានបេសកកម្ម ទៅធ្វើការនៅ*សាន់ហ្វ្រង់ស៊ីស្កូ*ចំនួន៣ខែ។ ក្នុងរយៈពេលដែលលោកមិននៅ លោកបណ្ឌិតបានណែនាំ*ហ៊ីដេយោ* ឱ្យស្គាល់លោកបណ្ឌិត *មីចឈែល* ដែលជាអ្នកឯកទេសខាងពិសពស់ ដើម្បីឱ្យលោកជួយមើលការខុសត្រូវ*ហ៊ីដេយោ*។



លោកបណ្ឌិត មីចឈែល

នៅយប់នៃថ្ងៃភ្លៀងដ៏រងាមួយ។ យុវជនជប៉ុនដ៏តូចទាប កាន់សំបុត្រណែនាំឱ្យស្គាល់ ពីលោកបណ្ឌិត*ហ្វីលេកស្នា*

ធ្វើដំណើរសំដៅទៅគេហដ្ឋានរបស់លោកបណ្ឌិត *មីចឡែល* ទាំងភ្លៀងសស្រិច ទទឹកជោក ។

នៅពេលដែលបានឃើញកែវភ្នែកខ្មៅថ្លា របស់យុវជន លោកបណ្ឌិត *មីចឡែល* បានគិតក្នុងចិត្តថា :

-យុវជននេះមិនមែនជាមនុស្សធម្មតាទេ ។

ពោលគឺ លោកបានមើលឃើញដល់ជំរៅនូវសមត្ថភាព របស់យុវជននេះ ។

ពីពេលនោះមក ការស្រាវជ្រាវដ៏ខ្លាំងក្លា គ្មានយប់គ្មានថ្ងៃរបស់ *ហ៊ីដេយោ* បានចាប់ផ្តើម ។ អ្នកណាក៏ដឹងដែរថា ពិសមួយកូនស្លាបព្រារបស់ពស់ អាចសំឡាប់មនុស្សបានលើស ពីមួយរយនាក់ ដូច្នេះ គឺជាការងារដ៏មានគ្រោះថ្នាក់ជាទី បំផុត ។ ត្រូវឱ្យម្នាក់យកខ្សែដែលធ្វើពីស្បែក វ៉ៃនទាក់ កពស់ ហើយចាប់ក្បាលវាទប់ឱ្យជាប់សិន ពេលនោះទើប ហ៊ីដេយោ បើកមាត់ពស់ឆ្កាង ហើយដាក់វាឱ្យខាំផ្ទាំងកញ្ចក់ មួយផ្ទាំង ទើបច្របាច់ខ្នាស់សរសៃដែលបញ្ចេញពិស រួចក៏

ច្បួតីរីតយក ពិសចេញ ។ គេយកពិសពស់នោះទៅចាក់ឱ្យសត្វនានា ដើម្បីស្រាវជ្រាវរកថ្នាំការពារពិសពស់ ។ *ហ៊ីដេយោ* ត្រូវទៅបណ្ណាល័យអានសៀវភៅ រួចហើយត្រូវទៅបន្ទប់ពិសោធន៍ធ្វើការស្រាវជ្រាវបន្តរហូត ។ រួចហើយតោងកត់ជាកំណត់នៅក្នុងសៀវភៅសរសេរ ។ ធ្វើបែបនេះប្រហែលជាបីខែ *ហ៊ីដេយោ* ក៏ធ្វើ កំណត់ហេតុបានប្រហែលជា២៥០ទំព័រ ។ បណ្ឌិត *ហ្វីលេកស្នា*ក្តី បណ្ឌិត *មីចឈែលល*ក្តី មានការភ្ញាក់ផ្អើលចំពោះការខិតខំស្រាវជ្រាវរបស់យុវជននេះណាស់ ។

នៅចន្លោះការស្រាវជ្រាវឥតឈប់ឈរនេះ រដូវរងាបានចូលមកជាថ្មីទៀត មិនដឹងជាពីអង្កាល់ណា ។ មកដល់ស្រុកអាមេរិកមិនទាន់ទាំងបានមួយឆ្នាំស្រួលបួលផង ឈ្មោះជនជាតិជប៉ុន *ណូហ្គូជី ហ៊ីដេយោ* ដែលស្រាវជ្រាវអំពីពិសពស់លេចឮរន្ទឺពេញស្រុកអាមេរិកបាត់ទៅហើយ ។

ការស្រាវជ្រាវនេះ មានឈ្មោះថា ការស្រាវជ្រាវរួម

*ហ៊ីលេកស្មា មីចឈែល ណូង្វដី*។ គេត្រូវផ្សាយ នៅឱកាសប្រជុំវេជ្ជបណ្ឌិតល្បីៗមួយ ឱ្យគេឯទៀតៗបានដឹងដែរ។ លោកបណ្ឌិត *ហ៊ីលេកស្មា* ជាអ្នកនិយាយពន្យល់ ហើយ *ហ៊ុដេយោ* ជាអ្នកធ្វើការពិសោធន៍នៅមុខគេ ឱ្យគេឯងបានឃើញជាក់ស្តែង។

នៅវេលាយប់នោះមានពិធីជប់លៀងដ៏ធំមួយ។ *ហ៊ុដេយោ* បាននៅអង្គុយជជែកពិភាក្សាគ្នាជាមួយនឹងគេ និងឯង ក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវជាតិអាមេរិកាំង ដ៏ល្បីល្បាញទាំងឡាយ។

អ្នកកម្លោះបានរំលឹកឃើញពេលដែលគេឱ្យខ្លួនទទួលទានបាយតែឯកឯងនៅបន្ទប់មួយផ្សេង នៅពេលដែលបណ្ឌិត *ហ៊ីលេកស្មា* អញ្ជើញមកជប៉ុន។

នៅអាយុ ២០ឆ្នាំ គេចេញមកតូក្យូ។

អាយុ ២១ឆ្នាំ ប្រឡងជាប់បានសញ្ញាប័ត្រវេជ្ជបណ្ឌិត

អាយុ ២២ឆ្នាំ ចូលធ្វើការនៅវិជ្ជាស្ថានស្រាវជ្រាវជម្ងឺឆ្លង



អាយុ ២៣ឆ្នាំ ទៅស្រុកចិន

អាយុ ២៤ឆ្នាំ ទៅស្រុកអាមេរិក

អាយុ ២៥ឆ្នាំ ចងក្រងសៀវភៅដែលស្រាវជ្រាវពីពិសពស់

បើយើងមើលទៅ ការងាររបស់យុវជននេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ យើងឃើញច្បាស់ថា គឺជាការងារប្រសើរគួរឱ្យសរសើរ។ *ហ៊ីដេយោ* ដែលរៀនសូត្រជានិច្ចជាកាលគ្មានពេលសំរាក ហើយដែលស្តាយពេលវេលាសូម្បីតែមួយវិនាទីក្តី មួយនាទីក្តីបែបនេះ ធ្វើឱ្យមនុស្សនានាមានការចាប់អារម្មណ៍មកលើគេជាខ្លាំង។

ពេលខ្លះមានមិត្តភក្តិមកបបួលទៅដើរលេង ៖

គេជានិច្ច។ ជីវភាពស្រាវជ្រាវប្រចាំថ្ងៃរបស់ *ហ៊ិដេយោ* ប្រព្រឹត្តទៅបែបនេះឯង។

យប់យន់កាន់តែជ្រៅស្ងាត់ច្រៀប។ គ្មានសំឡេងអ្វីមួយបន្លឺឡើងទៀតទេ។ នៅក្នុងភាពស្ងប់ស្ងាត់នេះ *ហ៊ិដេយោ* គូសវាសគម្រោងការនៃការស្រាវជ្រាវនៅក្នុងអារម្មណ៍ រួចហើយទើបកត់ទុកជាកំណត់ រួចទើបយកប៊ិចក្រហមកែពីលើ ឬសរសេរបន្ថែម នៅពេលដែលនឹកឃើញគំនិតថ្មី។ ដូច្នេះទៅ ជាធម្មតា *ហ៊ិដេយោ*ចូលដំណេកនៅម៉ោង ២កន្លះទៅម៉ោង ៥ភ្លឺ។

ប៉ុន្តែធ្វើអ្វីក៏ដោយ ក៏មិនដែលចេះតែស្រួលរហូតដែរ។ ពេលដែលសប្បាយក៏មាន ពេលដែលពិបាកចិត្តអស្ចារ្យក៏មាន។

-តើនៅពេលដែលការស្រាវជ្រាវពិសពស់នេះចប់ទៅ តើអាត្មាអញទៅធ្វើអ្វីទៅ? ការមានជោគជ័យត្រឹមប៉ុន្មានេះទៅជប៉ុនវិញក៏គ្មាននរណាគេភ្ញាក់គេផ្អើលដែរ។ បំណាច់នឹង

បានមកដល់ស្រុកអាមេរិកហើយ តោងតែរកធ្វើអ្វីមួយឱ្យសឿងបឿងទើបបាន ។ តើត្រូវធ្វើអ្វីទៅលោក?

នៅពេលដែលការលំបាកក្នុងចិត្ត មានទំហំកាន់តែធំទៅៗ បញ្ហាចក្ខុរបស់ *ហ៊ីដេយោ* ក៏កាន់តែបើកធំឡើងៗជាលំដាប់ ។ ចិត្តលំបាករបស់យុវជននេះ នៅវេលានោះមានសរសេរនៅក្នុងសំបុត្រដែលអ្នកកម្លោះផ្ញើទៅលោកគ្រូ *កុបាយ៉ាស៊ី* និងលោកគ្រូពេទ្យ *ជីវ៉ាគី* ។

"ខ្លួនខ្ញុំបាទជាកូនអ្នកស្រែចំការ ហើយត្រូវបានលោកគ្រូរកឃើញចំណុចល្អរបស់ខ្លួនឱ្យ ហើយទាញចំណុច នោះពន្លូតវែងមកបានប៉ុននេះ ។ មកដល់ស្រុកអាមេរិកនេះ ខ្ញុំបាទមានឱកាសនឹងធ្វើការស្រាវជ្រាវបន្ត ហើយអាចចិញ្ចឹមសេចក្តីសង្ឃឹមឱ្យមានទំហំកាន់តែធំឡើងៗទៀតផង ។ ខ្ញុំបាទតែងតែចងចាំសាលារៀន *អ៊ីណាវ៉ាស៊ីរ៉* ទុកនៅក្នុងដួងចិត្ត ហើយគិតថា សាលានេះធំជាងមហាវិទ្យាល័យនៅតូក្យូ

ហើយតែងតែគិតថា លោកគ្រូ*កុបាយ៉ាស៊ី* ប្រសើរខ្ពង់ខ្ពស់ជាងសាស្ត្រាចារ្យនៅមហាវិទ្យាល័យនានាណាទាំងអស់។"

"មុនពេលចេញដំណើរមកទីនេះ ខ្ញុំបាទតែងតែគិតខុសថា អ្នកដែលមានជោគជ័យនៅក្នុងជីវិតសុទ្ធសឹងតែជាមនុស្សល្អប្រសើរ ហើយខ្ញុំបាទតែងតែប៉ងប្រាថ្នាចង់ឱ្យខ្លួនឯងបានជោគជ័យ បានធ្វើការធំដុំ។ លុះមកដល់ស្រុកអាមេរិកនេះបានជួបបានស្គាល់មនុស្សនានា បានក្រេបជញ្ជក់នូវសេចក្ដីជូរចត់ក្នុងជីវិត ទើបត្រាស់ដឹងថា មនុស្សយើងបើមានតែកំឡាំងប្រាជ្ញាទទេ មិនអាចហៅថាជាមនុស្សប្រសើរបានទេ មិនខុសពីគ្រឿងយន្តដែលគ្មានព្រលឹងបែបនោះឯង។ ឥឡូវនេះខ្ញុំបាទបានដឹងច្បាស់ហើយថា តម្លៃមនុស្សមិនមែនស្ថិតនៅលើខួរក្បាលប៉ុន្មានទេ គឺស្ថិតនៅលើចរិតបុគ្គលិកលក្ខណៈដ៏ប្រសើររបស់បុគ្គលនោះ។"

ដោយសារតែការខិតខំប្រឹងប្រែងស្រាវជ្រាវដ៏ស្វិតស្វាញរបស់*ហ៊ីដេយោ* និងបុគ្គលិកលក្ខណៈដ៏ប្រសើរនៃអ្នកកម្លោះ

ការបិទទ្វារជិត មិនទទួលយកជនបរទេសឱ្យធ្វើការនៅក្នុង មហាវិទ្យាល័យ បានត្រូវកែប្រែហើយ គេក៏ទទួលយក *ហ៊ីដេយោ* ឱ្យធ្វើជាអ្នកជំនួយការងារពីពេលនោះទៅ ។ មិនត្រឹមតែប៉ុណ្ណោះទេ សុបិននិមិត្តដែលប៉ុនប៉ងជាយូរមកហើយ ថាចង់ទៅរៀនសូត្រនៅអឺរ៉ុប ក៏បានក្លាយទៅជាការពិតដែរ ។

# ការទៅសិក្សានៅអឺរ៉ុប



បណ្ឌិតគីតាសាតូ

តាំងពីពេល នៅស្រុកជប៉ុនម្ល៉េះ *ហ៊ីដេយោ* តែងតែមានបំណងចង់ទៅរៀននៅប្រទេសអាល្លឺម៉ង់។ លោកសាស្ត្រាចារ្យ *គីតាសាតូ* ដែលជាប្រធាននៃវិជ្ជាស្ថានស្រាវជ្រាវជម្ងឺឆ្លង ក៏ធ្លាប់មានប្រសាសន៍ដែរថា បើ *ហ៊ីដេយោ*ខំប្រឹងធ្វើការស្រាវជ្រាវ លោកនឹងបញ្ជូនយុវជននេះទៅរៀន។ ពេលនេះ សុបិននិមិត្តនោះបានក្លាយទៅជាការពិតហើយ។ *ហ៊ីដេយោ* បានឈានជើង ទៅជាន់ដីនៃទ្វីបអឺរ៉ុបជាលើកដំបូងបង្អស់នៅឆ្នាំ ១៩០៣។ ដោយសារតែការស្រាវជ្រាវមិនមានទំនាក់ទំនងនឹងប្រទេសអាល្លឺម៉ង់

*ហ៊ីដេយោ* គោងតែធ្វើដំណើរទៅក្រុង *កូពេនហាហ្គែន* នៃប្រទេស *ដាណឺម៉ាក*។ ទៅដល់ភ្លាម គេបានទៅគោរព លោកបណ្ឌិត *ម៉ាតស៊ិន* ជាបន្ទាន់ ។

-ឱ ! អ្នកឯងនេះហើយឬ ឈ្មោះ*ណូហ្គូជី* នោះ? ខ្ញុំឮតែ *ណូហ្គូជី* គិតស្មានតែជនជាតិអាមេរិក ។ មិនមែនអាមេរិកទេឬ?

-បាទ ខ្ញុំបាទ ជប៉ុនទាំនប្រោស ។

ដោយឃើញ*ណូហ្គូជី* នៅក្មេង លោកបណ្ឌិតក៏ចង់ដឹងពីអាយុរបស់អ្នកកម្លោះ តែលោកគិតថា បើសួរពីអាយុគេ ក្រែងនាំឱ្យគេអាក់អន់ចិត្ត លោកក៏មានប្រសាសន៍ សួរថា :



-នាយ*ល្វូងជី* តើអ្នកមើលមកខ្ញុំ ឃើញខ្ញុំមានអាយុប៉ុន្មានដែរ?

សំណួរនេះធ្វើឱ្យ *ហ៊ីដេយោ* ខ្វាយខ្វល់យ៉ាងខ្លាំង។ នៅជំនាន់នោះ បើគេសួរពីអាយុ តោងតែឆ្លើយថា អាយុនៃគូសន្ទនារបស់យើង ច្រើនជាងអាយុដែលយើងមើលឃើញ ទើបគេហៅថាមានសុជីវធម៌។ គិតបែបនេះហើយ *ហ៊ីដេយោ* ក៏ឆ្លើយថា :

-ជំរាបប្រសាសន៍លោកបណ្ឌិត លោកប្រហែលជាអាយុ ៦៥ឆ្នាំ។

តាមពិតនៅវេលានោះ លោកបណ្ឌិត ម៉ាតស៊ិន មានអាយុទើបតែ៣២ឆ្នាំតែប៉ុណ្ណោះ។ ហើយហ៊ីដេយោនៅពេលនោះអាយុ២៧ឆ្នាំ ។ ទោះជាតោងតែឆ្លើយឱ្យច្រើនលើសពីអាយុពិតប្រាកដរបស់គេយ៉ាងម៉េច ក៏ចំឡើយរបស់ហ៊ីដេយោ ដូចជាលើសជ្រុលហួសហេតុពេក។

កិច្ចសន្ទនាដ៏ចំឡែកនេះបានប្រព្រឹត្តទៅ ហើយមិត្តភាពរបស់អ្នកទាំងពីរមានអាយុវែងអន្លាយ ។ បើនិយាយពីប្រទេស *ដាណឺម៉ាក* មិត្តអ្នកអានខ្លះច្បាស់ជារំលឹកឃើញ លោក *អាន់ដែលសិន* ដែលជាបិតានៃរឿងនិទានកុមារមិនលែងឡើយ ។ នៅពេលដែល *ហ៊ីដេយោ* បានទៅដល់ស្រុក *ដាណឺម៉ាក* លោក *អាន់ដែលសិន* បានទទួលមរណភាពអស់រយៈពេល ៣០ឆ្នាំទៅហើយ ។

ប្រទេស *ដាណឺម៉ាក* ជាប្រទេសសុខសន្តិភាពណាស់ ។ ផ្ទះមួយណាក៏មានដាំផ្កាដែរ ។ នៅចន្លោះផ្ទះនឹងផ្ទះអ្នកស្រុកមានដាំដើមផ្កាជារបងឃាំង ។ *ហ៊ីដេយោ* គិតថា ខ្លួនឯងហាក់ដូចជាកំពុងតែចូលមកដល់ប្រទេសមួយ ដែលមានតែនៅតែក្នុងសុបិននិមិត្តប៉ុណ្ណោះ ។ ដោយរវល់តែគយគន់មើលទេសភាព គេគ្មានបានរៀនសូត្រអ្វីបន្តិចសោះ ។ ក៏ប៉ុន្តែ ទេសភាព និងមនុស្ស នៃប្រទេសដាណឺម៉ាកបានបញ្ចូលមកក្នុងបេះដូង *ហ៊ីដេយោ* នូវរបស់ថ្មីមួយបន្ថែមពីលើ



អ្វីដែលគេមានស្រេចទៅហើយ ។ ដោយ *ហ៊ីដេយោ* មិនមែនជាមនុស្សស្រមើស្រមៃអណ្តែតអណ្តូង មិនយូរប៉ុន្មានអ្នកកំឡោះ ក៏រៀបចំប្រុងប្រៀបទទួលការណែនាំពីលោកបណ្ឌិត *ម៉ាតស៊ិន* ហើយក៏ចាប់បន្តការស្រាវជ្រាវពីពិសពស់តទៅទៀត ។

មិនយូរប៉ុន្មាន គេក៏អាចរកឃើញថ្នាំសំរាប់ព្យាបាលសត្វដែលត្រូវពស់មានពិសម្យ៉ាង ឈ្មោះ *rattlesnake*

ចឹក។ ហើយការស្រាវជ្រាវនេះ ក៏មានទំនាក់ទំនងបន្តទៅលើមនុស្សដែរ។

នៅវេលានោះ មានដំណឹងលេចឮមកថា ជប៉ុនចាប់ផ្ដើមធ្វើសង្គ្រាមជាមួយនឹងរុស្ស៊ី។

កាលពី១០ឆ្នាំមុន ពេលខ្លួនកំពុងរស់នៅជ្រកកោននៅផ្ទះលោកគ្រូពេទ្យ *វ៉ាតាណាបេ* ខ្លួនធ្លាប់មានការបារម្ភពីសង្គ្រាមរវាងចិននិងជប៉ុនម្ដងហើយ ហើយឥឡូវនេះ ទោះជាខ្លួននៅស្រុកគេឯនាយឆ្ងាយពីប្រទេសជាតិក្ដី ក៏*ហ៊ីដេយោ* មានសេចក្ដីព្រួយបារម្ភពីស្រុកទេសជាខ្លាំង។ ក៏ប៉ុន្តែ ផ្ទុយពីការស្មានរបស់ជនជាតិអឺរ៉ុប ប្រទេសជប៉ុនបានមានប្រៀបលើគូបដិបក្ស ហើយ *ហ៊ីដេយោ* បានស្ងប់ស្ងាត់ចិត្តជាពន្លឹក។

លុះដល់ឆ្នាំ១៩០៤ *ហ៊ីដេយោ* បានចាកចេញពីប្រទេស *ដាណឺម៉ាក* ដែលខ្លួនធ្លាប់មានអនុស្សាវរីយល្អៗជាច្រើន ត្រឡប់ទៅស្រុកអាមេរិកវិញ បន្ទាប់ពីបានឃ្លាតចេញមកចំនួនមួយឆ្នាំ។

នៅវេលានោះ លោក*រ៉ុកហ្វេល័រ* ជាស្តេចប្រេងកាត និងជាអ្នកមានលេខមួយក្នុងពិភពលោក បានចំណាយលុយយ៉ាងច្រើន បង្កើតវិជ្ជាស្ថានពេទ្យមួយនៅទីក្រុងញូវយ៉ក។ លោកបណ្ឌិត*ហ្វីលេកស្នា* បានត្រូវគេជ្រើសរើសឱ្យធ្វើជាប្រធាននៃវិជ្ជាស្ថាន។ លោកបណ្ឌិតបានទាញ*ហ៊ីដេយោ* ដែលលោកស្រឡាញ់ពេញចិត្ត ទៅឱ្យធ្វើជាភ្នាក់ងារជួយទីមួយរបស់លោក។ ប្រាក់បៀវត្សរ៍វេលានោះ មានច្រើនសន្ធឹកសន្ធាប់ណាស់។ ក្រៅពី*ហ៊ីដេយោ* មានបុគ្គលិកផ្សេងទៀតចំនួន ៦នាក់។ ប៉ុន្តែ *ហ៊ីដេយោ* ដែលមានអាយុ២៧ ជាបុគ្គលិកក្មេងជាងគេបង្អស់។ ពីពេលនោះមក ផ្លូវដើររបស់*ហ៊ីដេយោ* កាន់តែលាតសន្ធឹងធំឡើងៗជាលំដាប់។



# វិជ្ជាស្ថានរ៉ូកហ្វេលល័រ

*ហ៊ីដេយោ* បានប្តូរផ្ទះទៅនៅទីក្រុងញូវយ៉ក។ គេបានជួលបន្ទប់មួយនៅ។ នៅក្នុងបន្ទប់ មានតុដ៏ធំសំបើមមួយដាក់នៅចំកណ្ដាលខាំងតែម្តង។ ជីវភាពមួយ ដែលមានការធ្វើដំណើរចុះឡើងពីផ្ទះទៅវិជ្ជាស្ថាន បានចាប់ផ្តើមឡើង។ វេលាខ្លះ គេគ្មានទាំងពេលមកសំរាកទទួលទានដំណេកឯផ្ទះផង។ ហើយការសំរាកពេលយប់នៅវិជ្ជាស្ថាន ក៏កាន់តែកើនឡើង។ *ហ៊ីដេយោ* គឺជាមនុស្សដែលភ្លេចអ្វីៗទាំងអស់នៅពេលដែល ខ្លួនស្លុងនឹងធ្វើអ្វីមួយ។ សូម្បីតែខោអាវ ឬសក់ ក្បាល ក៏អ្នកកំឡោះមិនរវល់ដែរ។

-ហ្អែ *ណូង្វជី* ខោខ្លួនប្រឡាក់សុទ្ធតែកំបោរស់ស្គុះ ហ្ន៎ !

-អញ្ចឹង? ទេ មិនមែនទេ ខោរហែកទេតើ !

មានពេលខ្លះ ពេលគេកំពុងតែទទួលទានបាយ *ហ៊ីដេយោ* ចូលមកត្រហេបត្រហប ហើយមើលទៅឃើញអាវធំរបស់ *ហ៊ីដេយោ* រហែកយ៉ាងធំ សឹងតែអាចចូលក្បាលមនុស្សម្នាក់បាន។ មនុស្សទាំងឡាយភ្ញាក់ផង ហួសចិត្តផង នាំគ្នាសើចគឹល។

នៅល្ងាចមួយ មានជប៉ុនម្នាក់មករក*ហ៊ីដេយោ*។ យុវជនជប៉ុននោះឈ្មោះ *មីយ៉ាហារ៉ា*។ *មីយ៉ាហារ៉ា* ក៏មកញូវយ៉កដើម្បីសិក្សាវិជ្ជាពេទ្យដែរ។ ដោយចិត្តរបស់យុវជននោះល្អខុសពីមុខរបស់គេ *ហ៊ីដេយោ* ក៏ពេញចិត្តនឹងអ្នកកំឡោះ *មីយ៉ាហារ៉ា* ស្ទួក។ ជីវភាពនៃបុរសចំឡែកទាំងពីរនាក់នេះក៏បានចាប់ផ្ដើមប្រព្រឹត្តឡើង។

នៅទីក្រុងញូវយ៉កបានមួយឆ្នាំ មីយ៉ាហារ៉ា ក៏ត្រឡប់ទៅស្រុកជប៉ុនវិញ ហើយជំនួសរូបយុវជននេះ មានយុវជនម្នាក់ទៀតឈ្មោះ *អារ៉ាគី* បានចូលមកសុំនៅរៀនសូត្រជាមួយនឹង*ហ៊ីដេយោ*។

*អាគីគី*ជានិស្សិត ដែលនៅជ្រកកោនរៀនសូត្រក្នុងសំណាក់នៃលោកគ្រូពេទ្យ *ជីភាគី* ដូច *ហ៊ីដេយោ* ពីមុនដែរ ។

ជារៀងរាល់ថ្ងៃ *ហ៊ីដេយោ* តែងតែទៅមកចុះឡើងវិជ្ជាស្ថាន ផ្ទះជួល ហើយជួនកាលមិនមកផ្ទះវិញក៏មានដែរ ។ ហើយចំនួនថ្ងៃដែលមិនត្រឡប់មកផ្ទះវិញ កាន់តែកើនឡើងៗជាលំដាប់ ។ ទោះជាត្រឡប់មកសំរាកឯផ្ទះ ក៏នៅពេលព្រឹកម៉ោង៨ គេបន្ទីបន្ទាន់បរិភោគអាហារពេលព្រឹកយ៉ាងញាប់ដៃ រួចហើយចេញទៅវិជ្ជាស្ថានវិញយ៉ាងតក់ក្រហល់ដែរ ។ *អាគីគី* ឃើញរបៀបរស់នៅរបស់ *ហ៊ីដេយោ* ក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

មានពេលខ្លះក៏ *ហ៊ីដេយោ* នៅផ្ទះដែរ ប៉ុន្តែភ្នែករបស់គេមិនដកពីសៀវភៅសោះ ។ បើមិនដូច្នេះទេ គឺសរសេរមិនឈប់ ។ ដៃម្ខាងទៀតកាន់បារីស៊ីហ្គាររហូតអត់លែង ។ អ្នកស្គាល់គេនិយាយថា វេលានោះ ក្នុងមួយថ្ងៃ *ហ៊ីដេយោ*

ជក់បារីស៊ីហ្គារ១៥ដើម ។ ទោះជា *អារ៉ាគី* និយាយថាម៉េចក្តី ក៏ *ហ៊ីដេយោ* អ៊ុអើតែទាំងអស់ ។

ហ៊ីដេយោទទួលវេនដាំបាយដែរ ។មានពេលមួយត្រូវវេនខ្លួនដាំបាយ *ហ៊ីដេយោ* ចូលទៅចង្ក្រានបាយ ដោយរីករាយ ។ ប៉ុន្តែភ្នែក របស់យុវជននៅតែនឹងសៀវភៅមិនដកឡើយ ។ មួយសន្ទុះ គេឮសំឡេង *ហ៊ីដេយោ* ស្រែកហៅ អារ៉ាគី :
-អើយ អារ៉ាគី ! អាណាគេ ធ្វើអ្វី ក៏ឈ្ងៀមអីឈ្ងៀមម្ល៉េះអើយ?

*អារ៉ាគី* ត្រហេបត្រហបរត់ចូលមក ហើយបើកគ្របឆ្នាំងមើលក៏ឃើញបាយខ្លោចអស់បាត់ទៅហើយ ។
-ម្ចាស់ថ្លៃ ! ណេហ៊ីយ តស់ទៅបាយហាង ។



អ្នកទាំងពីរក៏នាំគ្នាទៅ ហាងម្ហូបជប៉ុនដែលគេតែងតែទៅជារឿយៗ។ អ្នកម្ចាស់ហាងមិនចាំបាច់ ឱ្យ*ហ៊ីដេយោ* ហៅម្ហូបទាន់ទេ គេលើកម្ហូបមកជាស្រេច។ ពីព្រោះថា *ហ៊ីដេយោ* ហៅតែម្ហូបដដែលៗ។ *ហ៊ីដេយោ* ស្ងៀមស្ងាត់ជានិច្ច សូម្បីតែពាក្យគំនាប់គ្នា ក៏គេមិនដែលនិយាយឱ្យចេញជាពាក្យដែរ។ នៅពេលអង្គុយចុះភ្លាម ក៏បើកសៀវភៅភ្លាម ហើយនៅពេលបរិភោគ ក៏ទុកសៀវភៅនៅក្បែរនោះដែរ។ គេគ្រាន់តែយកសមចាក់អាហារ ហើយទាញវាមកបង់ក្នុងមាត់ ដោយមិនដែលមើលទៅចានម្ហូបម្តងណាឡើយ។ ទោះជានៅក្នុងចានមានអ្វីក៏ដោយ ក៏ *ហ៊ីដេយោ* មិនដែលរវល់ដែរ ភ្នែករបស់គេ នៅតែនឹងសៀវភៅឯណោះ។



ការសិក្សាស្រាវជ្រាវនៅក្នុងវិជ្ជាស្ថាន *រ៉ុកហ្វេល័រ* ប្រព្រឹត្តទៅអស់រយៈពេល ២៥ឆ្នាំ។ គេអាចចែករយៈពេល ២៥ឆ្នាំនេះបានជា ៣ ដំណាក់កាល។ ដំណាក់ទី១ ចាប់ពីឆ្នាំ១៩០៤ ដល់ឆ្នាំ១៩១០ ការស្រាវជ្រាវពីពិសពស់ ពីជម្ងឺរបេង ពីជម្ងឺភ្នែកឡើងបាយ(ត្រាក់កូម)។ ប៉ុន្តែលទ្ធផលមិនសូវជាកាក់កបប៉ុន្មានទេ។ ដូច្នេះកំឡុងពេលនេះ គឺជាកំឡុងពេលដ៏លំបាកសំរាប់*ហ៊ីដេយ៉ោ*។ ដំណាក់កាលទី២ គឺចាប់ពីឆ្នាំ ១៩១១ ដល់ឆ្នាំ១៩១៥ បានជោគជ័យក្នុងការស្រាវជ្រាវជម្ងឺស្វាយប្រមេះ និងរៀបអាពាហពិពាហ៍។ គេបានទទួលសញ្ញាប័ត្របណ្ឌិតពីប្រទេសជប៉ុន និងមេដាយ "*អុងស៊ីស្ហូ*" (មេដាយដែលព្រះចៅអធិរាជប្រទានចំពោះអ្នកស្រាវជ្រាវឬសិល្បករប្រសើរ) ហើយ ត្រឡប់មកប្រទេសជប៉ុន។ គឺជាដំណាក់កាលដ៏ភ្លឺចិញ្ចាចជាងគេបង្អស់នៅក្នុងជីវិតរបស់*ហ៊ីដេយ៉ោ*។ ដំណាក់កាលទី៣ ពីឆ្នាំ១៩១៦ ដល់ឆ្នាំ១៩២៨




វិជ្ជាស្ថានរ៉ុកហ្វេល័រ(Rockefeller) ។ សញ្ញាព្រួញចង្អុលកន្លែង
ស្រាវជ្រាវរបស់ហ៊ីដេយោ

ស្រាវជ្រាវជម្ងឺគ្រុនលឿង ។ការធ្វើដំណើរទៅ *អាមេរិកឡាទីន* (អាមេរិកប៉ែកកណ្ដាល និងខាងត្បូង) រួចមក ទៅអាហ្វ្រិក ហើយទទួលមរណភាពនៅទីនោះ ។

នៅពេលស្របាលៗនឹងគ្នានោះ មានគេបញ្ជូនដំណឹងពីប្រទេសអាល្លឺម៉ង់មកថា គេបានរកឃើញមេរោគនៃជម្ងឺស្វាយប្រមេះហើយ ។ *ហ៊ីដេយោ* បានគិតថា មេរោគនេះមានរូបរាងដូចជាមេរោគ ដែលខ្លួនបានឃើញតាមអតិ

សុខុមទស្សន៍នៅមន្ទីរពេទ្យរបស់លោកគ្រូពេទ្យ *វ៉ាតាណាបេ* អញ្ជឹង ។ ដោយសារតែមេរោគនេះ តើមនុស្សយើងមានការលំបាកប៉ុណ្ណាមកហើយ ។

*ហ៊ីដេយោ* បានរវៀសរវៃចាប់ផ្តើមធ្វើការស្រាវជ្រាវជម្ងឺនោះភ្លាមមួយរំពេច ។ ក្រោយពីពេលដែលពួកអាល្លឺម៉ង់រកឃើញមេរោគស្វាយប្រមេះចំនួន២ខែក្រុម *ហ៊ីដេយោ* ក៏បានរកឃើញមេរោគនោះផ្ទាល់នឹងភ្នែករបស់ពួកគេដែរ ។

តាំងពីពេលនោះមក *ហ៊ីដេយោ* ធ្វើការស្រាវជ្រាវ ដូចជាមានព្រលឹងអ្វីមកសន្ថិតពីលើ ឬក៏ដូចជាមនុស្សវិកលចរិត ។ អ្នកដទៃគេមើលមក គេនាំគ្នាឆ្ងល់គ្រប់ៗគ្នា ៈ

-តើពួកជប៉ុនដេកធ្វើរម៉ាន?

-នេះបានចំជាហៅថាធ្វើការ ២៤ម៉ោងមែនតែម្តង ។

-នេះមិនដឹងជាត្រូវដាក់ឈ្មោះថាម៉េចឱ្យសមទេ ។ តើមនុស្សលោកអាចធ្វើការរហូតដល់នេះបានឬ ? *ហ៊ីដេយោ* ធ្វើការ



ស្រាវជ្រាវស្ងិតស្ងាញហើយលឿនណាស់។ លឿនជាងពីពេលដែលគេស្រាវជ្រាវពិសពស់ទៅទៀត។ បន្ទប់ស្រាវជ្រាវធុំក្លិនបារីស៊ីហ្គារសឹងតែឈ្លក់។ នៅក្នុងបន្ទប់នោះ មានបំពង់ពិសោធន៍រាប់រយដើមតំរៀបគ្នាពេញ។ គេត្រូវតែពិនិត្យវាមួយ១យ៉ាងហ្មត់ចត់ ប្រកបដោយសេចក្ដីអត់ធ្មត់ក្រៃលែង។ តើនៅក្នុងចំណោមបំពង់ពិសោធន៍ទាំងឡាយនោះ មានបំពង់មួយណាប្រែប្រួលអ្វីទេ។ តើមេរោគស្វាយប្រមេះដ៏កំណាច ហើយបរិសុទ្ធ គ្មានលាយអ្វីនេះអាចកើត

មានឡើងនៅក្នុងបំពង់នេះកើតដែរឬយ៉ាងណា ? ប៉ុន្តែការស្រាវជ្រាវនេះក៏បានទទួលជោគជ័យ នៅទីបញ្ចប់។ បានន័យថា គេអាចច្បួតយកតែមេរោគនេះ មកចិញ្ចឹមឱ្យវាកើននៅក្នុងបំពង់ពិសោធន៍បាន។ ដោយសារជោគជ័យនៃការពិសោធន៍នេះ គេអាចបង្កើតវិធីបង្ការ និងថ្នាំថ្មីបាន។ ជោគជ័យនេះកើតមានឡើងនៅឆ្នាំ១៩១០។



# ពីការស្រាវជ្រាវមួយ
# ទៅការស្រាវជ្រាវមួយទៀត



អ្នកស្រី មេរី

នៅឆ្នាំ១៩១២ *ហ៊ីដេយោ* មានអាយុ៣៦ឆ្នាំ។ គេបានរៀបអាពាហពិពាហ៍ជាមួយនឹងនារីអាមេរិកាំងដ៏ស្លូតបូតម្នាក់ឈ្មោះនាង *មេរី ដាជីស*។ អ្នកទាំងពីរបានរើផ្ទះមកនៅ អាប៉ាតឺម៉ង់ (ផ្ទះល្វែងច្រើនជាន់សំរាប់ជួល) មួយនៅជាន់ទី៥។ ទោះជារៀបការហើយក្តី ក៏ជីវភាពស្រាវជ្រាវ *ហ៊ីដេយោ* នៅតែដដែលដែរ។

ពេលវេលាដែលនៅវិជ្ជាស្ថានស្រាវជ្រាវ វែងជាងពេលវេលាដែលគេនៅផ្ទះ។ ប៉ុណ្ណេះហើយក៏នៅតែមិនស្កប់ស្កល់ *ហ៊ីដេយោ* ពុនស្ពាយបំពង់ពិសោធន៍ ព្រមទាំងសម្ភារៈសំរាប់ពិសោធន៍ យកមកផ្ទះ ដាក់ក្នុងចង្ក្រាន ធ្វើការពិសោធន៍បន្ត។ រួចហើយថតរូប។ បន្ទាប់មកផ្តិតរូបនោះ។ នៅលើតុបាយ គេដាក់អតិសុខុមទស្សន៍ ហើយឆ្លុះពិនិត្យ។ ដល់ពេលបាយក៏យ៉ាប់។ មនុស្សដែលល្បីល្បាញថាជាអ្នកបរិភោគលឿន *ហ៊ីដេយោ* ចាប់អកៗមួយប៉ប្រិចក៏លែង ហើយងាក



ទៅរកអតិសុខុមទស្សន៍ បន្តការស្រាវជ្រាវតទៅទៀត ។ គេចិតខ្មៅដៃ បើកសៀវភៅសរសេរ អុជបារីស៊ីហ្គារដែលគេតែងតែជក់ ។ *មេរី* ដែលជានារីស្លូតបូត មិនដែលមានពាក្យធ្ងន់ស្រាលមួយអ៊ឹះទៅលើស្វាមីឡើយ ។ មិនត្រឹមតែប៉ុណ្ណោះនាងយកសៀវភៅមកអង្គុយក្បែរប្ដី អានឱ្យប្ដីស្ដាប់ ។

*ហ៊ីដេយោ* តែងតែនិយាយលេងថា :

-អូនឯងអានសៀវភៅសិក្សាពិបាកម្លឹងៗ ធ្វើម៉េចនឹងបងដែលជាអ្នកស្រាវជ្រាវមេរោគដ៏ថោកទាប និងតូចឆ្មារស្ដាប់យល់ ។

ប៉ុន្តែ *ហ៊ីដេយោ* ចាំយ៉ាងច្បាស់នូវសេចក្ដីនៅក្នុងសៀវភៅដែលភរិយាអានឱ្យស្ដាប់នោះ ។

ចំឡែកណាស់ នៅអាប៉ាតឹម៉ង់នោះ ជាន់ទី៥ដូច *ហ៊ីដេយោ* ដែរ មានជនជនជាតិជប៉ុនម្នាក់ឈ្មោះ *ហូរី*។ *ហូរី* ជាជាងគំនូរ ។ គេតែងតែបង្រៀន *ហ៊ីដេយោ* លេងអុក ។ *ហូរី* បង្រៀនអ្នកណាមិនបង្រៀន មកបង្រៀនចំអ្នកមហាលំបាកនេះ ។

នៅពេលដែលចាប់ផ្ដើមលេងស្រួលបួល ពីយប់ម៉ោង៩ ទៅ *ហ៊ីដេយោ* លេងរបួត សាមសែសិបក្ដារ ធ្វើឱ្យ *ហូរី* ពិបាកដល់កំណត់។ បើលេងឆាប់ពេក *ហ៊ីដេយោ* នឹងចាញ់ ម្ល៉ោះហើយ គេលេងយូរ យកឈ្នះចាញ់នឹងកំឡាំងកាយតែម្ដង។ លេងដំបូង ដោយខ្លាចចិត្តប្រពន្ធ *ហ៊ីដេយោ* អុកថ្មមៗទេ លុះដល់តែថ្មីកបន្តិច ក៏លេងស្រែកយកតែឈ្នះអស់សំឡេងតែម្ដង។

លុះលេងអុកអស់ចិត្តអស់ចង់ហើយ នៅពេលដែល *ហូរី* ត្រឡប់ទៅផ្ទះវិញបាត់ទៅ ការស្រាវជ្រាវក៏ចាប់ផ្ដើមបន្តទៅមុខទៀត។

ថ្ងៃនោះក្ដៅខ្លាំង ទោះជាយប់ហើយក្ដី ក៏អាកាសធាតុមិនឡើងត្រជាក់សោះ។ ធ្វើអ្វីមិនកើត ក៏លេងអុកទៀត។ អ្នកទាំងពីរគ្មានគិតថានៅមុខខ្លួនមាននារីភេទទេ គេលេងពាក់តែអាវក្នុងស្ដើងល្មៀ។ លុះម៉ោងជាង១២យប់ទៅ *ហូរី* ក៏លាទៅវិញ ព្រមទាំងនិយាយថា :

-ឯងក៏ល្មមសំរាកដែរហើយ កុំនៅយប់ពេក ។

-អើ មែន ។

យប់ថ្ងៃនេះ គេលែងឮសំឡេងរថភ្លើងរត់ទៀតហើយ ហើយអាកាសធាតុ ក៏ចាប់ចុះរងាបន្តិច ។

ដល់ពេលដែល *ហ៊ីដេយោ*អាចធ្វើការងារស្រាវជ្រាវបន្តទៀតហើយ ។



អតិសុខុមទស្សន៍ដែលហ៊ីដេយោប្រើ

នៅសម័យនោះ មានការសង្ស័យថា មានជម្ងឺរិកលចរិតម្យ៉ាងមានទំនាក់ទំនងជាមួយនឹងជម្ងឺស្វាយប្រមេះ ។

*ហ៊ីដេយោ* ក៏ស្រាវជ្រាវពីខាងនេះដែរ ។ គេគោងតែឆ្អឹះយកខួរក្បាលអ្នកជម្ងឺ ដែលស្លាប់ហើយ យកទៅត្រាំនឹងថ្នាំដើម្បីឱ្យវារឹង រួចហើយចៀរវាឱ្យស្ដើង ។ បន្ទាប់មកចៀរ

ថែមទៀតឱ្យកាន់តែស្ដើងឡើងៗ។ លុះចៀរឱ្យឡើងស្ដើងមែនទែន ដូចជាអាចម៍រណារទៅ គេក៏ដាក់ពណ៌ ហើយឆ្លុះមើលនឹងអតិសុខុមទស្សន៍ ថាតើមានមេរោគស្វាយប្រមេះឬគ្មាន។ ប្រសិនបើរកឃើញមេរោគស្វាយប្រមេះគេនឹងអាចនិយាយថា រោគនេះមានទំនាក់ទំនងជាមួយនឹងរោគស្វាយប្រមេះមែន។ *ហ៊ីដេយោ* បានយកហ្វីលស្លាយដីពីររយសន្លឹកមកមើល។ គេពិនិត្យមើលមួយសន្លឹកម្ដងៗ ..



-

យ៉ាងផ្ចិតផ្ចង់។ គេតោងតែសង្កេតហ្មត់ចត់សំបើមណាស់ សូម្បីតែស្រមោលតូចមួយ ក៏មិនត្រូវឱ្យកន្លងពីភ្នែកដែរ។ ម៉ោងមួយភ្លឺទៅហើយ នៅសល់ដល់ទៅមួយរយសន្លឹកឯនោះ នៅតែរកមិនទាន់ឃើញ។ គេរាប់១៥០, ១៨០, ១៩៥...

-ឱ ! ថ្ងៃនេះក៏គ្មានបានការអ្វីដែរ។

ប៉ុន្តែនៅពេលដែលពិនិត្យដល់ហ្វីលក្រោយគេបង្អស់ *ហ៊ី ដេយោ* ក៏ស្រាប់តែនិយាយខ្សឹបៗតែឯងថា :

-ដូចជាឃើញទេតើនេះ !

*ហ៊ីដេយោ*អុជបារីស៊ីហ្គារមួយដើម ហើយក៏ពិនិត្យមើលទៅក្នុងកែវឆ្លុះម្តងទៀត ។

-ឃើញហើយ ឃើញហើយរូបរាងពិតរបស់ឯង ។ភ្នែករបស់ *ហ៊ីដេយោ* រំភើបណាស់ ។ ទោះជាមេរោគ ឬ បិសាចតូចល្អិតប៉ុនណាក៏មិនអាចលាក់ខ្លួនឱ្យកំបាំងពីភ្នែក របស់យុវជននេះបានដែរ ។ គេរត់ទៅដាស់ភរិយាដែលកំពុងតែទទូលទាន



ពាក្យ"នីងតាយ"(ប្រែថាអំណត់)ដែលហ៊ីដេយោសរសេរ

ដំណេកលក់ស៊ុបស្ងួន។ ប៉ុននេះហើយនៅតែមិនទាន់អស់ចិត្ត ទៀត *ហ៊ីដេយោ* រត់ទៅគោះទ្វារបន្ទប់ហ្វូរី ត្រហេប ត្រហប ។ *ហ៊ីដេយោ* ចាប់ដៃហ្វូរី ដែលមានមុខសើងមមើង រលាក់ ហើយលោតកញ្ឆេងកញ្ឆោងត្រេកអរ។ គំនិតទេពកោសល្យ ដែលលេចផ្លូចពីខួរក្បាល *ហ៊ីដេយោ* ផ្គួបផ្សំជាមួយនឹងការ ខិតខំដ៏ស្វិតស្វាញ ប្រកបទៅដោយសេចក្តីអំណត់ របស់ អ្នក បានដោះស្រាយអាថិកំបាំងដែលមនុស្សក្នុងពិភពលោក ឆ្ងល់ បានមួយទៀតហើយ។ ប៉ុន្តែ *ហ៊ីដេយោ* មិនចូល ចិត្តពាក្យទេពកោសល្យនេះទេ។

-ខ្ញុំគ្មានជឿថា ទេពកោសល្យមានទេ ។ អ្វីក៏ដោយបើគ្មាន ការខិតខំ ការប្រឹងប្រែងទេ មិនអាចបានសំរេចជាដាច់ខាត។ គេត្រូវរៀនសូត្រឱ្យលើសអ្នកដទៃ ៣ ដង ៥ដង ទើបអាច រកឃើញអ្វីមួយបាន។ ហ្នឹងហើយទេពកោសល្យនោះ។

ពាក្យសំដីមួយឃ្លានេះ បង្ហាញយ៉ាងច្បាស់នូវទឹកចិត្ត របស់ *ហ៊ីដេយោ*។ ជាការពិត *ហ៊ីដេយោ* បានប្រតិបត្តនូវការ ពិតជាក់ស្តែងនេះដោយជោគជ័យ ។



# ត្រឡប់មកស្រុកកំណើត ជាទីស្រឡាញ់ និងរឭក

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩១៣ *ហ៊ីដេយោ* បានទៅជាន់ដីអឺរ៉ុបម្តងទៀត បន្ទាប់ពីឃ្លាតចេញចាកអស់រយៈពេល ១០ឆ្នាំ។ កាលពី ១០ឆ្នាំមុន គេទៅជានិស្សិត ប៉ុន្តែលើកនេះក្នុងនាមជាអ្នកស្រាវជ្រាវ *ហ៊ីដេយោ* បានទទួលសេចក្តីអញ្ជើញពីប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសដែលលូតលាស់ជាងគេបំផុតខាងវិស័យពេទ្យ ឱ្យទៅពន្យល់ពីការស្រាវជ្រាវរបស់គេ។

ហ៊ីដេយោ ឆៀងចូល ប៉ារីស ៥ថ្ងៃ រួចហើយទើបទៅក្រុង*វីយែន*នៃប្រទេស*អូទ្រីស*។ ទីប្រជុំបានឡើងពេញព្រៀប

សឹងតែធ្លាយ ដោយអ្នកប្រាជ្ញអាល្លឺម៉ង់ និងអូទ្រីស។ អ្នកទាំងឡាយចង់ឃើញអ្នកប្រាជ្ញពិភពលោក *ហ៊ីដេយោ* ព្រមទាំងចង់ដឹងឱ្យច្បាស់ ពីការស្រាវជ្រាវរបស់អ្នកប្រាជ្ញនេះ។ ទីប្រជុំចូលមិនចុះ មនុស្សទាំងឡាយតោងតែប្រជ្រៀតគ្នាហៀរហូរទៅដល់ក្រៅ។




ក្រុងនៃបណ្តាប្រទេសអឺរ៉ុបដែលហ៊ីដេយោបានអញ្ជើញទៅ

គឺជាជនជាតិជប៉ុនដំបូងបង្អស់ ដែលគេបានឃើញ។ សក់ *ហ៊ីដេយោ* កោងឡើងលើដូចជាអណ្ដាតភ្លើង មានដុះពុកមាត់ផង។ ដូចធម្មតាដែរ *ហ៊ីដេយោ*មិនសំឡឹងឆ្ពោះទៅរកមនុស្សទេ គេមើលទៅឯពិតាន។ ឯកសាររបស់គេបានត្រូវមនុស្សម្នាក់ទៀតអានជំនួស។ អ្នកដែលមកស្ដាប់ទាំងឡាយខំប្រឹងស្ដាប់យ៉ាងស្ងប់ស្ងាត់។ លុះអ្នកអានជំនួសអានឯកសារឱ្យចប់ហើយ *ហ៊ីដេយោ*ក៏បង្ហាញការរកឃើញ និងការស្រាវជ្រាវរបស់ខ្លួនរហូតមកដល់ពេលនេះ ដោយភ្លើងបញ្ចាំងជូនដល់មហាជន យ៉ាងល្អិតល្អន់ស្រួលយល់។ អ្នកប្រាជ្ញអឺរ៉ុបទាំងឡាយមានការភ្ញាក់ផ្អើលជាខ្លាំងចំពោះការស្រាវជ្រាវ និងគំរកគំហើញ ដ៏ពិបាកនិងដ៏វិសិទ្ធបែបនេះប្រព្រឹត្តទៅបានដោយមនុស្សតែម្នាក់ និងនៅក្នុងកំឡុងពេលដ៏ខ្លីបែប នេះ។

*ហ៊ីដេយោ*ចេញពីក្រុង*វីយែន* ទៅក្រុង*ប្រាង់ហ្វ៊ិត* ជួបនឹងអ្នកប្រាជ្ញដ៏ល្បីខាងជម្ងឺឆ្កែឆ្កួត គឺបណ្ឌិត*អេរីហ៊ីស*។ រួចមកទៀតគេក៏បានទៅជួបលោកបណ្ឌិត*ម៉ាតស៊ិន* ដែលគេបាន

បែកចេញជាយូរមកហើយ ឯទីក្រុង*ភូពេនហាហ្គែន* ទៀត ។ រួចពីនោះមក *ហ៊ីដេយោ* ឈៀងចូលទៅប្រទេស*នរវេយ* ប្រទេស*ស៊ុយអែដ* រួចវាងទៅទីក្រុង*ឡុងដ៏* ទៅទីក្រុង*ប៊ែរឡាំង* ហើយទើបត្រឡប់ទៅប្រទេសអាមេរិកវិញ ។

នៅពេលដែលខ្លួនត្រូវបានពិភពលោកទទួលស្គាល់ថាជា*ល្បូជី ហ៊ីដេយោ* បែបនេះហើយ *ហ៊ីដេយោ* ក៏មានចិត្តនឹករឮកដល់មាតាជាខ្លាំង ។



អ្នកស៊ីកា ម្ដាយហ៊ីដេយោ

-ជោគជ័យនេះគឺជាគុណបុណ្យម្ដាយទាំងស្រុង ។ បងតោងតែត្រឡប់ទៅជប៉ុនវិញជួបមុខលោកម្ដងទើបបាន ។ អ្នកម្ដាយមិនដឹងជារង់ចាំបងផ្សាភ្នែកយ៉ាងណាទេ នៅពេលដែល *ហ៊ីដេយោ*

កំពុងតែនិយាយយ៉ាងនេះជាមួយនឹង *ម៉េរី* ជាភរិយា ស្រាប់តែប៉ុស្តិ៍ យកសំបុត្រពីមិត្តភក្តិ ឈ្មោះ *អ៊ីស៊ីកា សាប៊ីរ៉ូ* មកឱ្យ ។ នៅក្នុងនោះមានរូបថតអ្នកស៊ីកា ជាមាតាមួយសន្លឹកភ្ជាប់ជាមួយដែរ ។



-នេះ មើលហ្មែអូន រូបថតម៉ែចាស់របស់បងនេះ ។ ម៉ែនេះចង់ជួបអូនឯងណាស់ បើយើងមិនទៅជួបលោកឥឡូវទេ

ម្ដាយ នេះច្បាស់ជាស្លាប់ ហើយយើងក៏នឹងខានបានឃើញលោក មួយជីវិតហើយ ។

*ហ៊ីដេយោ* នៅស្ងៀមលែងកើតហើយ ។ គេចង់តែទៅជួបមាតារបស់គេ ប៉ុន្តែ ទាស់តែគ្មានលុយ ។ ប្រាក់ខែមួយឆ្នាំចំនួន ៥០០០ដុល្លា ក៏ចំណាយអស់ ៗទៅលើការស្រាវជ្រាវ គ្មាន សល់មួយសេន ។

មិនដឹងធ្វើម៉េច *ហ៊ីដេយោ* ក៏រៃតេឡេក្រាមទៅខ្ចីលុយមិត្តម្នាក់នៅជប៉ុន ឈ្មោះ*ហូស៊ី ហាជីម៉េ*។ "ខ្ញុំចង់ទៅជួបម្ដាយ សូមផ្ញើលុយមក"។ ហ៊ីដេយោចង់យកភរិយាទៅជាមួយដែរ ប៉ុន្តែដោយគ្មានប្រាក់ផង មានបញ្ហាផ្សេងទៀតផង ក៏ចេញទៅជប៉ុនតែឯកឯង ។

នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩១៥ ហ៊ីដេយោបានត្រឡប់មកឃើញភ្នំ*ហ៊្វូជី* នៃប្រទេសជប៉ុនជាទីស្រឡាញ់វិញ បន្ទាប់ពីបានឃ្លាតចេញទៅអស់រយៈពេល១៦ឆ្នាំ។ ១៦ឆ្នាំមុនមានមនុស្សតិចណាស់ ដែលជូនដំណើរគេពីកំពង់ផែ*យោកូ*

*ហាម៉ា*។ ឥឡូវនេះ *ហ៊ុដេយោ* ត្រឡប់មកទីនេះវិញ ដោយមានមនុស្សជាច្រើនមកទទួល។ លោកគ្រូ *កុបាយ៉ាស៊ិ* ក៏ខំមកពីឆ្ងាយមកទទួលខ្លួនដែរ។ នៅកំពង់ផែ គេបានជួបមុខលោកគ្រូពេទ្យជីវ៉ាគីដែរ។ ពេលចុះពីកប៉ាល់ ក៏ត្រូវពួកអ្នកកាសែតមកចោមរោមព្រោងព្រាត រកតែនិយាយសាសងជាមួយនឹងគ្រូ និងមិត្តភក្តិក៏មិនបាន។

នៅតូក្យូ *ហ៊ុដេយោ* ស្នាក់នៅសណ្ឋាគារ *អ៊ីមប៉េរីយ៉ាល់* ហើយបានទៅធ្វើសុន្ទរកថាសិក្សា នៅសាកលវិទ្យាល័យតូក្យូ។ នៅថ្ងៃទី៩ ខែកញ្ញា ទើបបានឱកាសត្រឡប់ទៅស្រុកកំណើតជាទីនឹករឭកវិញ។ នៅ *ភូរីយ៉ាម៉ា* អ្នកភូមិនិងមិត្តចាស់ៗ ជាច្រើន បានមកទទួលគេ។ នៅភូមិកំណើត *អូគីណាជីម៉ា* មានវទេះភ្លើងរត់ដូចស្រុកផ្សេងទៀតហើយ។

ប៉ុន្តែភូមិកំណើតឥតមានការប្រែប្រួលប៉ុន្មានឱ្យខុសពី២០ឆ្នាំ មុនទេ។ ផ្លូវផ្ទះដែល រៀបជាជួរនៅដដែល។ ភ្នំ *បាន់ដៃ* ទន្លេ *អ៊ីណាវ៉ាស៊ីរ៉ូ*។ អ្វី ដែលប្លែក គឺមានតែខ្លោងទ្វារបៃតង





ហ៊ីដេយោត្រឡប់មកស្រុក ពីស្តាំ លោកគ្រូកុបាយ៉ាស៊ី មាតា ហ៊ីដេយោ  អ៊ីស៊ីតស៊ីកា

ដែលគេធ្វើឡើងសំរាប់ទទួលខ្លួននិងកុមារាកុមារីទាំងឡាយតែប៉ុណ្ណោះ។ *ហ៊ីដេយោ* នៅតែរំលឹកឃើញឡើងវិញ នូវពាក្យថា" អ្នកផ្សងព្រេង" ដែលអ្នកផងតែងតែហៅខ្លួនពីដើម។

ដោយគោរពតាមពាក្យប្រដៅរបស់មាតាដែលជានារីគ្រប់លក្ខណ៍ *ហ៊ីដេយោ*បានដើរទៅគំនាប់អ្នកភូមិតាមផ្ទះមួយ

ម្តងៗឱ្យគ្រប់ផ្ទះ ថ្លែងអំណរគុណគេដែលបានជួយមើលមាតា នៅពេលដែលខ្លួនមិននៅ មុននឹងទៅជួបមុខម្តាយ ។ រួចមកទើបទៅសាលារៀន ហើយទៅគោរពផ្នូរជូនតា ។ ធ្វើតាមបែបបទបែបនេះសព្វគ្រប់ហើយ ដល់តែល្ងាចទើបបានជួបមាតា បានកាន់ដៃមាតា ។ គេឃើញតែទឹកភ្នែកហូររហាមនៅលើថ្ពាល់របស់អ្នកទាំងពីរ ។ លុះដល់យប់ ទើប *ហ៊ីដេយោ*អាចនិយាយ ប្ញបាច់ពីនេះពីនោះជាមួយនឹងម្តាយ និងបងស្រីយ៉ាងល្អូកល្អឺន ។ ការនិយាយរៀបរាប់ប្រាប់គ្នាទៅវិញទៅមកនោះ មានច្រើនសន្ទឹកសន្ធាប់ក្រៃលែង ភ្លេចៗខ្លួន ដល់ថ្ងៃរះបាត់ ។ *ហ៊ីដេយោ* និយាយដដែលៗថា :

-ខ្ញុំធ្វើការស្រាវជ្រាវពីជម្ងឺ មានគ្រោះថ្នាក់ខ្លាំងពេក ចេះតែបារម្ភថាច្បាស់ជាស្លាប់ថ្ងៃណាមួយមិនខានទេ ។ សំណាងល្អចេះមិនស្លាប់ដែរ ។នៅថ្ងៃបន្ទាប់មក ពួកអ្នកភូមិបានមកជួបជុំគ្នានៅផ្ទះហ៊ីដេយោជាច្រើន ។

ហ៊ីដេយោបានទៅលេងសាលាដ៏ជាទីនឹករឭក ហើយបាន សំណេះសំណាលជាមួយនឹងសិស្សានុសិស្សទាំងឡាយ ។

មិនយូរប៉ុន្មាន *ហ៊ីដេយោ* គោងតែត្រឡប់ទៅតូក្យូវិញ ។ លើកនេះ ម្ដាយ និងលោកគ្រូ*កុបាយ៉ាស៊ី*និងភរិយាលោក ក៏ទៅជាមួយគ្នាដែរ ។ ម្ដាយ *ហ៊ីដេយោ* មិនដែលចេញពីភូមិទៅណាមកណាមួយជំហានទេ នៅតែផ្ទះ ។ គាត់ស្លៀកតែចងក្បិន ដើម្បីឱ្យស្រួលកំរើកខ្លួនធ្វើការ មិនដែលបានស្លៀកសំឡយនឹងគេនឹងឯងឡើយ ។ លើកនេះម្ដាយលះបង់សេចក្ដីខ្មាសអៀន ហើយចេញដំណើរជាមួយកូនប្រុសធ្វើទេសចរណ៍មើលភូមិស្រុកគេម្ដុំខាង*កាំងសៃ*។ ទោះជាត្រូវចូលប្រជុំឯនេះឯនោះរវល់វិលក្បុង *ហ៊ីដេយោ* ក៏កាន់ដៃមាតា នាំមាតាដើរមើលក្រុង*ណាហ្គ៉ា ក្យូតូ អូសាកា អ៊ីសេ* ទាល់តែអស់ដែរ ។ នៅអូសាកា មានបវរកញ្ញាស្អាតលើសគេ រាំច្រៀងអបអរសាទរការអញ្ជើញមកដល់នៃ*ហ៊ីដេយោ* ប៉ុន្តែ *ហ៊ីដេយោ*



មិនមានការចាប់អារម្មណ៍ទៅលើទេ គេគិតតែពីចាប់ត្រីម្ហូបអាហារជូនមាតាទាំងពីរ :

-អ្នកម្ដាយ ត្រីនេះសាច់ទន់ឆ្ងាញ់ណាស់ ពិសារមើលមើល៍ !

-អ្នកម្ដាយ *កុបាយ៉ាស៊ី* ចូលចិត្តត្រីអាំងមែនទេ? នេះ នេះ!

នារីដែលខំច្រៀងរាំ លុះមិនឃើញ *ហ៊ិដេយោ* រវីរវល់អើពើ ក៏អាក់អន់ចិត្តជាខ្លាំង។ ប៉ុន្តែ អ្នកដែលបានឃើញ *ហ៊ិដេយោ* ថ្នាក់ថ្នមមាតាបែបនេះ អត់ ទ្រាំបង្ហូរទឹកភ្នែកមិនបាន ក៏លបចេញទៅពួនយំក្បែរទ្វារក៏មាន។ ( អ្នកស្រីម្នាក់ឈ្មោះ

*មីណាមីងាវ៉ា មីតស៊ីអិ* ដែលជាប្រធាននៃនារីបំរើសណ្ឋាគារចាំរឿងនោះច្បាស់ណាស់។ នារីនេះបានបរិច្ចាគប្រាក់កាស់ ផ្ទាល់ខ្លួនធ្វើរូបសំណាកបណ្ឌិត *ហ៊ីដេយោ* ។ ដោយប្រាក់កាស់នោះមិនគ្រប់គ្រាន់ គេក៏បានធ្វើសំណូមពរឱ្យ *អ៊ីស៊ីកា* និង *អាវ៉ាគី* ដែលជាមិត្តរបស់ហ៊ីដេយោជួយអង្គាសលុយពីសិស្សសាលាបឋមសិក្សាអូសាកាបន្ថែម ហើយបានសាងសង់ជារូបសំណាករបស់ *ហ៊ីដេយោ* មួយដ៏ល្អសមសួន។)



អ្នកមីណាមីងាវ៉ា ឈរថត
នៅមុខរូបចម្លាក់

ការដើរកំសាន្តដ៏រីករាយបានចប់ហើយ។ *ហ៊ីដេយោ* ក៏ត្រឡប់មក *អូគីណាស៊ីម៉ា* វិញ ហើយយកប្រាក់ ដែលជារង្វាន់ ដែលបានទទួលគឺ រង្វាន់ "*អុងស៊ីហ្វូ*" (រង្វាន់ដែល

ព្រះចៅអធិរាជលោកប្រទានទៅអ្នកស្រាវជ្រាវ ដែលជាសមាជិកនៃវិជ្ជាស្ថានស្រាវជ្រាវ រកឃើញអ្វីដែលប្រសើរជាប្រយោជន៍សាធារណៈ) ចំនួន ១ ពាន់យ៉េន ទៅធ្វើអំណោយដល់វត្តអារាម សាលារៀន និងរូបព្រះនាង *ពាភមីតា*។ សល់បន្តិចបន្តួច ក៏ទិញស្រែទុកឱ្យមាតាធ្វើ ចិញ្ចឹមជីវិតដើម្បីកុំឱ្យខ្លួនមានការបារម្ភពីម្តាយ ។ ដោយហេតុថា រូបខ្លួនមិនអាចចេះតែនៅជិតម្តាយបានរហូតទេ ។ ដល់ពេលដែល *ហ៊ីដេយោ* ត្រូវត្រឡប់ទៅប្រទេសអាមេរិកវិញហើយ ។ មាតាក៏មានអាយុច្រើនដែរទៅហើយ ។ លើកនេះគឺបែករហូតហើយ ។ ប៉ុន្តែមាតាបែរជាបង្ខំបុត្រ ឱ្យត្រឡប់ទៅធ្វើការស្រាវជ្រាវបន្ត ឯស្រុកគេវិញទៅ ។

*ហ៊ីដេយោ* បានបង្ហើបប្រាប់មិត្តភក្តិថា :

-តែប៉ុណ្ណេះ ខ្ញុំអស់ចិត្តហើយ ស្លាប់អង្កាល់ក៏បានដែរ ។

មែន ការជួបជុំនេះ បានទៅជាការជួបគ្នាចុងក្រោយនៃមាតាកូនរបស់គ្រួសារ *ណូហ្គូជី* នេះ ។

ទោះបីជា*ហ៊ីដេយោ* យល់ថា ខ្លួនគេបានវិលត្រឡប់មកស្រុកកំណើតត្រូវពេលក៏ដោយ គេគោងតែលាស្រុកទេសនេះទៅវិញ ។

មុនពេលចេញដំណើរពីតូក្យូមួយថ្ងៃ យប់នោះ *ហ៊ីដេយោ* និយាយដោយមុខស្រពោន បបួលមិត្តថា :

-ខ្ញាចង់ទទួលទានគុយទាវរទេះដែលគេរុញណាស់រើយ ។

បើប្រៀបធៀបទៅនឹងស្រុកអាមេរិក ស្រុកជប៉ុននៅអន់ថយខ្លាំងណាស់ ។ ប៉ុន្តែចំពោះ*ហ៊ីដេយោ* ជប៉ុនគឺជាស្រុកតែមួយដែលមិនអាចយកអ្វីមកប្តូរជំនួសបានឡើយ ។ គេនិយាយថា :

-នៅកាន់តែយូរ កាន់តែលែងចង់ឃ្លាត ដូច្នេះគោងតែប្រញាប់ចាកចេញទៅអាមេរិកវិញទើបបាន ។

*ហ៊ីដេយោ*ហាក់ដូចជាត្រូវតែកាត់ចិត្តពីរបស់អ្វីមួយដែលខ្លួនពិបាកនឹងកាត់ចិត្តឱ្យដាច់ ។



# ការប្រយុទ្ធជាមួយនឹង គ្រុនខាន់លឿង

*ហ៊ីដេយោ*បានត្រឡប់មកធ្វើការងារស្រាវជ្រាវ នៅវិជ្ជាស្ថានជាថ្មីទៀតហើយ។ គេធ្វើការងារស្រាវជ្រាវនេះ មិនដឹងយប់មិនដឹងថ្ងៃ ដូចពីដើម។ នៅជំនាន់នោះ ពួកអាមេរិកមានទំលាប់មើលងាយជនជាតិដែលមានសម្បុរលឿង ខ្មៅ ដូចជា ជនជាតិអាស៊ី និងអាហ្វ្រិកណាស់។ ជាពិសេស តាំងពីមានសង្គ្រាមជាមួយនឹងចិន និងរុស្ស៊ីមក អាមេរិកស្អប់ជប៉ុនជាខ្លាំង។ ថ្ងៃមួយ នៅពេលដែល*ហ៊ីដេយោ* ដើរកាត់សួនឧទ្យាន មានគេស្រែកថា ៖

-អា ហ្យាប់ (អាជប៉ុន)!

*ហ្សាប់* គឺជាពាក្យនិយាយមើលងាយជនជាតិជប៉ុន ។ ពេលឮ បែបនេះ *ហ៊ីដេយោ* ក៏ស្រែកទៅថា :

-គ្នាជាអ្នកស្រាវជ្រាវនៅវិជ្ជាស្ថាន*រ៉ុកហ្វេល័រ*រ៉ឺយ! ឯងដែលឮឈ្មោះ*ណូហ្គូជី* ទេ?

នៅពេលឮបែបនេះ អ្នកនោះក៏ឱនក្បាលសុំទោសសំបើម ។ ឃើញតែប៉ុននេះ យើងអាចដឹងបានហើយថា តើ *ហ៊ីដេយោ* មានគេស្គាល់ និងគោរពច្រើនយ៉ាងណា ។ *ហ៊ីដេយោ* បានបន្តទៀតដោយសំដីមុតៗថា :



-យើងមិនមែនចង់ប្រដៅអ្នកឯងថា មិនត្រូវប្រើពាក្យបែប នេះចំពោះយើងតែម្នាក់ដែលជា *ណូងូជី* នៃវីជ្ជាស្ថានរ៉ុកហ្វេល័រទេ គឺយើងចង់ប្រាប់អ្នកឯងថា ទោះជា ជាមួយនឹងជប៉ុន ដែលគ្មានឈ្មោះបោះសម្លេង ក៏អ្នកឯងមិនត្រូវប្រើពាក្យ បែបនេះដែរ ។

*ហ៊ីដេយោ* វិរជននៃពិភពលោក ទោះជានៅទីណា ក៏ មិនដែលភ្លេចជប៉ុនដែរ ។

នៅឆ្នាំ១៩១៧ *ហ៊ីដេយោ*មានអាយុជាង៤០ហើយ ។ នៅអាយុនោះ សុខភាព*ហ៊ីដេយោ* បានចុះទ្រុឌទ្រោមយ៉ាង ឆាប់រហ័ស ។ ដំបូង *ហ៊ីដេយោ* បានគិតថា ខ្លួនឯងប្រហែល ជាកើតជម្ងឺ *វ៉ៃល៍* ហើយ ។ ពីព្រោះថា ពីរបីអាទិត្យមុននេះ នៅពេលដែលខ្លួនបានធ្វើការពិសោធន៍ ខ្លួនបានច្រឡំស្រូប មេរោគនេះចូលក្នុងខ្លួនខ្លះ ។ ប៉ុន្តែក្រោយមកទើបបានដឹងថា ខ្លួនកើតជម្ងឺគ្រុនពោះវៀន ។ ជម្ងឺនេះគឺមកពីខ្លួនទទួលទាន ងាវសមុទ្រឆៅច្រើនពេក ។ ងាវនេះឮគេថា វានាំឱ្យមាន

សុខភាពល្អ ទើបខំបរិភោគ មិនដឹងអ្វីថា បរិភោគច្រើននាំឱ្យទៅជាមានជម្ងឺបែបនេះសោះ។ ច្បាស់ជានៅក្នុងសត្វនេះមានមេរោគជម្ងឺគ្រុនពោះវៀនហើយ។

នៅពេលដែលចូលសំរាកពេទ្យ ជម្ងឺនេះបានឡើងខ្លាំងបាត់ទៅហើយ។ ហើយមនុស្សទាំងឡាយមានការបារម្ភជាខ្លាំង ថាពោងតែវះកាត់ទើបជា។ មិនត្រឹមតែជនជាតិអាមេរិកាំងតែប៉ុណ្ណោះទេដែលព្រួយបារម្ភ មនុស្សទាំងឡាយទូទាំងពិភពលោក នាំគ្នាព្រួយបារម្ភពីសុខភាពរបស់អ្នកប្រាជ្ញនេះ។

នៅពេលដែលឮដំណឹងនេះ មាតា *ហ៊ីដេយោ* ដែលនៅវេលានោះមានអាយុ៦៥ឆ្នាំហើយ បានទៅបន់ស្រន់ព្រះនាង *ព្រះម៉ែបារាមីតា* សូមឱ្យព្រះនាងជួយឱ្យជម្ងឺ *ហ៊ីដេយោ* បានជាសះស្បើយ ឥតមានខកខានឡើយ។

ចំនឹងពេលនោះការងារស្រាវជ្រាវរបស់ *ហ៊ីដេយោ* ក៏មិនសូវមានដំណើរការល្អផង *ហ៊ីដេយោ* មានការលំបាក ដូចជាមនុស្សថប់ដង្ហើម។ នៅក្នុងគ្រែ គេតែងតែគិតថា :

-បើស្លាប់ឥឡូវ មិនដឹងជាធូរយ៉ាងណាទេ។ ស្លាប់ទៅក៏មិនមានអ្វីនឹងស្ដាយដែរ។

មានពេលខ្លះ គេភ្ញាក់ឡើង ហើយនិយាយថាៈ

-មានកណ្ដុរប្រែងច្រើនរាប់ពាន់ក្បាលវាដើរកាត់មុខខ្ញុំមួយម្ដងៗ ហើយក្បួនដំណើរវានោះវែងហៅមហាសែនវែង។ មិនចេះចប់។

នេះគឺជាការយល់សប្តិរបស់គេ។ ប៉ុន្តែគេត្រូវតែរស់។ *ហ៊ីដេយោ*មានការងារដែលគេត្រូវតែបំពេញតទៅមុខទៀត។ នៅពេលដែលជម្ងឺបានធូរបន្តិច នរៈនេះនៅមិនស្ងៀមទេ។ ពេលខ្លះគេលបហៅសហការី ដែលធ្វើការជាមួយនៅវិជ្ជាស្ថានឱ្យមកជួបគេ ហើយសួរពីការស្រាវជ្រាវ។ សហការីនេះលបយកបំពង់ពិសោធន៍ដាក់តាមហោប៉ៅមកដែរ។ *ហ៊ីដេយោ* ពិនិត្យមួយខ្ទាច់យ៉ាងឆាប់។

នៅពេលកំពុងតែសំរាកនៅលើគ្រែងពេទ្យ បែបនេះក្តី *ហ៊ីដេយោ*ឆ្លៀតរៀនភាសា*អេស្ប៉ាញ*។ តើគេមានបំណង នឹងធ្វើអ្វីដែរ ដែលខំរៀនភាសា*អេស្ប៉ាញ* នេះ។

*ហ៊ីដេយោ* ចេះភាសា*អង់គ្លេស* ភាសា*អាល្លឺម៉ង់* ភាសា បារាំង ភាសាចិន ភាសា*ដេណឺម៉ាក* ហើយនៅរករៀនភាសា *អេស្ប៉ាញ* ថែមទៀត។ ដើម្បីនឹងសំរាកព្យាបាលជម្ងឺ *ហ៊ីដេយោ* បានធ្វើដំណើរទៅសំរាកនៅផ្ទះឯស្រុកស្រែ យកខ្យល់អាកាសបរិសុទ្ធ។



រូបគំនូរដែលគូរដោយហ៊ីដេយោ



នៅក្រោយផ្ទះមានកូនស្ទឹងដ៏ស្អាតហូរកាត់។ *ហ៊ីដេយោ* ចូលចិត្តទីកន្លែងរបៀបស្រុកស្រែចំការបែបនេះណាស់។ ប៉ុន្តែការងាររវល់មមាញឹកបានរារាំងគេមិនឱ្យមកសំរាកនៅទីដ៏រម្យនាបែបនេះឡើយ។ នៅក្នុងវ៉ាលីស មិត្តរបស់គេ គឺ *ហូរី* បានទុកប្រអប់គូល័រទឹក សំរាប់គូររូបឱ្យមួយឈុត។ *ហ៊ីដេយោ* ដក ខ្មៅដៃចេញមក ហើយចាប់ផ្ដើមគូសវាសរូបទេសភាព។ ពេលកំពុងគូរមាន មនុស្សដើរកាត់មក។ *ហ៊ីដេយោ*

មិនរវល់ចៀសផ្លូវឱ្យអ្នកដំណើរទេ បែរជាសួរទៅ ទាំងគ្មានក្រែងចិត្តអ្នកដំណើរថា :

-ហ្ន៎ មើលដើមឈើនោះមើល៍! ខ្ញុំកំពុងគូររូបដើមឈើហ្នុងណាំ! ឃើញដូចគ្នាបេះបិតទេ?

គំនូរដែល *ហ៊ីដេយោ* គូរមាននៅសល់រហូតមកដល់សព្វថ្ងៃនេះប៉ុន្មានផ្ទាំងដែរ ។

ជីវភាពដ៏សប្បាយរីករាយនៅស្រុកស្រែបានចប់ហើយៗ *ហ៊ីដេយោ*គោងតែត្រឡប់មកទីក្រុងញូវយ៉កវិញ ។ ជម្ងឺក៏លាប់ឡើងវិញ ។ លើសពីនេះ ត្រូវចូលពេទ្យវះកាត់ពោះវៀនដុះខ្នាយទៅទៀត ។ មិនត្រឹមតែប៉ុណ្ណោះទេ *មេរី* ជាប្រពន្ធក៏កើតពោះវៀនដុះខ្នាយ ហើយត្រូវចូលពេទ្យវះកាត់ដែរ ។ ឃើញថា ទុក្ខជាន់លើព្រួយតែម្ដង ។

នៅខែមិថុនា ឆ្នាំ១៩១៨ *ហ៊ីដេយោ*បានចូលទៅធ្វើការវិញទាំងនៅរញ៉ីរញ៉ៃ ដើរមិនទាន់ត្រង់ផ្លូវស្រួលបួលនៅឡើយ ។ ស្រាប់តែលោកបណ្ឌិត *ហ្វ៊ីលេកស្នា*ចូលមក ហើយ

ពឹងឱ្យទៅស្រុក *អេគ័រឌ័រ*។ នៅស្រុកនោះកំពុងតែមានការរាតត្បាតដោយជម្ងឺគ្រុនខាន់លឿង លោកសុំឱ្យ *ហ៊ីដេយោ*



នៅក្នុងបន្ទប់ស្រាវជ្រាវ

ទៅស្រាវជ្រាវរកមេរោគនោះ ។ *ហ៊ីដេយោ*ត្រូវតែប្រឈមមុខ តតាំងនឹងការផ្សងព្រេងដ៏ធំមួយទៀតហើយ ។ ពីពេលនេះទៅមុខចំនួន១០ឆ្នាំ *ហ៊ីដេយោ* តោងតែប្រយុទ្ធជាមួយនឹងជម្ងឺគ្រុនខាន់ លឿង(yellow fever) នេះហើយ ។

ជម្ងឺនេះបានធ្វើឱ្យមនុស្សជាច្រើន មានការលំបាកជាយូរយារណាស់មកហើយ ។ ដោយសារតែរោគនេះ នៅការដ្ឋាននៃព្រៃកជីក *ប៉ាណាម៉ា* មនុស្សជាច្រើនរូបបានធ្លាក់ខ្លួនឈឺ នាំឱ្យរារាំងការងារ ។ នៅស្រុក *អេគ័រឌ័រ* មានទាហានម្នាក់ ក្នុងចំណោមទាហានពីរនាក់ ធ្លាក់ខ្លួនមានជម្ងឺនេះ ។ គេដឹងតែមយ៉ាងថា មូសជាអ្នកចំឡងជម្ងឺនេះ ។ ក្រៅពីនេះ គឺងងឹតសូន្យឈឹង ។ ជម្ងឺនេះនៅជាអាថិកំបាំងសុទ្ធសាធ ។

*ហ៊ីដេយោ*បានទៅដល់ *អេគ័រឌ័រ* នៅថ្ងៃទី៥ ខែកក្កដា ។ គឺជាស្រុកមួយក្តៅណាស់ ។ ប៉ុន្តែទៅដល់ភ្លាម នៅថ្ងៃបន្ទាប់ គេគោងតែធ្វើការងារភ្លាមមួយរំពេជ ។

ភាសាអេស្ប៉ាញដែលគេរៀននៅពេលកំពុងដេកព្យាបាលជម្ងឺគ្រុនពោះវៀន មានប្រយោជន៍មិនតិចទេនៅពេលនេះ ។

នៅថ្ងៃទី៩ គេបានរកឃើញមេរោគមួយដែលគេមិនធ្លាប់ជួបប្រទះសោះ ។ *ហ៊ីដេយោ*បានគិតថា នេះច្បាស់ជាមេរោគជម្ងឺគ្រុនខាន់លឿងហើយ ។ ហ៊ីដេយោ ប្រញាប់ចិញ្ចឹមមេ

រោគនេះ ហើយចាប់ផ្តើម ធ្វើការស្រាវជ្រាវកំចាត់ជម្ងឺនេះ។ គេបានធ្វើការពិសោធន៍ទៅលើកណ្តុរប្រែង លា កណ្តុរស ជាបន្តបន្ទាប់ រហូតដល់អាចបង្កើតនូវថ្នាំថ្មីសំរាប់ព្យាបាល។ ដោយសារតែថ្នាំថ្មីនេះ មានមនុស្សជាច្រើនបានទទួលការសង្គ្រោះឱ្យផុតពីសេចក្តីស្លាប់។

នៅយប់មុនថ្ងៃចេញដំណើរពី*អេត័រន៉ុរ* ពោលគឺនៅថ្ងៃទី ២៩ ខែតុលា អ្នកល្បីៗជាតិ*អេត័រន៉ុរ*ជាច្រើន បានបើកពិធីជប់លៀងសំរាប់*ហ៊ុដេយោ* ហើយបានបំពាក់សក្តិ ជាកូឡូណែលពេទ្យ ជូនថែមទៀតផង។ ជាសក្ខីភាព *ហ៊ុដេយោ*បានទទួលសំលៀកបំពាក់ទាហាន និងដាវ។

សេចក្តីត្រេកអររបស់មនុស្សទាំងឡាយមិនស្ងប់ស្ងាត់តែត្រឹមនេះទេ ប៉ុន្តែ គេថែមទាំងចារឈ្មោះអ្នកប្រាជ្ញនេះដាក់លើផ្លូវ និងបាឡុងបង្ហោះថា "*ណូងូជី*" ថែមទៀតផង។




ប្រទេសអេក្វាទ័រ និងប្រទេសដែលនៅជិតៗនោះ ដែលហ៊ីដេយោបានទៅ



ពិធីថ្លែងអំណរគុណហ៊ីដេយោ នៅប្រទេសអេគ័រឌ័រ

ក្រោយមកទៀត *ហ៊ីដេយោ*បានធ្វើដំណើរទៅប្រទេស *ម៉ិចស៊ិក* ប្រទេស*ប៉េរូ* ប្រទេស*ប្រេស៊ិល* ប្រទេស*ហ្សាម៉ៃកា* ប្រទេស*យុកាតាំង* ជាដើម ដើម្បីស្រាវជ្រាវពីជម្ងឺគ្រុនខាន់លឿងនេះ ។

នៅក្រោយពេលដែល*ហ៊ីដេយោ*ចាកចេញពីស្រុក*អេគ័រឌ័រ*បានបីបួនថ្ងៃ ម្ដាយរបស់គេដែលមានអាយុ៦៥ឆ្នាំ ហើយ

បានចាប់មានជម្ងឺនៅឯស្រុកកំណើត ឯភូមិ *អូគីណាជីម៉ូរ៉ា* ។ អ្នក *ស៊ីកា* បានកើតជម្ងឺផ្កាសាយធំ ឈ្មោះ *អ៊ីនហ្វ៊្លូអិនសា* ដែលជាជម្ងឺអាក្រក់មួយ កើតឡើងក្រោយសង្គ្រាមលោកលើកទី១ ។ ជម្ងឺនេះរាលដាលរាតត្បាតពេញមួយពិភពលោក ។ ជម្ងឺ របស់អ្នក*ស៊ីកា* កាន់តែធ្ងន់ឡើងៗជាលំដាប់ ទៅជាមានជម្ងឺ រលាកសួតថែមទៅទៀត ។



ភ្នំ និងស្ទឹងនៃស្រុកកំណើតរបស់*ហ៊ីដេយោ* កំពុងតែរុំស្រោប ក្រសោបទៅដោយព្រឹលជុំជិត ។ ចង្ក្រានកំដៅមាន

ធ្យូងដុតឆេះក្ដៅងំ។ នៅជុំវិញនោះ គេឃើញលោកគ្រូ*កុបាយ៉ាស៊ុ* និងមិត្តភក្ដិរបស់*ហ៊ីដេយោ*អង្គុយដឹកង់។ អ្នកស៊ីកាបានទទួលមរណភាពនៅថ្ងៃទី១៩ខែវិច្ឆិកា ក្រោមការសោកស្ដាយនៃអ្នកទាំងអស់នេះ។ នៅថ្ងៃនោះ *ហ៊ីដេយោ* ត្រូវធ្វើការពិសោធន៍បង្ហាញវេជ្ជបណ្ឌិតតំបន់។ ប៉ុន្ដែ ដូចជាមានប្រផ្នូលអ្វី ឱ្យគេគិតឃើញតែពីមាតា ហើយគេគ្មានកំឡាំងកំហែងនឹងធ្វើអ្វីទាល់តែសោះ។ មានរឿងដែលចម្លែកបែបនេះដែរ ក្នុងលោកយើងនេះ។

ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ១៩២២ លោកគ្រូពេទ្យ*ជីវ៉ាគី* ជាទីនឹករឮក បានបញ្ចប់ទស្សនកិច្ចនៅអឺរ៉ុប ហើយមកដល់អាមេរិក។ *ហ៊ីដេយោ* តែងតែមានកូនចិត្តមួយចង់ឱ្យលោកគ្រូ*កុបាយ៉ាស៊ុ* និងលោកគ្រូ*ជីវ៉ាគី* មកលេងស្រុកអាមេរិកណាស់។ ឥឡូវនេះបំណងនោះបានសំរេចហើយ។ *ហ៊ីដេយោ* បានទុកការងារ និងអ្វីៗទាំងអស់ចោល ប្រហែលជាមួយខែនាំលោកគ្រូ*ជីវ៉ាគី* ដើរមើលស្រុកភូមិគេ ហើយព្រមទាំងណែ

នាំលោក ឱ្យបានស្គាល់អ្នកមានឈ្មោះល្បីៗជាច្រើន។ ក្នុងចំណោមនោះមានស្ដេចនៃគំរកគំហើញ គឺលោក*អេឌីសុន*ម្នាក់ដែរ។



# ដំណើរទៅអាហ្វ្រិក

យើងបានចូលមកដល់រដូវក្ដៅនៃឆ្នាំ១៩២៧ហើយ ។នៅវេលានោះ នៅក្នុងក្បាលរបស់ *ហ៊ីដេយោ* មានសេចក្ដីបារម្ភមួយកើតឡើង ។ គឺដំណឹងថា ថ្នាំដែល *ហ៊ីដេយោ* រកឃើញមិនមានប្រសិទ្ធភាពទៅលើជម្ងឺគ្រុនខាន់លឿងនៅអាហ្វ្រិកឡើយ ។

លើសពីនេះទៅទៀត វេជ្ជបណ្ឌិតដ៏ចំណាប់ចំនួនម្នាក់ដែល *ហ៊ីដេយោ*មានទំនុកទុកចិត្តអស្ចារ្យ គឺអ្នកប្រាជ្ញខាងវិជ្ជាពេទ្យ ឈ្មោះ *ស្តូគីស* ដែលបានទៅស្រាវជ្រាវដល់អាហ្វ្រិកបានធ្លាក់ខ្លួនមានជម្ងឺគ្រឹប ។ គិតឱ្យមែនទែនទៅមេរោគនោះច្បាស់ជាមិនមែនជាមេរោគដែល *ហ៊ីដេយោ* រកឃើញនៅឯ

*អេតរ៉ង់* កាលពី៩ឆ្នាំមុនទេ។ បើអញ្ចឹងមែន ខ្លួនតោងតែទៅ ដល់ទីកន្លែងពិនិត្យឱ្យឃើញច្បាស់នឹងភ្នែកទើបបាន។

ព្រលឹងរបស់ *ហ៊ីដេយោ* បានហោះហើរទៅទ្វីបអាហ្វ្រិក ដ៏ងងឹតស្លុបដែលបានត្របាក់យកជីវិតរបស់អ្នកប្រាជ្ញប្រសើរៗ ជាបន្តបន្ទាប់។ មានអ្នកខ្លះ និយាយថា :

-រឿងស្រុកគេ ទុកឱ្យអ្នកស្រុកគេគិតតែឯងទៅ ចាំបាច់ទៅរវល់នាំឱ្យឈឺក្បាលធ្វើអ្វី?

លោកបណ្ឌិត *ហ្វ៊ីលេកស្នា* ក៏បានឃាត់ *ហ៊ីដេយោ* ដែរ :

-អ្នកឯងជាអ្នកប្រាជ្ញប្រសើរណាស់ អ្នកមិនចាំបាច់អ្វីនឹងធ្វើដំណើរទៅទីដ៏ឆ្ងាយបែបនេះនាំតែហត់ទេ។

ប៉ុន្តែ *ហ៊ីដេយោ*បានឆ្លើយយ៉ាងហ្មត់ចត់ថា :

-ទោះបីជាខ្ញុំបាទទៅទីនោះ ហើយឈឺស្លាប់ក៏មិនអីដែរ។

សូម្បីតែអ្នកស្រី *មេរី* ជាភរិយាឃាត់ ក៏ *ហ៊ីដេយោ* នៅតែចចេសមិនកែប្រែការសំរេចចិត្តរបស់ខ្លួនដែរ។

នៅថ្ងៃទី២២ ខែតុលា *ហ៊ីដេយោ* បានអនុញ្ញាតឱ្យតែសហការី២រូបជូនដំណើរទៅដល់ផែកប៉ាល់ ហើយឡើងជិះកប៉ាល់ចេញដំណើរទៅ ។ វេលានោះ *ហ៊ីដេយោ* មានអាយុ ៥១ឆ្នាំហើយ ។ លើកនេះខ្លួននឹងលែងបានមកជាន់ដីទ្វីបអាមេរិក ដែលខ្លួនបានមកជាន់ ហើយខាំក្រាបមិនឱ្យរបូតកាលពី២៧ឆ្នាំមុននោះ ជាលើកទី២ទៀតហើយ ។




តំបន់អាហ្វ្រិកដែលហ៊ីដេយោបានទៅ

នៅទីក្រុង*ឡាហ្គូស*នៃទ្វីបអាហ្វ្រិក សហការីដែលធ្វើការនៅវិជ្ជាស្ថាន*រ៉ុកហ្វេល័រ* បាននៅរង់ចាំការមកដល់នៃ*ហ៊ីដេយោ*។ ពីទីនោះ គេត្រូវធ្វើដំណើរបន្តទៅក្រុងឈ្មោះ *អក្កូរា* ហើយនៅធ្វើការងារនៅទីនោះ។ នៅទីនោះ មានវិជ្ជាស្ថានមួយ ដែលសង់ឡើងដោយជនជាតិអង់គ្លេស ហើយអ្នកដែលនៅប្រចាំការ ជាប្រធាននៃវិជ្ជាស្ថាន ឈ្មោះ*យ៉ាំង* ជាមនុស្សរហ្មត់ចត់ណាស់។

ចាប់ពីពេលនោះមក ការងាររួមដ៏លំបាកមួយដែលមានអ្នកទាំងពីរជាស្នូល នឹងចាប់ផ្ដើមហើយ។ ដើម្បីធ្វើការពិសោធន៍មួយ គេត្រូវការស្វា៩០០។ សេះក៏ត្រូវបានគេយកមកធ្វើរបស់សំរាប់ពិសោធន៍ដែរ។ ដើម្បីនឹងធ្វើបែបនេះ គេតោងតែមានចំណីសំរាប់សត្វទាំងនេះស៊ី មួយថ្ងៃបីតោន។ បន្ទាប់មក តោងតែជួលអ្នកជំនួយការងារប្រហែលជា៣០០នាក់។

ដោយសារតែស្រុកនេះនៅជិតខ្សែអេក្វាទ័រ មួយថ្ងៃៗក្តៅខ្លាំងណាស់ ។ អកុសលអ្វីដោយ នៅម៉្តុំនោះមិនមានអ្នកជម្ងឺគ្រុនខាន់លឿង ការស្រាវជ្រាវមិនអាចប្រព្រឹត្តទៅបានដោយសំរួលដូចបំណងឡើយ ។ មួយថ្ងៃៗ *ហ៊ីដេយោ* អង្គុយតែព្រួយ ។ ភ្លេចៗខ្លួន ដល់ចុងឆ្នាំបាត់ ។



ពេលមួយនោះ សហការីដែលធ្វើការនៅវិជ្ជាស្ថាន បានមករក *ហ៊ីដេយោ* ឯផ្ទះ ក៏ស្រាប់តែឃើញ *ហ៊ីដេយោ* នៅសំរាកលើគ្រែស្តឹក ។ គឺរូបគេបានត្រូវជម្ងឺគ្រុនខាន់លឿងញ៉ាំបាត់

ទៅហើយ។ តើ*ហ៊ីដេយោ* នឹងត្រូវស្លាប់ទីនេះដូច*ស្តូគីស* ដែរឬ?

ភ័ព្វល្អ ជម្ងឺនេះមិនទាន់ធ្ងន់នៅឡើយ ហើយម្យ៉ាងទៀត ប្រហែលជា*ហ៊ីដេយោ* បានចាក់ថ្នាំដែលខ្លួនបានរកឃើញបង្ការមកហើយ ទើបបានជាអាចសង្គ្រោះបានបែបនេះ។ លុះចូលដល់ខែកុម្ភៈ ការងារស្រាវជ្រាវរបស់*ហ៊ីដេយោ* កាន់តែយ៉ាប់ទៅៗ។ ម៉ោងពេលសំរាប់ទទួលទានដំណេកដែលតិចស្រាប់ហើយ ក៏រឹងរិតតែចុះតិចទៅៗជាលំដាប់។

ពេលព្រឹកម៉ោង១០ គេក្រោកសរសេរកំណត់ហេតុ ដែលជាលទ្ធផលនៃការពិនិត្យ រួចមកទទួលទានបាយ។ ពេលរសៀលសំរាកបន្តិច បន្ទាប់មកគឺគិតតែពីធ្វើការរហូតទល់ភ្លឺបែបនេះរហូតជារៀងរាល់ថ្ងៃ។

វេលាយប់ នៅពេលដែលមានសត្វដែលយកមកធ្វើការពិសោធន៍ស្លាប់ *ហ៊ីដេយោ* តោងតែហៅ*យ៉ាំងេ*មក ហើយចាប់ផ្តើមវះកាត់សត្វនោះ។

ជីវភាពស្រាវជ្រាវដ៏ហត់ចត់នេះ ធ្មេចបើក១ ក៏បាន៩ ខែបាត់ទៅហើយ ។ មានពេលខ្លះ គេហាក់ដូចជាមានកូន សង្ឃឹម :

-ដូចជារកឃើញហើយតើហ្ន៎ ! ស្រួលមិនស្រួល យើងអាច រកឃើញគន្លាក់មួយក៏មិនដឹង ។ តស៊ូ ខំស្រាវជ្រាវតទៅ ទៀត ។

ប៉ុន្តែនៅថ្ងៃបន្ទាប់ ពេលខំពិនិត្យមែនទែនទៅ ក៏ឃើញ ថាមិនអាចយកជាការបាន,កូនសង្ឃឹមនោះក៏រលាយរូបរាង បាត់ទៅ ។ ការនេះមិនមែនមានតែម្តងឬពីរដងទេ គឺកើត មានឡើងញឹកញាប់ណាស់ ។

ការស្រាវជ្រាវបែបនេះចេះតែបន្តឡើង ហើយគេក៏បាន រកឃើញជាលំដាប់ថា ជម្ងឺគ្រុនខាន់លឿងដែលគេរកឃើញ ពី១០ឆ្នាំមុន ខុសពីជម្ងឺគ្រុនខាន់លឿងអាហ្វ្រិកនេះ ។ បន្ទាប់ មក គេក៏រកឃើញមេរោគខុសៗគ្នាចំនួន៥បែប ។ ដោយមាន ឯកសារគ្រប់គ្រាន់ហើយ *ហ៊ីដេយោ* ក៏អាចត្រឡប់មកក្រុង

ញូវយ៉កដែលមានសម្ភារៈស្រាវជ្រាវគ្រប់គ្រាន់ ងាយស្រួលក្នុង ការស្រាវជ្រាវ ។

គេបានកំណត់យកអាទិត្យទី៣ នៃខែឧសភា ឆ្នាំ១៩២៩ ធ្វើជាថ្ងៃសំរាប់ចេញដំណើរ ។ *ហ៊ីដេយោ* មានការរវល់ជាប់ជារៀងរាល់ថ្ងៃ ដើម្បីរៀបចំឥវ៉ាន់ចេញដំណើរ ។ នៅពេលនោះ *ហ៊ីដេយោ* បានដឹងខ្លួនខ្លះៗហើយថា ខ្លួនអស់កម្លាំង ។ ប៉ុន្តែនៅពេលដែលមានភ្ញៀវចំឡែកមកលេង គេតែងតែនៅដល់យប់ៗ លេងអុកដែលគេចូលចិត្ត ។

ថ្ងៃចេញដំណើរទៅ *អក្ករា* ជិតចូលមកដល់ហើយ ។ គេត្រូវដើរលាមិត្តដែលធ្វើការនៅវិជ្ជាស្ថាន ឯ*ឡាហ្គុស*។ នៅទីនោះ *ហ៊ីដេយោ*មិលទៅឃើញហាក់ដូចជា ជាមនុស្សជានាធម្មតាគ្មានជម្ងឺអ្វីទេ ។ នៅថ្ងៃបន្ទាប់ គេនិយាយថា ដូចជាស្រៀវខ្លួន ហើយក៏គិតថាប្រហែលជាកើតជម្ងឺគ្រុនចាញ់ ។

ប៉ុន្តែនៅពេលដែលគេពិនិត្យឈាម *ហ៊ីដេយោ* គេមិនឃើញមេរោគគ្រុនចាញ់ទេ។ នៅវេលាយប់ នៅក្នុងកប៉ាល់ដែលគេជិះសំដៅទៅក្រុង *អក្កា* គេក៏ចាប់រងាញាក់ជាថ្មីទៀត។



ដោយនៅក្រុង *អក្កា* គ្មានផែធំ កប៉ាល់មិនអាចចូលចតបានទេ។ គេតោងតែប្ដូរទៅជិះកប៉ាល់តូច ទើបអាចចូលទៅកំពង់ផែបាន។ ប៉ុន្តែដោយមានរលកធំពេក កប៉ាល់តូចមិនអាចកាត់ចេញពីកប៉ាល់ដែលបើកដោយចំហាយទឹកបាន

ឡើយ ។ លុះដល់កន្លែងដែលអាចផ្តាច់ចេញពីកប៉ាល់ចំហាយទឹក ហើយ ក៏ត្រូវខ្យល់ខ្លាំងបក់មក ធ្វើឱ្យក្តោងត្រូវខ្យល់ខ្លាំង ទៅមុខមិនលឿនសោះ ។

ពេលគេដកក្តោងចេញ កប៉ាល់ក៏អាចទៅមុខបាន ប៉ុន្តែ *ហ៊ីដេយោ* នេះទទឹកជោក ។ គ្រាន់តែឡើងដល់ច្រាំងហើយ បានទៅដល់ផ្ទះមិត្តភ្លាម *ហ៊ីដេយោ* ក៏ចូលទៅទទួលទានដំណេកស្ងឹក ។

ថ្ងៃបន្ទាប់ គេក៏ដឹក *ហ៊ីដេយោ* ទៅមន្ទីរពេទ្យ ហើយ *ហ៊ីដេយោ* ក៏សន្លប់សន្លិនឥតដឹងខ្លួនរហូត ។

ពោលគឺគេបានកើតជម្ងឺគ្រុនខាន់លឿងបាត់ទៅហើយ ។ មួយថ្ងៃ ពីរថ្ងៃ ប្រាំពីរថ្ងៃកន្លងផុតទៅ ។ ជម្ងឺនេះឡើងដល់កំពូលនៅថ្ងៃទី៧ ។ មិត្តទាំងឡាយនាំគ្នានៅស្ងៀមស្ងាត់ក្បែរខ្លួនអ្នកជម្ងឺ ។ មើលទៅ ឃើញហាក់ដូចជាមានផ្លូវ ក៏ស្រាប់តែនៅថ្ងៃទី៨ *ហ៊ីដេយោ* ឡើងញាក់ញ័រ ហើយនៅថ្ងៃទី៩ក៏គេងស្ងៀមស្ងាត់ ។



នៅយប់នោះ *យ៉ាំង* បានមកសួរជម្ងឺ។ *ហ៊ីដេយ៉ោ* បើក ភ្នែកដូចមនុស្សធម្មតា ហើយនិយាយទៅកាន់*យ៉ាំង* ទាំង ព្រួយបារម្ភថា :

-*យ៉ាំង* ឯងមិនអីទេឬ?

ទោះជាខ្លួនឯងមានជម្ងឺដាបដល់នេះហើយ ក៏ *ហ៊ីដេយ៉ោ* នៅតែបារម្ភអំពីអ្នកដទៃ។

*យ៉ាំង* ឆ្លើយថា :

-បាទមិនអីទេ។ មើលមើល៍ ខ្ញុំមានសុខភាពល្អប្រសើរណាស់។

*ហ៊ីដេយោ* តបទៅ *យ៉ាំង* ថា :

-ខ្ញុំមិនដឹងជាយ៉ាងណាទេ *យ៉ាំង*។

និយាយតែប៉ុណ្ណេះ *ហ៊ីដេយោ* ក៏សំរាកលង់លក់ទៅក្នុងដំណេកដ៏ជ្រៅ។ បន្ទាប់មក នៅថ្ងៃទី២១ ខែឧសភា នៅវេលាថ្ងៃត្រង់ *ហ៊ីដេយោ* ក៏ទទួលមរណភាព។ ជីវិតដែលមានប្រវែង៥១ឆ្នាំ ៦ខែ ប្រកបទៅដោយវីរភាព បានបញ្ចប់នៅអាហ្វ្រិក ដ៏សែនឆ្ងាយពីស្រុកកំណើត។



ផ្នូររបស់ហ៊ីដេយោ នៅវីតឡូន ក្រុងញូវយ៉ក

សាកសពរបស់ *ហ៊ីដេយោ* បានត្រូវគេដាក់ទៅក្នុងម្ឈូសដែក មានលំអទៅដោយបុប្ផជាតិនៃប្រទេសក្តៅ ដូចជាគេកំពុងតែដេកសំរាកក្នុងសួនផ្កា ហើយដឹកដោយកូនកប៉ាល់ដែលអូសដោយកប៉ាល់ចំហាយទឹក ។

*យ៉ាំង* បានជូនដំណើរសពហើយ ទើបត្រឡប់មកវិជ្ជាស្ថានវិញ ហើយបាចថ្នាំរំងាប់មេរោគបន្ទប់នានា ។ ប៉ុន្តែ*យ៉ាំង* នេះក៏ទទួលមរណភាពជាបន្ទាប់នោះ ដោយជម្ងឺគ្រុនខាន់លឿងដែរ ហាក់ដូចជាទៅតាមមិត្ត ឯស្ថាននាយដែរ ។

គេបានបូជា*ហ៊ីដេយោ*នៅ*វិតឡូន* នាទីក្រុងញូវយ៉ក ហើយគេបានចារនៅលើផ្នូរអ្នកប្រាជ្ញនេះថា : "*ណូហ្គូជី ហ៊ីដេយោ*" អ្នកនេះបានបូជាអ្វីៗទាំងអស់សំរាប់វិទ្យាសាស្ត្រ ។ ជីវិតគេមានឡើងសំរាប់បំរើមនុស្សជាតិ ហើយស្លាប់ក៏ដើម្បីបំរើមនុស្សជាតិដែរ ។

**ចប់**

# សេចក្ដីពន្យល់

*ណូហ្គូជីហ៊ីដេយោ* ដែលខ្ញុំស្គាល់

វេជ្ជបណ្ឌិត *តាកាណូ រ៉ុគ៉ូរ៉ូ*

អតីតប្រធានវិជ្ជាស្ថាន*គីតាសាតូ*

(១) ជនជាតិជប៉ុនណាម្នាក់ក៏ដឹងដែរថា *ណូហ្គូជី ហ៊ីដេយោ* ជាអ្នកប្រាជ្ញដ៏ប្រសើរខាងវិជ្ជាពេទ្យ ប៉ុន្តែអ្នកដែលដឹងថា តើការសិក្សាស្រាវជ្រាវរបស់លោក ខាងវិជ្ជាពេទ្យមានអ្វីខ្លះ ប្រហែលជាមានតិចតួចណាស់។

ដោយយើងម្នាក់ៗស្រឡាញ់ និងគោរពលោកជ្រុលពេកទៅ យើងក៏មិនព្រមចង់ដឹងឮ ឬយល់អំពីអត្ថន័យខ្លឹមសារនៃការសិក្សាស្រាវជ្រាវដែលលោកបន្សល់ទុកឱ្យទេ ហើយខិតខំតែគោរពបូជាលោក ក្នុងនាមជាវេជ្ជបណ្ឌិត ឬក៏ព្រះជាម្ចាស់មួយអង្គ។

យល់ដូច្នេះហើយ បានជាខ្ញុំសរសេរអត្ថបទនេះ ដើម្បីឱ្យអ្នកអាន បានជ្រាបថា តើ*ល្អូងជី ហ៊ីដេយោ* បានធ្វើអ្វីខ្លះ ទើបបានជាលោកមានឈ្មោះល្បីរន្ទឺ ពាសពេញពិភពលោកបែបនេះ។ ពោលគឺដើម្បីឱ្យមិត្តអ្នកអានស្គាល់ពីតម្លៃពិតប្រាកដរបស់លោក។

(២) លោក*ល្អូងជី ហ៊ីដេយោ* ជាបុរសម្នាក់ដែលមានប្រាជ្ញាវៀងវៃ ខិតខំរៀនសូត្រ មានអំណត់អត់ធ្មត់ ហើយមិនសុខចិត្តចុះចាញ់នរណាស្រួលៗឡើយ។ ការខិតខំ ហើយខិតខំទៀតរបស់លោក បានធ្វើឱ្យលោកក្លាយទៅជាមហាបុរសបែបនេះ។ ហើយមានមូលហេតុមួយទៀតដែលយើងមិនត្រូវភ្លេច គឺសំណាងរបស់លោកដែលបានជួបនឹងមនុស្ស ដ៏ប្រសើរៗជាច្រើន។ យើងលើកយកឧទាហរណ៍មួយ គឺកាលនៅជាទារក លោកបានរលាកដៃ ហើយបានទទួលការព្យាបាលប្រកបដោយជោគជ័យ។ នេះគឺជាសំណាងរបស់លោកមួយ។ ដោយសារតែមានបច្ច័យនេះ ទើប*ហ៊ីដេយោ*

មានបំណងនឹង ក្លាយទៅពេទ្យ ហើយសំរេចចិត្តថា ត្រូវជួយមនុស្សដែលមានទុក្ខដោយជម្ងឺ។ ជំនួបនឹងវេជ្ជបណ្ឌិត *វ៉ាតាណាបេ* ដែលព្យាបាលដៃឆ្វេងលោក ក៏ជានិស្ស័យមួយដែរ ។ វេជ្ជបណ្ឌិត *វ៉ាតាណាបេ* គឺជាអ្នក ដែលបានទទួលការសិក្សាអប់រំនៅប្រទេសអាមេរិក។ ការបានឆ្លុះមើលមេរោគនៃជម្ងឺគ្រុនលាប់តាមអតិសុខុមទស្សន៍នៅមន្ទីព្យាបាលរបស់វេជ្ជបណ្ឌិតនេះ គឺជានិស្ស័យ នាំឱ្យលោកមានការចង់សិក្សាពីមេរោគក្នុងវិជ្ជាពេទ្យ។ លោកចេញពីស្រុកកំណើត មកតូក្យូ ប្រឡងជាប់សញ្ញាប័ត្រពេទ្យ បានចូលទៅធ្វើការនៅវិជ្ជាស្ថានជម្ងឺឆ្លង ក៏ដោយសារតែនិស្ស័យនេះឯងដែរ ។ នៅទីនោះ វេលាដែលបានឃើញជោគ ជ័យនៃបណ្ឌិត *គីតាសាតូ* ទើបលោកក៏មានចិត្ត ចង់ធ្វើការងារនោះបន្តពីបណ្ឌិតនេះ។

(៣) លុះដល់ចូលទៅធ្វើការនៅវិជ្ជាស្ថាននេះ ដោយលោកមានទេពកោសល្យខាងភាសាបរទេស គេក៏ឱ្យលោកទៅធ្វើការនៅបណ្ណាល័យ ។ ការងារនេះបានផ្តល់ឱកាសឱ្យលោកបានរៀនកាន់តែច្រើន ។ ដោយលោកគ្មានលុយទិញសៀវភៅបរទេស នេះគឺជាសំណាងដ៏ថ្លៃថ្លាបំផុតមួយដោយអាចអានសៀវភៅតាមចំណង់ចិត្ត ។

ត្រូវនឹងពេលនោះ លោកបណ្ឌិតអាមេរិកាំង *ហ៊ីលេកស្មា* ដែលជាអ្នកប្រាជ្ញខាងអតិសុខុមប្រាណ ឆ្មៀងមកធ្វើទស្សនកិច្ចនៅវិជ្ជាស្ថាន ដើម្បីជួបបណ្ឌិត *គីតាសាតូ, ហ៊ីដេយោ* ក៏បានទទួលនូវសំណាងដ៏ល្អមួយទៀតគឺការបញ្ជាពីប្រធានឱ្យនាំបណ្ឌិតអាមេរិកាំងនេះធ្វើទស្សនកិច្ច ។ ឱកាសនេះជាកូនសោមួយដ៏សំខាន់សំរាប់ធ្វើឱ្យសំណាង ដែលប្រុងនឹងចូលមកហើយអាចចូលមកបានកាន់តែស្រួល ។ គេបានឆ្លៀតឱកាស អួសទាញពន្លកនិស្ស័យនៃជំនួបនេះធ្វើ ដំណើរសឹងតែថាមិនអស់លុយមួយសេនទៅស្រុកអាមេរិក ។

សេចក្ដីក្លាហាននេះ ពិបាកនឹងរកពាក្យមកដាក់ឱ្យណាស់ មិនធម្មតាទេ ចំពោះមនុស្សទូទៅ។ ប្រាកដណាស់ថា វិជ្ជាអតិសុខុមប្រាណរបស់ *ហ៊ុដេយោ* បានដុះពន្លកប៉ិច ឡើងដោយសារបណ្ឌិត *គីតាសាតូ* ហើយលូតលាស់កាន់ តែខ្លាំងឡើងៗ ដោយសារការបង្រៀនរបស់បណ្ឌិត *ហ៊ីលេកស្នា*។ ប្រសិនបើគ្មានការណែនាំ ដឹកកក់ក្ដៅរបស់ បណ្ឌិត *ហ៊ីលេកស្នា*ទេ ក៏ *ហ៊ុដេយោ* មិនដឹងជា ក្លាយទៅជា អ្វីដែរ។

លោក *ហ៊ីលេកស្នា* មិនត្រឹមតែបានបំបើកភ្នែករបស់ *ហ៊ុដេយោ* ចំពោះការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះទេ លោកថែម ទាំងបានណែនាំ *ហ៊ុដេយោ* ទៅឱ្យស្គាល់ក្រុមជំនុំសិក្សា ព្រម ទាំងបញ្ជូនលោកឱ្យទៅរៀននៅអឺរ៉ុបទៀតផង។ នៅប្រទេស *ដាណឺម៉ាក* , *ហ៊ុដេយោ* បានរៀនវិជ្ជាសេរ៉ូមឈាមពីវិជ្ជាស្ថាន នៃវេជ្ជបណ្ឌិត *ម៉ាតស៊ិន* ហើយនៅពេលដែលត្រឡប់មកពី អឺរ៉ុបវិញ ក៏បានចូលទៅធ្វើការនៅក្រោមបង្គាប់របស់បណ្ឌិត ហ៊ីលេកស្នាដែលបានឡើងធ្វើជាប្រធានវិជ្ជាស្ថានរ៉ុកហ្វេល័រ

(៤) វិជ្ជាស្ថាន*រ៉ុកហ្វេល័រ* ជាកន្លែងប្រជុំអ្នកប្រាជ្ញថ្នាក់ពិភពលោក ពីគ្រប់ប្រទេសក្នុងពិភពលោក ដូច្នេះការងារជាបុគ្គលិកនៃវិជ្ជាស្ថាននេះ ហាក់ដូចជាផ្លាកដ៏ធំមួយដែលគេបំពាក់ឱ្យលោកថា ជាអ្នកប្រាជ្ញសំបើមម្នាក់រួច ស្រេចបាត់ទៅ ហើយ ។

ពីឆ្នាំ១៩០៤ទៅ នៅក្នុងរយៈពេល១០ឆ្នាំ *ហ៊ីដេយោ* បានខិតខំរៀនសូត្រខ្លាំងក្លាណាស់ ។ ជាមួយនឹងគ្នានេះ កិត្តិនាមរបស់*ហ៊ីដេយោ* ក៏បានឡើងរន្ទឺពាសពេញពិភពលោកដែរ ។ ជាពិសេស ការរកឃើញ "ជម្ងឺរិកលស្គីក" ជម្ងឺ "របេងខួរឆ្អឹង" និង*ស្ពីរ៉ូហេតា* នៃរោគស្វាយប្រមេះ ដែលនៅក្នុងខួរក្បាល និងខួរឆ្អឹងនៃអ្នកជម្ងឺ ព្រមទាំងជោគជ័យនៃការ "ចិញ្ចឹមបរិសុទ្ធ" នៃមេរោគនេះបាន បានធ្វើ ឱ្យមានការកែលំអការពិនិត្យ ជម្ងឺស្វាយប្រមេះ វ៉ាក់សាំង អុត ហើយជាហេតុនាំឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីក្រុមជំនុំសិក្សាអ្នកស្រាវជ្រាវវិជ្ជាពេទ្យ ។

ក្រៅពីនេះ *ហ៊ីដេយោ* បានធ្វើរបាយការអំពីអតិសុខុមប្រាណដែលជាមេរោគនៃជម្ងឺស្លឹកកុមារ ជម្ងឺឆ្កែឆ្កួត ជម្ងឺភ្នែកឡើងបាយ ជាបន្តបន្ទាប់ ដែលជាហេតុនាំឱ្យពិភពលោកមានការភ្ញាក់ផ្អើលជាខ្លាំង។ ប៉ុន្តែជោគជ័យទាំងឡាយនេះ មិនទាន់សមស្របតាមផ្លែផ្កាដែល *ហ៊ីដេយោ* បានសង្ឃឹមទុកជាមុននៅឡើយទេ។ គួរឱ្យស្តាយដែរដោយសារថា បាន តែកិត្តិនាម តែគ្មានខ្លឹមសារជាដុំកំភួន។

ដោយការស្រាវជ្រាវរបស់ *ហ៊ីដេយោ* បានគេចុះផ្សាយនៅក្នុងទស្សនាវដ្ដី នៃវិជ្ជាស្ថានទស្សនាវត្តីវិជ្ជាពេទ្យពិសោធន៍ជាបន្តបន្ទាប់ លោកក៏បានក្លាយទៅជាលោកគ្រូធំនៃការស្រាវជ្រាវ មេរោគនៃជម្ងឺ។

នៅឆ្នាំ១៩១៣ *ហ៊ីដេយោ* បានទទួលសេចក្ដីអញ្ជើញពីបណ្ដាប្រទេសខាងអឺរ៉ុប ហើយបានអញ្ជើញទៅអឺរ៉ុប។ នៅទីនោះ លោកបានដើរធ្វើបឋកថាអំពីការពិសោធន៍គ្រប់ច្រកល្ហក។ គឺជាសម័យមាសនៃជីវិតរបស់ *ហ៊ីដេយោ*។

(៥) ពីរឆ្នាំក្រោយមក លោកបានធ្វើមាតុភូមិនិវត្តន៍ បន្ទាប់ ពីបានបែកចេញចោលអស់រយៈពេល១៦ឆ្នាំមក ។

នៅប្រទេសជប៉ុន *ហ៊ីដេយោ* បានទទួលការស្វាគមន៍ដ៏អ៊ឹកធឹកពីពិភពវិជ្ជាពេទ្យជប៉ុន ហើយបានទទួលសញ្ញាប័ត្រវេជ្ជបណ្ឌិតពីសាកលវិទ្យាល័យ *ក្យូតុ* និងសញ្ញាប័ត្របណ្ឌិតវិទ្យាសាស្ត្រវិជ្ជាពីសាកលវិទ្យាល័យតូក្យូ ។

រូបខ្ញុំបានជួបនឹងលោកបណ្ឌិត *ណូហ្គូជី ហ៊ីដេយោ* ជាដំបូងបង្អស់នៅពេលនោះ។ នៅឆ្នាំនោះ បណ្ឌិត *គីតាសាតូ* បានលាលែងពីវិជ្ជាស្ថានជម្ងឺឆ្លង ហើយកំពុងតែប្រុងប្រៀបរៀបចំកសាងវិជ្ជាស្ថាន *គីតាសាតូ*។ សាវ័កប៉ុន្មាននាក់របស់លោកបណ្ឌិត *គីតាសាតូ* ដែលបានលាលែងពីវិជ្ជាស្ថានជាមួយនឹងលោកដែរ កំពុងតែធ្វើការសិក្សាស្រាវជ្រាវដ៏សែនអផ្សុកហប់ដង្ហើម នៅក្នុងសួន "សំរាកថែសុខភាព" របស់បណ្ឌិត *គីតា សាតូ*។

*ណូហ្គូជី* ដែលមិនបានភ្លេចគុណលោកបណ្ឌិត *គីតាសាតូ* ដែលកំពុងតែមានការលំបាកច្រើន បានទៅលួងលោមលើកទឹកចិត្តលោក។ រួចហើយបាន មានប្រសាសន៍លើកទឹកចិត្តបុគ្គលិកពេទ្យ ដែលធ្វើការនៅ ក្នុងបន្ទប់ស្រាវជ្រាវ ថា ៖

-ខ្លួនខ្ញុំនេះក៏ជាសហការីម្នាក់របស់ប្អូនៗដែរ។ សុំប្អូនៗខិតខំជាមួយខ្ញុំ។

ខ្លួនខ្ញុំបានឮប្រសាសន៍នេះផ្ទាល់នឹងត្រចៀក ហើយមានអារម្មណ៍រំភើបយកតែម៉ែនទែន ចំពោះទឹកចិត្តពុះកញ្ជ្រោលរបស់លោក។

ខ្ញុំចាំថា បណ្ឌិត *ណូហ្គូជី ហ៊ីដេយោ* មានការចាប់អារម្មណ៍ទៅលើ *ស្ពីរ៉ូហេតា* (spirochaeta) នៃមេរោគជម្ងឺ *វ៉ាយល៍* ដែលរកឃើញដោយបណ្ឌិត *អ៊ីណាដា* ហើយលោកចង់ទៅពិនិត្យមើលផ្ទាល់ដល់ទីកន្លែង ខ្ញុំក៏ជូនដំណើរលោកទៅ។

សម័យនោះ ប្រទេសជប៉ុនកំពុងតែផ្តើលស្រាវជ្រាវ *ស្ពីរ៉ូហេតា* (spirochaeta)។ ក្រៅពី *ស្ពីរ៉ូហេតា* នៃជម្ងឺ

*វ៉ាយល៍* មានការរកឃើញ*ស្ពីរ៉ូហេតា* ពិសកណ្តុរ ហើយម្តង នោះ មានការរកឃើញរហូតដល់ទៅ*ស្ពីរ៉ូហេតា* នៃមេរោគ គ្រុន "Typhus" ដែលនាំឱ្យចេញកន្ទួល និង "ជម្ងឺឆ្លងសម្ពាធ ឈាមទាបរបស់សេះ" ជាដើមថែមទៅទៀត។

*ហ៊ីដេយោ* បានយកឯកសារស្រាវជ្រាវពី*ស្ពីរ៉ូហេតា* ទាំង នេះទៅស្រុកអាមេរិកវិញ។ ដោយសារតែលោកធ្លាប់មាន ទំនាក់ទំនងយ៉ាងជ្រៅ ទៅលើការស្រាវជ្រាវពូជ*ស្ពីរ៉ូហេតា* ផង លោកក៏មានការចង់ដឹងពីការសិក្សាស្រាវជ្រាវពី*ស្ពីរ៉ូហេតា* នេះនៅប្រទេសជប៉ុនសំបើមដែរ។ ខ្ញុំយល់ថា *ស្ពីរ៉ូហេតា* នៃ គ្រុនខាន់លឿង ដែល*ហ៊ីដេយោ* រកឃើញ ក្រោយពីការធ្វើ ដំណើរមកជប៉ុន មានទំនាក់ទំនងជាមួយគ្នា។

(៦) នៅឆ្នាំ១៩១៨ *ហ៊ីដេយោ*បានធ្វើដំណើរទៅប្រទេស *អេគ័រឌ័រ* ដើម្បីស្រាវជ្រាវខាន់លឿង។ ការស្រាវជ្រាវនេះ ហើយ ដែលបានផ្តាច់ជីវិតរបស់លោក។ លោកបានប្រមែ ប្រមូលផ្លែផ្កា នៃការសិក្សាស្រាវជ្រាវ នៅប្រទេស*អេគ័រឌ័រ*

ហើយបានធ្វើរបាយការផ្សព្វផ្សាយថា ជាមេរោគគ្រុនខាន់លឿង តែនោះជា *ស្ពីរ៉ូហេតា* មួយបែបតែប៉ុណ្ណោះ ។

រហូតមកដល់ពេលនោះ អ្នកសិក្សាស្រាវជ្រាវពីរោគខាន់លឿង បានកំណត់ថា មេរោគនេះជាអតិសុខុមប្រាណដ៏តូចឆ្មារជ្រុលហួសហេតុ ដែលគេមិនអាចពិនិត្យឃើញបានតាមអតិសុខុមទស្សន៍ឡើយ ។ *ណូហ្គូជី* បានប្រែក្រឡាប់គំនិតនេះ ហើយបានប្រកាសបង្ហាញប្រាប់ពិភពលោកថា *ស្ពីរ៉ូហេតា* ជាមេរោគនៃជម្ងឺ ។

ចំឡែកអ្វី *ស្ពីរ៉ូហេតា*នៃខាន់លឿងនេះ ដូចគ្នានឹង*ស្ពីរ៉ូហេតា*នៃជម្ងឺ *វ៉ាយល៍* របស់ជប៉ុនសែនដូច ។ ការប្រកាសនេះ ដំបូងមានមនុស្សជាច្រើនទទួលស្គាល់ទ្រឹស្តីរបស់ *ណូហ្គូជី* ប៉ុន្តែដល់ក្រោយមក គំនិតជំទាស់ជាច្រើនបានកើនឡើង ។ មនុស្សទាំងឡាយគិតថា របៀបសិក្សារបស់ *ហ៊ីដេយ៉ោ* ត្រឹមត្រូវ ប៉ុន្តែគ្រឿងផ្សំពីដើមដំបូងមកមានការភ័ន្តច្រឡំ ។ មានពាក្យចចាមអារាមថា នៅពេលស្រាវជ្រាវរោគគ្រុនខាន់

លឿងនៅ*អេត័រឌ័រ* អ្នកជំនួយបានច្រឡំយកគ្រឿងផ្សំនៃការពិសោធន៍ជម្ងឺ*វ៉ាយល៍* ដែលកើតឡើងនៅ*អេត័រឌ័រ*មកឱ្យ*ហ៊ីដេយោ* ធ្វើការពិសោធន៍ ទើបបានជាមានការច្រឡំបែបនេះកើតឡើង។

រឿងនេះស្លេះត្រឹមនេះចុះ នៅ*អេត័ឌ័រ* ការរកឃើញ*ស្ពីរ៉ូហេតា* នៃរោគគ្រុនខាន់លឿង បានធ្វើឱ្យអ្នកស្រុកទូទាំងប្រទេសសប្បាយ ហើយសរសើរលោកជាខ្លាំង។ គេបានបំពាក់ឱ្យ*ណូហ្គូជី* នូវសក្តិទាហានដ៏ខ្ពង់ខ្ពស់បំផុត ហើយព្រមទាំងដាក់ឈ្មោះវិថីមួយនៃទីក្រុងថា "វិថី*ណូហ្គូជី ហ៊ីដេយោ*" ទៅទៀត។

*ណូហ្គូជី*សប្បាយចិត្ត ត្រឡប់មកញូវយ៉កវិញ ហើយត្រូវនឹងពេលនោះ ខ្ញុំនៅវិជ្ជាស្ថាន*រ៉ុកហ្វេល័រ* ខ្ញុំក៏បានជួបលោកជាលើកទី២។

*ល្វូដជី* ជឿជាក់ឥតចម្ងល់ទៅលើគំរកឃើញរបស់លោក ។ នៅពេលដែលខ្ញុំចោទជាសំនួរឥតក្រែងទៅលើលោក១ ក៏ឆ្លើយថា ៖

-បើយើងចេះតែជឿ អ្វីដែលអ្នកស្រាវជ្រាវមុនៗសរសេរវិជ្ជាសាស្ត្រ នឹងមិនមានការលូតលាស់ទៅមុខទេ ។

បន្ទាប់មក នៅពេលដែលកំសួលទៅលើទ្រឹស្តី*ស្ទីវ៉ូហេតា* រោគគ្រុនខាន់លឿងរបស់*ល្វូដជី* បានចុះខ្សោយ ក៏លេចឮពាក្យចចាមអារាមមកថា នៅខាងមាត់សមុទ្រខាងលិចនៃអាហ្វ្រិក ជម្ងឺគ្រុនខាន់លឿងបានឆ្លងរាលដាល ។ ដោយសារតែវិជ្ជាស្ថាន*រ៉ុកហ្វេល័រ* ព្រមទាំង*ល្វូដជី*ផ្ទាល់ បានជ្រុលប្រកាសថា មេរោគនៃជម្ងឺ ជា*ស្ទីវ៉ូហេតា* គេក៏ត្រូវទទួលខុសត្រូវ ហើយ*ល្វូដជី* ក៏ចេញទៅប្រយុទ្ធនឹងជម្ងឺគ្រុនខាន់លឿងនៅទីដ៏ឆ្ងាយ ឯទឹកដីដែលជនជាតិអង់គ្លេសត្រួតត្រាគឺ *ហ្គោលដ៍កូស្ត* នោះទៅ ។

ការរៀបចំត្រៀមធ្វើការសិក្សារពិសោធន៍ បានល្អសព្វគ្រប់ឥតចន្លោះ ហើយ*ល្វាំងជី* ក៏ចេញដំណើរទៅ។ ក៏ប៉ុន្តែ *ស្ពីរ៉ូហេតា* ដែលគេចង់បាននោះ រកមិនចេះឃើញសោះ។ មិនត្រឹមតែប៉ុណ្ណោះ ភាពគ្មានប្រសិទ្ធភាពនៃថ្នាំចាក់បង្ការ ដែល*ល្វាំងជី* ខ្លួនឯងបានធ្វើនោះ ក៏ត្រូវបានបញ្ជាក់ដោយការពិសោធន៍នៃរូប*ល្វាំងជី* ខ្លួនឯងផ្ទាល់ដែរ។

លោក*ល្វាំងជី* បានត្រូវជម្ងឺគ្រុនខាន់លឿងមែនទែនញាំញីហើយចុងបញ្ចប់ ក៏ទទួលមរណភាពទៅ។ សំរេចសំរួមទៅគំនិតដែលអ្នកសិក្សាស្រាវជ្រាវពីមុនឯនោះទេ ដែលត្រឹមត្រូវ។ ពោលគឺថា មេរោគនៃជម្ងឺគ្រុនខាន់លឿងនេះជាវីរុសជាអតិសុខុមប្រាណដ៏តូចឆ្មារដែលចំឡងដោយមូស។ មុនពេលចេញទៅសមរភូមិអាហ្វ្រិកបន្តិច ខ្ញុំបានជួបនឹងលោកជាលើកទី៣។ លោកបាននាំខ្ញុំដើរមើលក្រោលសត្វ នៃវិជ្ជាស្ថាន*រ៉ុកហ្វេល័រ*។ ពេលនោះ លោកកំពុងតែធ្វើការពិសោធន៍ជម្ងឺឆ្លងភ្នែកឡើងបាយទៅលើសត្វ*សូវចូវ*។ ខ្ញុំបាន

គិតថា ហេតុតែឈ្មោះថាបណ្ឌិត*ល្វាំងជី* ទោះចង់ធ្វើការពិសោធន៍លើសត្វដ៏មានតម្លៃថ្លៃថ្លាប៉ុនណា ក៏អាចធ្វើយ៉ាងធូរដោយសេរីបានដែរ ។

*ល្វាំងជី* បានចាប់ដៃសត្វ*ស្វាវ៉ូវ* បណ្ដើរ ព្រលាត់ត្របកភ្នែកវាបណ្ដើរ ដើម្បីបង្ហាញរូបភាពនៃជម្ងឺភ្នែកឡើងបាយដល់ខ្ញុំ ។ រួចហើយ លោកក៏និយាយថា បើការពិសោធន៍នៅទីនេះបានជោគជ័យ លោកនឹងទៅជប៉ុន ហើយចង់រំលើងឱ្យអស់នូវជម្ងឺនេះពីស្រុកអាស៊ី ។ ប៉ុន្តែ គោលបំណងនេះមិនបានសំរេចផង ជីវិតលោកក៏ចប់មុននោះនៅអាហ្វ្រិកទៅ ។

(៧) ពាក់ព័ន្ធទៅនឹងជម្ងឺគ្រុនខាន់ស្លាក់ *ហ៊ីដេយោ* បានទទួលបរាជ័យមែន ប៉ុន្តែការស្រាវជ្រាវទៅលើ*ស្ពីរ៉ូហេតា*របស់*ល្វាំងជី*សំបើមអស្ចារ្យមែន ។

ការពិសោធន៍*ស្ពីរ៉ូហេតា* នៃស្វាយប្រមេះឆ្លងទៅលើសត្វ "ការចិញ្ចឹមបរិសុទ្ធ" នៃមេរោគនោះ ការធ្វើទឹកថ្នាំ (*លូអេទីន*) សំរាប់ពិនិត្យរោគដែលជាលទ្ធផលបានពីការចិញ្ចឹមនោះ

របៀបពិនិត្យឈាម សេរ៉ូម ស្វាយប្រមេះ ព្រមទាំងការរក ឃើញវិកលស្ពឹក *ស្ពីរ៉ូហេតា* ស្វាយប្រមេះដែលមាននៅក្នុង ក្រឡារបេងខួរឆ្អឹង ជាការងារដ៏ប្រសើរអស្ចារ្យ ។ វិកលស្ពឹក និងរបេងខួរឆ្អឹង គឺជាជម្ងឺសរសៃប្រសាទដែលកើតព្រមគ្នា ជាមួយនឹងស្វាយប្រមេះ ហើយដែលក្រុមជំនុំសិក្សាស្រាវ ជ្រាវវិជ្ជាពេទ្យ តែងតែមានការជឿងឆ្ងល់អំពីទំនាក់ទំនង របស់វាជាមួយនឹងមេរោគនៃជម្ងឺស្វាយប្រមេះ ។ តើជម្ងឺនេះ បណ្តាលមកពីពិសនៃជម្ងឺស្វាយប្រមេះតែឯកឯង ឬក៏ *ស្ពីរ៉ូ ហេតា* ខ្លួនឯងតែឯងនេះជាអ្នកបង្ក គឺជាបញ្ហាដ៏ធំ ដែល ពិភពវេជ្ជវិទ្យាកំពុងតែពិបាកសំរេច ។ *ណូហ្គូជី* បានសន្និដ្ឋាន ថា ប្រសិនបើ*ស្ពីរ៉ូហេតា* ផ្ទាល់ ជាអ្នកបង្កបង្កើតនោះ ច្បាស់ ជាមាន*ស្ពីរ៉ូហេតា* នៅក្នុងខួរក្បាល និងខួរឆ្អឹងមិនខាន ឡើយ ។

យោលទៅតាមការសន្និដ្ឋាននេះ *ណូហ្គូជី* បានធ្វើគំរូខួរ ក្បាល ខួរឆ្អឹងនៃអ្នកជម្ងឺដែលកើតវិកលស្ពឹក និងរបេងខួរ

ឆ្អឹង ហើយតែងតែពិនិត្យយ៉ាងល្អិតល្អន់តាមអតិសុខុមទស្សន៍។ ធ្វើការនៅតែវិជ្ជាស្ថានទទេ មិនគ្រប់គ្រាន់ទេ *ល្វូងជី* ស្ពាយអតិសុខុមទស្សន៍យកមកផ្ទះ ហើយខិតខំពិនិត្យស្រាវជ្រាវភ្លេចបាយភ្លេចទឹក។ គឺជាការងារដ៏លំបាកមហាសែនលំបាក។ តើអង្កាល់ទៅទើបគេអាចរកឃើញ *ស្ពីរ៉ូហេតា* ដែលជាគោលបំណងរបស់គេនោះ? គឺជាការងារមួយដែលមើលកោះត្រើយមិនឃើញឡើយ តែគេត្រូវតែបន្តការងារនេះជារៀងរាល់ថ្ងៃដដែលៗ។ ការខិតខំឆ្លុះមើលទៅក្នុងអតិសុខុមទស្សន៍ ប្រកបដោយអំណត់យ៉ាងយូរនេះបានផ្តល់ផ្លែផ្កាហើយ។ *ល្វូងជី* បានរកឃើញ *ស្ពីរ៉ូហេតា*។

ដោយសារគំរកគំហើញនេះ បញ្ហាដ៏លំបាករហូតមកដល់ពេលនេះក៏ត្រូវបានដោះស្រាយ។ មិត្តដែលរស់នៅផ្ទះជិតនោះបានឃើញបានដឹងថា នៅពេលនោះ លោកបានស្រែកហ៊ោរត្រេកអរសប្បាយជាខ្លាំង។

(៨) ជនជាតិជប៉ុនទាំងឡាយមានមោទនភាពណាស់ដោយនៅក្នុងវិជ្ជាស្ថានដ៏ល្បីក្នុងពិភពវេជ្ជសាស្ត្រអាមេរិក គឺ វិជ្ជាស្ថាន *រ៉ុកហ្វេល័រ* មាន*ណូហ្គូជី* ជាជនជាតិជប៉ុនដូចខ្លួនធ្វើការងារ មានយសសក្តិ ដល់ទៅប្រធានកាប៊ីណេ។

ដូច្នេះ គ្មានគ្រូពេទ្យម្នាក់ណា ដែលថាទៅដល់ញូវយ៉ក ហើយមិនបានជួប*ណូហ្គូជី*ទេ។

ចំពោះ*ណូហ្គូជី* គាត់មិនដឹងជាមានការរំខានយ៉ាងណាទេ។ ប្រហែលជាអញ្ចឹងហើយ បានជានៅពេលដែលអ្នកដំណើរធម្មតាខ្លះទៅសុំជួប *ណូហ្គូជី* តែងតែធ្វើមុខក្រញូវ មិនទទួលភ្ញៀវ ដែលជាហេតុនាំឱ្យជប៉ុនជាច្រើននិយាយអាក្រក់ពីលោក។

ប៉ុន្តែ គួរតែដឹងថា យើងដែលគ្មានការអ្វីធំដុំផងក៏ចេះតែទៅសុំជួបគេឯនេះទេ ដែលខុសនោះ។ ពីព្រោះយើងទៅរំខានការស្រាវជ្រាវ ដែលចំពោះគេសូម្បីតែមួយរយៈខ្លី ក៏មានតម្លៃកាត់ថ្លៃមិនបានដែរ។ យើងមិនដឹងពីកំហុសយើង

ហើយបែរជានិយាយអាក្រក់ពីគេ នេះគឺជាទង្វើអាក្រក់មួយតែម្តង។

នៅក្រោយពេលដែល*ណូហ្គូជី* ទទួលអនិច្ចកម្មទៅ កេរ្តិ៍ឈ្មោះក្រអូបរបស់លោកបានឡើងរន្ទឺទាំងនៅអាមេរិក និងនៅជប៉ុន។ គេបានសាងសង់អាគារអនុស្សាវរីយ *ណូហ្គូជី* ដែលមានដាក់របស់ជាកេរ្តិ៍ដំណែលលោកជាច្រើន ហើយសព្វថ្ងៃនេះ អាគារនេះមានប្រយោជន៍ជាច្រើនចំពោះការអប់រំសង្គម។

**ចប់**

# ប្រវត្តិរបស់ណូងូជី ហ៊ីដេយោ

| | | |
|---|---|---|
| ឆ្នាំ១៨៧៦ | | ថ្ងៃ៩វិច្ឆិកាកើតនៅភូមិ អ្វូគីណាជីមូរ៉ា មាតាបិតាដាក់ឈ្មោះសេសាគីឱ្យ |
| ឆ្នាំ១៨៧៨ | អាយុ២ឆ្នាំ | លូនចូលជើងក្រាន រលាកដៃខាងឆ្វេងជាដំណំ |
| ឆ្នាំ១៨៨៣ | អាយុ៧ឆ្នាំ | ខែ មេសា ចូលរៀនសាលាបឋមសិក្សាមីតស៊ុវ៉ា |
| ឆ្នាំ១៨៨៩ | អាយុ១៣ឆ្នាំ | លោកគ្រូកុបាយ៉ាស៊ីបានណែនាំឱ្យទៅរៀនសាលាបឋមសិក្សាជាន់ខ្ពស់ |
| ឆ្នាំ១៨៩២ | អាយុ១៦ឆ្នាំ | ទៅព្យាបាលដៃឆ្វេងនៅមន្ទីព្យាបាលកៃយោ នៅវ៉ាកាម៉ាតស៊ឹ |
| ឆ្នាំ១៨៩៣ | អាយុ១៧ឆ្នាំ | ចេញពីសាលាបឋមសិក្សាជាន់ខ្ពស់ហើយទៅសុំរៀនមន្ទីព្យាបាលកៃយោ |
| ឆ្នាំ១៨៩៦ | អាយុ២០ឆ្នាំ | ប្រឡងសញ្ញាប័ត្រពេទ្យគន្លាក់ទី១ ជាប់ដោយបានលោកជីវ៉ាគីជួយ បាន ចូលធ្វើការនៅមន្ទីព្យាបាលធ្មេញណាកាយ៉ាម៉ាបណ្ដើររៀនបណ្ដើរ |
| ឆ្នាំ១៨៩៧ | អាយុ២១ឆ្នាំ | ប្រឡងជាប់សញ្ញាប័ត្រពេទ្យគន្លាក់ទី២ជាប់ចូលធ្វើគ្រូនៅមន្ទីព្យាបាល ធ្មេញណាកាយ៉ាម៉ា ។ខែ វិច្ឆិកាទៅជាអ្នកជំនួយការនៅមន្ទីពេទ្យជូនតិនដូ |
| ឆ្នាំ១៨៩៨ | អាយុ២២ឆ្នាំ | ធ្វើការជាអ្នកជំនួយបណ្ឌិតគីតាសាតូ នៅវិជ្ជាស្ថានជម្ងឺឆ្លង ប្តូរឈ្មោះជា ហ៊ីដេយោ |
| ឆ្នាំ១៨៩៩ | អាយុ២៣ឆ្នាំ | បានធ្វើជាអ្នកជូនដំណើរលោកបណ្ឌិតហ្វីលេកស្នាដែលមកជប៉ុនធ្វើទស្សន កិច្ច ។ ខែកញ្ញាបានរកឃើញអ្នកជម្ងឺប៉េស្ត ក៏មានឈ្មោះល្បីល្បាញ ។ |
| ឆ្នាំ១៩០០ | អាយុ២៤ឆ្នាំ | ខែធ្នូ ធ្វើដំណើរទៅអាមេរិក ដោយរំពឹងលើលោកបណ្ឌិតហ្វីលេកស្នា |
| ឆ្នាំ១៩០១ | អាយុ២៥ឆ្នាំ | ខែមករា ទៅជាអ្នកជំនួយការរបស់បណ្ឌិតមីចឈែល ស្រាវជ្រាវពិសពស់ |
| ឆ្នាំ១៩០៣ | អាយុ២៧ឆ្នាំ | ខែតុលា ទៅជាអ្នកជំនួយការនៃវិជ្ជាស្ថានការណេងី ហើយបានទៅ សិក្សានៅវិជ្ជាស្ថានជាតិខាងឈាមនៅប្រទេសដាណឺម៉ាក |
| ឆ្នាំ១៩០៤ | អាយុ២៨ឆ្នាំ | ខែតុលា ចេញពីដាណឺម៉ាកត្រឡប់ទៅញូវយ៉កវិញ ហើយទៅជាអ្នក ជំនួយថ្នាក់លេខ១នៅវិជ្ជាស្ថានរ៉ុកហ្វេល័រ |
| ឆ្នាំ១៩១១ | អាយុ៣៥ឆ្នាំ | បានទទួលជោគជ័យក្នុងការចិញ្ចឹមបរិសុទ្ធនៃស្ពីរ៉ូហេតារោគប្រមេះ ដែលរហូតមកដល់ពេលនេះមិនទាន់មានអ្នកណាម្នាក់បានទទួលជោគ ជ័យនៅឡើយ ។ ខែឧសភា ទទួលសញ្ញាប័ត្រវេជ្ជបណ្ឌិតជប៉ុន |

| | | |
|---|---|---|
| ឆ្នាំ១៩១២ | អាយុ៣៦ឆ្នាំ | ខែមេសារៀបការជាមួយមេរី ដាជីស |
| ឆ្នាំ១៩១៣ | អាយុ៣៧ឆ្នាំ | រកឃើញស្ពីរ៉ូហេតា រោគប្រមេះដែលនៅក្នុងឈាម នៃអ្នកជម្ងឺរោគវិកលស្តីក និងជម្ងឺប្រមេះខួរឆ្អឹង ។<br>ខែកញ្ញាចេញដំណើរទៅធ្វើបឋកថាឯប្រទេសទាំងឡាយនៅអឺរ៉ុបហើយនៅខែវិច្ឆិកាត្រឡប់មកអាមេរិកវិញ ។ |
| ឆ្នាំ១៩១៤ | អាយុ៣៨ឆ្នាំ | ទៅជាសមាជិកពេញក្របខណ្ឌនៃវិជ្ជាស្ថានរ៉ុកហ្វេល័រ ។ ខែមេសាទទួលសញ្ញាប័ត្របណ្ឌិតខាងវិទ្យាសាស្ត្រ ។ |
| ឆ្នាំ១៩១៥ | អាយុ៣៩ឆ្នាំ | ខែមេសា មកជប៉ុនដើម្បីទទួលមេដាយ អុងស៊ុស្វូ ពីតេកុកឹងាគឺស៊ុអ៊ីងរបស់ក្រសួង អប់រំជាតិជប៉ុន ។ ខែវិច្ឆិកាត្រឡប់ទៅអាមេរិកវិញ ។ |
| ឆ្នាំ១៩១៨ | អាយុ៤២ឆ្នាំ | ខែកក្កដា ទៅប្រទេសអេគ័ឌ័រ នៅអាមេរិកឡាទីន ។រកឃើញមេក្រុបនៃរោគគ្រុនលឿង ។ ខែវិច្ឆិកា មាតាគឺអ្នកស៊ីកាទទួលមរណភាព ។ |
| ឆ្នាំ១៩២៣ | អាយុ៤៧ឆ្នាំ | បិតាឈ្មោះសាយោស៊ីគេ ទទួលមរណភាព ។បានទៅជាសមាជិកនៃតេកុកឹងាគឺស៊ីអ៊ីង ដែលជាកិត្តិយសដ៏ខ្ពង់ខ្ពស់សំរាប់អ្នកស្រាវជ្រាវជប៉ុន ។ |
| ឆ្នាំ១៩២៧ | អាយុ៥១ឆ្នាំ | បានបង្ហាញឱ្យគេដឹងពីមេរោគត្រាក់កូម( ភ្នែកឡើងបាយ) ។ ខែតុលាចេញដំណើរទៅអាហ្វ្រិក ។ |
| ឆ្នាំ១៩២៨ | អាយុ៥២ឆ្នាំ | ថ្ងៃ២១ខែឧសភា ទទួលមរណភាពដោយ ជម្ងឺគ្រុនលឿងនៅអក្ក្រាប្រទេសអាហ្វ្រិក |



ណូហ្គូជីហ៊ីដេយោ



おまイの。しせにわ。みなたまけました。わたくしも
よろこんでをりまする。なかたの
かんのんさまに。さまにねん。よこもりを。い
たしました。べん京なぼでも。きりかない
。いぼし。ほわこまりをりますか。おまい
か。きたならば。もしわけかてきまし
よ。はるになるト。みなほかいドに
いてしまいます。わたしも。こころ
ぼそくありまする。ドかはやく
きてくたされ。かねを。もろたこトたれ
にもきかせません。それをきかせるト
みなのまれてしまいます。はやくき
てくたされ。はやくきてくたされ
はやくきてくたされ。はやくき
てくたされ。

សំបុត្រពីអ្នកស៊ីកាជាមាតា។ មាតារបស់ហ៊ីដេយោមិនដែលបានទៅរៀននៅសាលាទេ ប៉ុន្តែដោយបំណាច់ដែលនឹកកូនពេកក៏ខិតខំរៀនអក្សរហើយសរសេរឱ្យកូនឆាប់មកជួប

| | | |
|---|---|---|
| ឆ្នាំ១៩១២ | អាយុ៣៦ឆ្នាំ | ខែមេសារៀបការជាមួយមេរី ដាជីស |
| ឆ្នាំ១៩១៣ | អាយុ៣៧ឆ្នាំ | រកឃើញស្ពីរ៉ូហេតា រោគប្រមេះដែលនៅក្នុងឈាម នៃអ្នកជម្ងឺរោគវិកលស្តីក និងជម្ងឺប្រមេះខួរឆ្អឹង ។<br>ខែកញ្ញាចេញដំណើរទៅធ្វើបឋកថាឯប្រទេសទាំងឡាយនៅអឺរ៉ុបហើយនៅខែវិច្ឆិកាត្រឡប់មកអាមេរិកវិញ ។ |
| ឆ្នាំ១៩១៤ | អាយុ៣៨ឆ្នាំ | ទៅជាសមាជិកពេញក្របខណ្ឌនៃវិជ្ជាស្ថានរ៉ុកហ្វេល័រ ។ ខែមេសាទទួលសញ្ញាប័ត្របណ្ឌិតខាងវិទ្យាសាស្ត្រ ។ |
| ឆ្នាំ១៩១៥ | អាយុ៣៩ឆ្នាំ | ខែមេសា មកជប៉ុនដើម្បីទទួលមេដាយ អុងស៊ុសូ ពីតេកុកឹងាគីស៊ុអ៊ីង របស់ក្រសួង អប់រំជាតិជប៉ុន ។ ខែវិច្ឆិកាត្រឡប់ទៅអាមេរិកវិញ ។ |
| ឆ្នាំ១៩១៨ | អាយុ៤២ឆ្នាំ | ខែកក្កដា ទៅប្រទេសអេគ័ឌ័រ នៅអាមេរិកឡាទីន ។រកឃើញមេក្រុបនៃរោគគ្រុនលឿង ។ ខែវិច្ឆិកា មាតាគឺអ្នកស៊ីកាទទួលមរណភាព ។ |
| ឆ្នាំ១៩២៣ | អាយុ៤៧ឆ្នាំ | បិតាឈ្មោះសាយោស៊ីគេ ទទួលមរណភាព ។បានទៅជាសមាជិកនៃតេកុកឹងាគីស៊ីអ៊ីង ដែលជាកិត្តិយសដ៏ខ្ពង់ខ្ពស់សំរាប់អ្នកស្រាវជ្រាវជប៉ុន ។ |
| ឆ្នាំ១៩២៧ | អាយុ៥១ឆ្នាំ | បានបង្ហាញឱ្យគេដឹងឮពីមេរោគត្រាក់កូម( ភ្នែកឡើងបាយ) ។ ខែតុលាចេញដំណើរទៅអាហ្វ្រិក ។ |
| ឆ្នាំ១៩២៨ | អាយុ៥២ឆ្នាំ | ថ្ងៃ២១ខែឧសភា ទទួលមរណភាពដោយ ជម្ងឺគ្រុនលឿងនៅអក្ករាប្រទេសអាហ្វ្រិក |



ណូហ្គូជីហ៊ីដេយោ



おまイの。しせにわ。みなたまけました。わたく
しもよろこんでをりまする。なかた
のかんのんさまに。さまにねん。よこもりを
たしました。べん京なぼでも。きりがない
。いぼし。ほわこまりをりますか。おまい
か。きたならば。もしわけかてきまし
よ。はるになるト。みなほかいドに
。いてしまいます。わたしも。こころぼ
そくありまする。ドかはやく
きてくだされ。かねをもろたこトたれ
にもきかせません。それをきかせるト
みなのまれて。しまいます。はやくき
てくたされ。はやくきてくたされ
はやくきてくたされ。はやくきて
くたされ。

សំបុត្រពីអ្នកស៊ីកាជាមាតា។ មាតារបស់ហ៊ីដេយោមិនដែលបានទៅរៀននៅសាលាទេ ប៉ុន្តែដោយបំណាច់ដែលនឹកកូនពេកក៏ខិតខំរៀនអក្សរហើយសរសេរឱ្យកូនឆាប់មកជួប



ផ្ទះកំណើតហ៊ីដេយោ



ទិដ្ឋភាពនៅក្នុងផ្ទះ



លោកគ្រូកុបាយ៉ាសុ



សេសាគីថតក្រោយពេលវះកាត់ដៃ



អ្នកស៊ីកា ជាមាតា



ហ៊ីដេយោថតជាមួយមាតាទាំងពីរៈរូបខាងឆ្វេងម្តាយកំណើតរូបខាងស្តាំម្តាយចញ្ចឹម ដែលជា ភរិយារបស់លោកគ្រូកុបាយ៉ាស៊ី។



ហ៊ីដេយោថតជាមួយនឹងលោកគ្រូពេទ្យ
វ៉ាតាណាបេ



ហ៊ីដេយោថតជាមួយនឹងលោកគ្រូពេទ្យជីវ៉ាគី



ហ៊ីដេយោថតជាមួយនឹងអ៊ីស៊ីតស៊ីកា



បណ្ឌិតមីចឆែល( Dr Weir Mitchell )



បណ្ឌិតហ្វីលេកស្នា (Dr Simon Flexner)



អតិសុខុមទស្សន៍នៅវិជ្ជាស្ថានរ៉ុកហ្វេល័រ



គំរូពស់សំរាប់ការស្រាវជ្រាវ



នាមប័ណ្ណ




ហ៊ីដេយោកាលនៅជាអ្នកជំនួយការនៅសាកលវិទ្យាល័យពែនស៊ីលវ៉ានីញ៉ា

ហ៊ីដេយោស្រាវជ្រាវនៅអាមេរិក ឆ្នាំ១៩០១



អតិសុខុមទស្សន៍ដែលហ៊ីដេយោតែងតែប្រើ



វិជ្ជាស្ថានរ៉ុកហ្វេល័រ



ហ៊ីដេយោនៅក្នុងបន្ទប់ពិសោធន៍

ភូគោលដែលតាំងនៅលើតុក្នុងបន្ទប់ពិសោធន៍








ផែនទីទីក្រុងញូវយ៉ក

ការងារស្រាវជ្រាវរបស់ហ៊ីដេយោ



អាវកុំប្លេដែលហ៊ីដេយោស្រឡាញ់





បណ្ឌិតម៉ាតស៊ិន (Dr Thorwald Madsen)








ឯកសារដែលហ៊ីដេយោតែងប្រើសំរាប់ពន្យល់ពីការស្រាវជ្រាវរបស់ខ្លួន។



គ្រឿងឥស្សរិយយសដែលបានទទួលពីព្រះចៅអធិរាជ

ឯកសណ្ឋានវេជ្ជបណ្ឌិតកិត្តិយសដែលបានទទួលពីប្រទេសអេត្យ៉ូពី



ហ៊ីដេយោស្លៀកពាក់ឯកសណ្ឋានទាហានអេត្យ៉ូពី





ពិធីជប់លៀងបដិសណ្ឋារកិច្ចដោយប្រធានាធិបតេយ្យប៉េរូនៅលីម៉ា




ផែនទីអាហ្វ្រិកដែលហ៊ីដេយោយកទៅជាមួយ





លោកវីលីយាំអាលេចសាន់ដា យ៉ាំង

(Mr William Alexander Young)

សំលៀកបំពាក់ដែលហ៊ីដេយោតែងស្លៀកពាក់

នៅបរទេស



ហ៊ីដេយោធ្វើការងារ







គ្រឿងបរិក្ខាពេទ្យនានាដែលហ៊ីដេយោយកទៅអាហ្វ្រិកជាប់នឹងខ្លួន



ហ៊ីដេយោទៅអក្ក្រានៅអាហ្វ្រិកនៅឆ្នាំ១៩២៧

កាសែតញូវយ៉កថែមចុះផ្សាយពីដំណឹងមរណភាព របស់ណូហ្គូជីហ៊ីដេយោ នៅថ្ងៃទី២២ខែឧសភា ឆ្នាំ១៩២៨






កាសែតអាសាហ៊ីជប៉ុនចុះផ្សាយពីមរណភាពហ៊ីដេយោ



គ្រឿងឥស្សរិយយសនានាដែលហ៊ីដេយោបានទទួល




ផ្ទាំងសិលាចារិកនៅមុខផ្ទះកំណើតហ៊ីដេយោ
ឆ្លាក់ដោយខ្លួនឯងផ្ទាល់ពេលវិលត្រឡប់មកនៅឆ្នាំ ១៩១៥
ថា" នីងតាយ " បកប្រែថា សេចក្តីអំណត់ ព្យាយាម ។




តែមប្រើអនុស្សាវរីយ៍រំលឹកហ៊ីដេយោនៅប្រទេសហ្គាណា



រូបគំនូរមាតា



រូបខ្លួនឯង



រដូវព្រឹលធ្លាក់ គូរដោយហ៊ីដេយោ

រូបភាពហ្គឹងថ្កល់





រូបគំនូរដោយហ៊ីដេយោ
នៅឆ្នាំ១៩១៩



រូបស្រះឈូក



រូបមេរីជាភរិយា



រូបប៉មបំភ្លឺកបាល់



រូបគំនូរ
ដែលគូរដោយ
ហ៊ីដេយោ

អ្នកបកប្រែ ៖ ប៉ែន សេដ្ឋារិន កើតនៅភ្នំពេញ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ។ ចេញពីវិទ្យាល័យព្រះយុគន្ធរនៅឆ្នាំ ៧៣ ។ នៅឆ្នាំ៧៣ដដែល ប្រឡងជាប់និស្សិតសាស្ត្រាចារ្យខាងភាសាបារាំងខ្មែរហើយចូលរៀនមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ។ ឆ្នាំ១៩៧៤បានទទួលអាហារូបករណ៍ ពីរដ្ឋាភិបាលជប៉ុន មករៀនខាងគរុវិជ្ជានិងចិត្តសាស្ត្រ ហើយបានទទួលសញ្ញាប័ត្រអនុបណ្ឌិតខាងគរុវិជ្ជា និងចិត្តសាស្ត្រនៅឆ្នាំ១៩៨១ ។ សព្វថ្ងៃជា អ្នកនិពន្ធ, សាស្ត្រាចារ្យភាសាខ្មែរនៅសាកលវិទ្យាល័យអក្សរសាស្ត្របរទេសតូក្យូនិងជាអ្នកសិក្សាស្រាវជ្រាវពីរឿងជាតកខ្មែរ-ជប៉ុន ដើម្បីរៀបចំនិក្ខេបបទបណ្ឌិតនៅសាកលវិទ្យាល័យហូសេ តូក្យូ ។ បាននិពន្ធ,បកប្រែ និងបោះពុម្ពផ្សាយនូវកម្រងអក្សរសិល្បជប៉ុនល្បីៗអក្សរសិល្បជប៉ុននិងបរទេសជាច្រើន ដែលទាក់ទង ទៅនឹងសីលធម៌ សេចក្តីមេត្តា ករុណា បញ្ញា មិត្តភាពនិងទំនុកចិត្តព្រមទាំងទស្សនវិជ្ជាដើម្បីសន្តិភាពជានិច្ចនិរន្ត ជា ភាសាខ្មែរ ។

មេដាយនិងរង្វាន់ដែលបានទទួលនៅប្រទេសជប៉ុនៈ

ឆ្នាំ១៩៩៣មេដាយខួប៣៥ឆ្នាំនៃរដ្ឋបាលក្រុងម៉ាជីដា ឆ្នាំ៩៤រង្វាន់យុវជនប្រសើរនិងមេដាយប្រជាជនល្អនៃក្រុងតូក្យូ ឆ្នាំ២០០៤ រង្វាន់ព្រួជេនស្យាលនៃកាសែតយោមីអ៊ូរីលើកទី១ និងមេដាយផ្សេងៗទៀតជាច្រើន។

នៅប្រទេសកម្ពុជានៅឆ្នាំ៩៧ បានទទួលរង្វាន់ព្រះសីហនុរាជ ចំពោះប្រលោមលោករឿង "ក្រោមមេឃពណ៌ខៀវនៃទីក្រុងតូក្យូ" នៅឆ្នាំ៩៥ បង្កើតមន្ទីរវប្បធម៌នារី ដែលមានបណ្ណាល័យអាចឱ្យចូលអានសៀវភៅខ្មែរនិងជប៉ុននៅបឹងទំពន់ , ភ្នំពេញ។ សូមទាក់ទងមកលេខ ០១២-៣៣៣-៦៤៦ មន្ទីរវប្បធម៌នារី នៃសមាគមជំនួយវប្បធម៌អាស៊ីអាគ្នេយ៍ ស្ថិតនៅ ភូមិចំរើនផល ស្រុកមានជ័យ បឹងទំពន់ ជិតពេទ្យរុស្ស៊ី។

បានតាំងបំណងប្តូរផ្តាច់បរិច្ចាគទ្រព្យធនផ្ទាល់ដើម្បី ឱ្យកូនខ្មែរ អានច្រើន អាចយល់ដឹងពីកាតព្វកិច្ចព្រមទាំងសិទ្ធិហើយអប់រំខ្លួនឱ្យទៅជាពលរដ្ឋចិត្តធម៌ ចេះសណ្តោសគ្នាទៅវិញទៅមក តាមលំនាំព្រះពុទ្ធសាសនា តែមានកម្លាំងកាយនិងចិត្តរឹងប៉ឹងអាចឈរជា សរសរទ្រទ្រង់ ការពារខ្លួននិងប្រទេសជាតិ ជានិច្ចជាកាល។

## ស្តីពី មូលនិធិ The Daido Life Foundation

1. ពេលវេលាកំណើត : ខែមីនា ឆ្នាំ ១៩៨៥
2. ប្រធាន : ណាវតេរី មីយ៉ាតូ Naoteru Miyato
3. អាស័យដ្ឋាន : 1-2-1, Edobori,Nishi-Ku ,Osaka, Japan, 550-0002
4. គោលបំណងៈ ដើម្បីជាអនុស្សាវរីយ៍ខួបគំរប់៨០ឆ្នាំនៃ The Daido Life Insurance Company (ហៅកាត់ថា "Daido Life") មូលនិធិ Daido Life Foundation ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៥ ដោយមានសេចក្តីអនុញ្ញាតិពីរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ក្នុងគោលបំណងចូលរួមវិភាគទានក្នុងអន្តរជាតូបនីយកម្មរបស់ជប៉ុន ឆ្លងកាត់តាមការផ្លាស់ប្តូរវប្បធម៌ រវាងជប៉ុននឹងប្រទេសនានាក្នុងពិភពលោក ព្រមទាំងជំនួយនានា។
5. គំនិតនៃការបង្កើតមូលនិធិ :

   អាជីវកម្មនៃការធានារ៉ាប់រងជីវិត គឺការទាមទារឱ្យមានការរស់នៅជាមួយគ្នាដោយសហត្ថិភាព និងការជួយគ្នាទៅវិញទៅមក ដែលជាទង្វើប្រកបទៅដោយវិចារណញ្ញាណខ្ពស់សំរាប់មនុស្សលោក។ តាំងពីពេលមានរូបរាងមក Daido Life តែងតែធ្វើសកម្មភាពដែលយោលទៅលើឧត្តមគតិនេះ

ហើយឆ្លងកាត់តាមការពង្រីកអាជីវកម្មរបស់ខ្លួនឱ្យបានកាន់តែធំទៅ មូលនិធិនេះបានខិតខំលើកកំពស់សុខមាលភាពប្រជាជន ជាទម្លាប់រៀង១មក។ ទន្ទឹមនឹងគ្នានេះ ដោយឈរលើគំនិតថា "សហគ្រាស គឺជាឧបករណ៍សាធារណៈនៅក្នុងសង្គម" មូលនិធិយើងខ្ញុំបានខិតខំចូលរួមវិភាគទាន ក្នុងការងារផ្តួចផ្តើមនូវការសិក្សារបស់និស្សិត ជំនួយទៅលើការសិក្សាស្រាវជ្រាវវេជ្ជវិជ្ជា និងការងារពិនិត្យសុខភាព ទោះបីជាតិចតួចក៏ដោយ។

នៅឱកាសខួបគំរប់ទី ៨០ ឆ្នាំរបស់ Daido Life នៅឆ្នាំ ១៩៨២ ក្រោយពីបានរិះគិតពីលក្ខណៈ ដែលសហគ្រាសត្រូវតែមានយ៉ាងហ្មត់ចត់មក ដើម្បីប្រតិបត្តនូវគំនិតនេះឱ្យចេញជារូបរាង យើងក៏បានបង្កើតមូលនិធិ Daido Life Foundation។ ការបង្កើតមូលនិធិនេះ មានបំណងឆ្លើយតបទៅនឹងការទាមទារនៃសម័យកាល ដែលឆ្ពោះទៅរកការអភិវឌ្ឍន៍សន្តិភាពពិភពលោក ដែលជាលក្ខណ្ឌសំខាន់បំផុតសំរាប់ការលូតលាស់នៃប្រទេសជប៉ុន។

១. សកម្មភាពសំខាន់ៗ

(១) ការជូនរង្វាន់ "ដៃដូសេម៉េ" ចំពោះការស្រាវជ្រាវអំពីតំបន់ ៖ គឺជារង្វាន់ទៅលើការស្រាវជ្រាវដែលមានលក្ខណៈ

វិទ្យាសាស្ត្រនៃតំបន់នានា ក្នុងពិភពលោកដែលជា គ្រឹះមួយ នៅពេលដែលគេគិតអំពីអន្តរជាតូបនីយកម្ម។ ការងារនេះ បានទទួលការជ្រោមជ្រែងពីសហគមន៍បញ្ញវន្ត។

(២) ការងារបកប្រែ និងបោះពុម្ពផ្សាយ

1. ការបកប្រែនិងបោះពុម្ពអក្សរសិល្ប៍អាស៊ីមកជាភាសាជប៉ុន

(សេរី "អក្សរសិល្ប៍ទំនើបអាស៊ី")

យើងជ្រើសរើសអក្សរសិល្ប៍ទំនើបអាស៊ី (ប្រលោមលោក កំណាព្យ អេសេ្ស រឿងល្ខោន អត្ថបទទិតៀន) ដែលគួរបកប្រែបោះពុម្ពឱ្យជប៉ុនបានស្គាល់ ក្នុងគោលបំណង ឱ្យជប៉ុនយល់ពីស្ថានភាពនៃប្រទេសអាស៊ីបច្ចុប្បន្ន។

2. ការបកប្រែនិងបោះពុម្ពជាភាសាអាស៊ី

(សេរី "ចាប៉ានីស មីរ៉ា")

ក្នុងគោលបំណងឱ្យប្រទេសអាស៊ីនានាស្គាល់ជប៉ុនកាន់តែច្បាស់ យើងបានចាប់ផ្តើមបកប្រែនិងបោះពុម្ពសៀវភៅជប៉ុន ជាភាសាអាស៊ីនានា យ៉ាងសកម្មពីឆ្នាំ១៩៩៩ មក។ ការងារនេះមានបំណងចង់ផ្តល់ជាពតិមានដល់អ្នកសិក្សាស្រាវជ្រាវ និងប្រជាជន អំពីនយោបាយ

សេដ្ឋកិច្ចប្រវត្តិសាស្ត្រ បញ្ហាបរិដ្ឋាន រឿងពិតរបស់វិរបុរសជប៉ុន ជាដើម ដែលជាការពិសោធន៍ ដែលជប៉ុនបានដើររួចមកហើយ ឬមួយក៏ជាដំបូន្មាន ដើម្បីឱ្យបានយល់ពីជប៉ុន។

(៣) របបផ្តល់អាហារូបករណ៍ចំពោះជនបរទេសនៃមូលនិធិវប្បធម៌អន្តរជាតិដៃដូសេម៉េ

តាមរយៈគំរោងផ្តល់អាហារូបករណ៍ចំពោះនិស្សិត មូលនិធិយើងខ្ញុំបានផ្តល់អាហារូបករណ៍ ចំពោះនិស្សិតមហាវិទ្យាល័យ (មានជូនទៅនិស្សិតថ្នាក់អនុបណ្ឌិត ឬបណ្ឌិតដែរ) នៃប្រទេសដែលយើងជួយ ក្នុងគោលបំណងចូលរួបរួមវិភាគទាន ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស នៅបណ្តាប្រទេសអាស៊ីភាគអាគ្នេយ៍។

(៤) ការជូនអំណោយជាសៀវភៅ ឬជាឯកសារជប៉ុន

ជូនអំណោយជាសៀវភៅនិងឯកសារជប៉ុនដល់សាកលវិទ្យាល័យដែលមាននាយកដ្ឋានភាសាជប៉ុននៃបណ្តាប្រទេសនៃអាស៊ីអាគ្នេយ៍ ក្នុងគោលបំណងផ្តួងផ្តើមការអប់រំភាសាជប៉ុន និងការយោគយល់ទៅវិញទៅមក។

## ចំពោះការបោះពុម្ពសេរី "ចាបានីស មីរ៉ា"

ក្នុងគោលបំណងឱ្យបណ្ដាប្រទេសអាស៊ីបានស្គាល់ប្រទេសជប៉ុនកាន់តែច្បាស់ យើងខ្ញុំបានលើកយកអត្ថបទអក្សរសិល្ប៍ និងឯកសារជប៉ុនដែលទាក់ទងនឹងនយោបាយ សេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រជាដើមរបស់ជប៉ុន មកបកប្រែ បោះពុម្ពផ្សាយជាបណ្ដាភាសាអាស៊ី ចាប់តាំងពីឆ្នាំ១៩៩៩មកម្ល៉េះ។ ក្នុងគោលបំណងចង់ឱ្យអ្នកសិក្សាស្រាវជ្រាវ ព្រមទាំងប្រជាជនអាស៊ីទាំងអស់បានស្គាល់កាន់តែច្បាស់ ពីទំរង់នៃនយោបាយរដ្ឋបាល ការលូតលាស់នៃសេដ្ឋកិច្ច និងមាគ៌ាដែលជប៉ុនបានដើររួចមកហើយ ឆ្លងកាត់តាមការអានអក្សរសិល្ប៍ និងឯកសារជប៉ុន ដែលបានបកប្រែទៅជាភាសាជាតិរបស់ប្រទេសនានានេះ។

យើងបានឱ្យឈ្មោះគំរោងបកប្រែ និងបោះពុម្ពផ្សាយនេះថា " ចាប៉ានីស មីរ៉ា " ។

លើកនេះ យើងបានលើកយករឿងពិតរបស់បណ្ឌិត "ណូងូជី ហ៊ីដេយោ" ដែលលោកស្រី សាស្ត្រាចារ្យ ប៉ែន សេដ្ឋារិន បានបកប្រែជាភាសាខ្មែរមកបោះពុម្ព។

ចំពោះមូលនិធិរបស់យើង រឿងនេះគឺជាសៀវភៅទី២ ដែលបានបកប្រែចេញជាភាសាខ្មែរ ។

បណ្ឌិត ណូងូជី ហ៊ីដេយោ មានកំណើតក្នុងគ្រួសារកសិករក្រក្សត់ នៅភូមិភាគល្វឹសាននៃប្រទេសជប៉ុន ។ កាលនៅជាទារកអាយុ២ឆ្នាំ លោកបានរលាកភ្លើង ហើយមានរបួសដៃឆ្វេងជាដំណំ ប៉ុន្តែលោកមិនបានចុះចាញ់ទេ ហើយបានខិតខំតស៊ូជំនះនឹងខ្លួនឯង ទោះជាបរាជ័យក៏មិនចោលទឹកចិត្តដែលប៉ុនប៉ង ហើយតែងតែខិតខំពុះពារសំដៅទៅរកគោលបំណង ដែលមានទំហំធំទៅៗ ជាលំដាប់ ។ ផ្លូវដែលលោកបានត្រួសត្រាយមក មិនមែនមានតែជនជាតិជប៉ុនតែប៉ុណ្ណោះទេ ដែលដឹង តែមានជនជាតិដ៏ច្រើនក្នុងពិភពលោកដឹងឮទូលំទូលាយណាស់ ។ យើងជឿជាក់ថា រឿងនេះអាចផ្តល់ជាគតិដ៏ច្រើនចំពោះមិត្តអ្នកអាន ។

ខែមីនា ឆ្នាំ ២០០៦

មូលនិធិ THE DAIDO LIFE FOUNDATION



DAIDO THE DAIDO LIFE FOUNDATION

មូលនិធិខ្មែរសម្រាប់ការសិក្សា       ករុណាខ្មែរ

គីម វាសនា

បណ្ឌិតប៉ែន សេដ្ឋារិន